ក

# មាតិកា

## I.ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១.ព្រះរាជក្រម


២៩-១០-២០១០-ព្រះរាជក្រម នស/រកម/១០១០/០១៦ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ *(ត មកពីរាជកិច្ច លេខ ៨៣)* ៨៦១៦


### ២.ព្រះរាជក្រឹត្យ


០៣-១១-២០១០-ព្រះរាជក្រឹត្យ នស/រកត/១១១០/៨៤៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ សប្បុរសជន វៀតណាម ចំនួន ០២ រូប ៨៦៧៣

០៣-១១-២០១០-ព្រះរាជក្រឹត្យ នស/រកត/១១១០/៨៥០ ស្តីពី ការតែងតាំងលោក **ង៉ាម អេងហុង** និង លោក **យួយ ត្រី** ជា ឧកញ៉ា ៨៦៧៤

០៣-១១-២០១០-ព្រះរាជក្រឹត្យ នស/រកត/១១១០/៨៥១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ ចំនួន ០៧ រូប ៨៦៧៥

០៤-១១-២០១០ -ព្រះរាជក្រឹត្យ នស/រកត/១១១០/៨៥២ ស្តីពី ការលើកលែងទោសឱ្យទណ្ឌិតចំនួន ០១ នាក់ ៨៦៧៦

០៤-១១-២០១០ -ព្រះរាជក្រឹត្យ នស/រកត/១១១០/៨៥៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សុវត្ថារា តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ០២ រូប នៅខេត្តព្រះសីហនុ និង នៅក្រុងព្រៃវែង ៨៦៧៧

០៤-១១-២០១០ -ព្រះរាជក្រឹត្យ នស/រកត/១១១០/៨៥៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ចំពោះ សប្បុរសជន បរទេស ចំនួន ០២ រូប ៨៦៧៨

០៤-១១-២០១០ -ព្រះរាជក្រឹត្យ នស/រកត/១១១០/៨៥៦ ស្តីពី ការបញ្ចប់ភារកិច្ចឯកឧត្តម **ចាន់ ម៉ែន** ពីទីប្រឹក្សារាជរដ្ឋាភិបាល ៨៦៧៩


## II.រាជរដ្ឋាភិបាល

### អនុក្រឹត្យ


១០-១១-២០១០-អនុក្រឹត្យលេខ ១០៨៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨៦៨០

១០-១១-២០១០-អនុក្រឹត្យលេខ ១០៨៧ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ៨៦៨១
១០-១១-២០១០-អនុក្រឹត្យលេខ ១០៨៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៨៦៨២
១០-១១-២០១០-អនុក្រឹត្យលេខ ១០៨៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨៦៨៣
១០-១១-២០១០-អនុក្រឹត្យលេខ ១០៩០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨៦៨៦
១០-១១-២០១០-អនុក្រឹត្យលេខ ១០៩១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨៦៨៧
១០-១១-២០១០-អនុក្រឹត្យលេខ ១០៩២ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៨៦៨៨
១០-១១-២០១០-អនុក្រឹត្យលេខ ១០៩៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៨៦៨៩
១០-១១-២០១០-អនុក្រឹត្យលេខ ១០៩៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៨៦៩២
១០-១១-២០១០-អនុក្រឹត្យលេខ ១០៩៥ អនក្រ.តត ស្តីពី ការជូនមេដាយមាសការងារ ៨៦៩៣
១០-១១-២០១០-អនុក្រឹត្យលេខ ១០៩៦ អនក្រ.តត ស្តីពី ការជូនមេដាយមាសការងារ ៨៦៩៥
១០-១១-២០១០-អនុក្រឹត្យលេខ ១០៩៧ អនក្រ.តត ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ៨៧០២
១០-១១-២០១០-អនុក្រឹត្យលេខ ១០៩៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨៧០៥
១០-១១-២០១០-អនុក្រឹត្យលេខ ១០៩៩ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៨៧០៦

## III. ការងារបណ្តាក្រសួង

### ១. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០២-១១-២០១០-ប្រកាសលេខ ៨៩៥ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន មីស្ទូន រ៉ាប់បើរ អ៊ីមផត អិចផត បង្កើតរោងចក្រ ផលិតកៅស៊ូក្រែប ៨៧០៧
០២-១១-២០១០-ប្រកាសលេខ ៨៩៦ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ា យ៉ាង ហ្គាមេន (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៨៧១១

### ២. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៨-០១-២០១០ -លិខិតបញ្ជាក់លេខ ០៥១៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ឥសាន្ត កៅស៊ូ រតន: ៨៧១៥
២៨-០១-២០១០ -លិខិតបញ្ជាក់លេខ ០៥២០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ស៊ីស៊ីអ គ្រេឌីត & អ៊ែតទើថាយស៊ីង ៨៧១៧
២៩-០១-២០១០ -លិខិតបញ្ជាក់លេខ ០៥២៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់សាខាក្រុមហ៊ុន ហ្គោ អ៊ី អិន ស៊ី ៨៧១៩

២៩-០១-២០១០ -លិខិតបញ្ជាក់លេខ ០៩៣៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់សាខាក្រុមហ៊ុន **អិល អិន អេស ខេ ខនស្ត្រាក់សិន** ៨៧២០

២៩-០១-២០១០ -លិខិតបញ្ជាក់លេខ ០៩៤០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សាន់ ”រត (ខេមបូឌា) អុិមផត អិចផត** ៨៧២២

២៩-០១-២០១០ -លិខិតបញ្ជាក់លេខ ០៩៤១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី ”រ៉ានី អុិម្ភិច** ៨៧២៤

២៩-០១-២០១០ -លិខិតបញ្ជាក់លេខ ០៩៤២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គ្រាឌ៊ិច (ខេមបូឌា)** ៨៧២៦

២៩-០១-២០១០ -លិខិតបញ្ជាក់លេខ ០៩៤៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិន.អេ.ខេ.អ៊ែតវ៉ានស៍ត្រេឌីង** ៨៧២៨

២៩-០១-២០១០ -លិខិតបញ្ជាក់លេខ ០៩៤៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វីម៉ូត អ៊ែតសេស មេនេចមេនថេគណូឡូជី (អេមថេត)** ៨៧៣០

*ត មកពីរាជកិច្ច លេខ ៨៣*

# ព្រះរាជក្រម

នស/រកម/១០១០/០១៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០ នាសម័យប្រជុំវិសាមញ្ញ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង
## បង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ ដែលបានចុះហត្ថលេខានៅទីក្រុងឆាអាំ ព្រះរាជាណាចក្រថៃឡង់ដ៍ នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩ ដូចមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

ពរ/រក.១០១០.៩៥២

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋមន្ត្រីស្តីទី

**ហត្ថលេខា**

**ភឹម ស៊ីផន**

**លេខ:៧៣៩ ច.ល**

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ វិច្ឆិកា ឆ្នាំ២០១០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

2/2

# ជំពូក ១២
# សហប្រតិបត្តិការសេដ្ឋកិច្ច

## មាត្រា ១
## ទំហំ និង គោលដៅ

១- បណ្តាភាគីទាំងអស់បានបញ្ជាក់ឡើងវិញ នូវសារៈសំខាន់នៃគំនិតផ្តួចផ្តើមសហប្រតិបត្តិការសេដ្ឋកិច្ច ដែលកំពុងកើតមានឡើងរវាងអាស៊ាន-អូស្ត្រាលី និងណូវែលហ្សេឡង់. និងបានឯកភាពដើម្បីបំពេញនូវភាពជាដៃគូផ្នែកសេដ្ឋកិច្ចដែលមានស្រាប់របស់ខ្លួនក្នុងគ្រប់វិស័យ ដែលបណ្តាភាគីទាំងអស់មានចំណាប់អារម្មណ៍ទៅវិញទៅមក. ដោយលើកយកមកពិចារណានូវកំរិតនៃការអភិវឌ្ឍន៍ផ្សេងៗគ្នា នៃបណ្តាភាគីទាំងអស់។

២- បណ្តាភាគីទាំងអស់ទទួលស្គាល់បទបញ្ញត្តិនានា ដើម្បីលើកទឹកចិត្ត និង ជួយសម្រួលកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ដោយរាប់បញ្ចូលនូវជំពូកផ្សេងៗទៀតនៃកិច្ចព្រមព្រៀងនេះ។

៣- កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច នៅក្រោមជំពូកនេះ និងជួយគាំទ្រដល់ការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ឆ្លងតាមសកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ច ដែលទាក់ទងដល់វិស័យពាណិជ្ជកម្ម ឬ វិនិយោគដូចដែលបានបញ្ជាក់នៅក្នុងកម្មវិធីការងារ។

## មាត្រា ២
## និយមន័យ

ដើម្បីជំពូកនេះ :

ក- **ភាគីដែលកំពុងអនុវត្ត ឬ បណ្តាភាគីដែលកំពុងអនុវត្ត** មានន័យថា. សំរាប់សមាសភាគនីមួយៗនៃកម្មវិធីការងារ, ភាគី ឬ បណ្តាភាគីដែលទទួលខុសត្រូវ សម្រាប់ការអនុវត្តនៃសមាសភាគនោះ

ខ- **កម្មវិធីការងារ** មានន័យថា កម្មវិធីសកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ច, ដែលបានរៀបចំទៅជាសមាសភាគ, ដែលបានបញ្ជាក់នូវអត្តសញ្ញាណទៅវិញទៅមក ដោយបណ្តាភាគីទាំងអស់មុនពេលដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន។

## មាត្រា ៣

## ធនធាន

១- ដោយការទទួលស្គាល់នូវគម្លាតអភិវឌ្ឍន៍ ក្នុងចំណោមបណ្តារដ្ឋសមាជិកអាស៊ាន និង ក្នុងចំណោមបណ្តាភាគីទាំងអស់, បណ្តាភាគីទាំងអស់នឹងចូលរួមវិភាគទានសមស្របដើម្បីអនុវត្តនៃកម្មវិធីការងារនេះ ។

២- ក្នុងការបញ្ជាក់នូវអត្តសញ្ញាណកំរិតនៃការចូលរួមវិភាគទានសមស្របដល់កម្មវិធីការងារ ភាគីទាំងអស់នឹងលើកយកមកពិចារណានូវ :

(ក) កំរិតនៃការអភិវឌ្ឍន៍ផ្សេងៗគ្នា និង សមត្ថភាពនៃបណ្តាភាគីទាំងអស់

(ខ) ការចូលរួមវិភាគទានតាមសទ្ធាណាមួយ ដែលនឹងអាចអនុវត្តបានចំពោះសមាសភាគកម្ម វិធីការងារដោយបណ្តាភាគីទាំងអស់

(គ) កំរិតនៃការចូលរួមវិភាគទានសមស្រប ធ្វើឱ្យប្រសើរដល់ទំនាក់ទំនង និងនិរន្តភាពនៃសហប្រតិបត្តិការ, ពង្រឹងភាពដៃគូរវាងបណ្តាភាគីទាំងអស់ និងកសាងនូវការសន្យា ដែលបានចូលរួមដោយបណ្តាភាគីទាំងអស់ ដើម្បីធ្វើឱ្យការអនុវត្តន៍កាន់តែមានប្រសិទ្ធភាព និងការត្រួតពិនិត្យនៃសមាសភាគកម្មវិធីការងារ ។

## មាត្រា ៤

## កម្មវិធីការងារសហប្រតិបត្តិការសេដ្ឋកិច្ច

១- សមាសភាគកម្មវិធីការងារនីមួយៗ នឹង :

ក- ជាប់ទាក់ទងដល់វិស័យពាណិជ្ជកម្ម និងវិនិយោគ និង គាំទ្រដល់ការអនុវត្តន៍នៃកិច្ចព្រមព្រៀងនេះ

ខ- ត្រូវបានបញ្ជាក់នៅក្នុងកម្មវិធីការងារ

គ- ជាប់ពាក់ព័ន្ធជាអប្បបរមានៃរដ្ឋសមាជិកអាស៊ាន ២, អូស្ត្រាលី និង/ឬ ណូវែលហ្សេឡង់

ឃ- ថ្លែងបញ្ជាក់នូវអត្ថិភាពទៅវិញទៅមកនៃបណ្តាភាគីទាំងអស់ដែលបានកំពុងចូលរួម, និង

ង- ចៀសវាងការជាន់គ្នានូវសកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ចដែលមានស្រាប់ ប្រសិនបើអាចធ្វើបាន

២- ការពណ៌នានូវសមាសភាគ នៃកម្មវិធីការងារនីមួយៗ គួរបញ្ជាក់ឱ្យបានពិស្តារដែលចាំបាច់ផ្តល់នូវភាពច្បាស់លាស់ ដល់ភាគីទាំងអស់ដោយយោងទៅលើគោលដៅ និងគោលបំណងនៃសមាសភាគទាំងនោះ ។

## មាត្រា ៥
## ចំណុចប្រសព្វសំរាប់ការអនុវត្តន៍

១- ភាគីនីមួយៗ ត្រូវតែងតាំងនូវចំនុចប្រសព្វសំរាប់រាល់បញ្ហាទាំងឡាយ ដែលទាក់ទងនឹងការអនុវត្តន៍កម្មវិធីការងារ និងត្រូវឱ្យភាគីទាំងអស់ធ្វើទំនើបកម្មទៅលើភាពពិស្តារនៃចំនុចប្រសព្វរបស់ខ្លួននីមួយៗ ។

២- ចំនុចប្រសព្វទាំងអស់នឹងត្រូវទទួលខុសត្រូវ និងរាយការណ៍ពីការអនុវត្តន៍កម្មវិធីការងារ ដោយអនុលោមតាមមាត្រា៦ (ការអនុវត្តន៍ និងការវាយតំលៃលើសមាសភាគនៃកម្មវិធីការងារ) និងមាត្រា៧ (ការពិនិត្យមើលឡើងវិញនូវកម្មវិធីការងារ) និងសម្រាប់ឆ្លើយតបទៅនឹងសំនួរទាំងឡាយពីភាគីណាមួយ ដែលទាក់ទងទៅ នឹងកម្មវិធីការងារ ។

## មាត្រា ៦
## ការអនុវត្តន៍ និងការវាយតំលៃទៅលើសមាសភាគនៃកម្មវិធីការងារ

១- មុនពេលនៃការចាប់ផ្តើមនៃអង្គប្រកបកម្មវិធីការងារនីមួយៗ ភាគីអនុវត្តណាមួយ ឬទាំងអស់ ដែលកំពុងធ្វើការពិគ្រោះយោបល់ជាមួយភាគីដែលចូលរួមពាក់ព័ន្ធ ត្រូវបង្កើតផែនការអនុវត្តន៍ទៅលើសមាសភាគនៃកម្មវិធីការងារនោះ និងត្រូវផ្តល់ផែនការនោះទៅគ្រប់ភាគីនីមួយៗ ។

២- ភាគីអនុវត្តន៍ណាមួយ ឬទាំងអស់ ទៅលើសមាសភាគនៃកម្មវិធីការងារ អាចប្រើយន្តការដែលមានស្រាប់សំរាប់ធ្វើការអនុវត្តន៍ទៅលើសមាសភាគនោះ ។

៣- រហូតដល់ការបញ្ចប់នៃសមាសភាគនៃកម្មវិធីការងារ ភាគីអនុវត្តន៍ណាមួយ ឬទាំងអស់ ត្រូវធ្វើការពិនិត្យមើល និងវាយតំលៃឱ្យបានទៀងទាត់ ទៅលើសមាសភាគដែលមានការជាប់ទាក់ទង និងផ្តល់នូវរបាយការណ៍ឱ្យបានទៀងទាត់ជូនទៅភាគីនីមួយៗ ដោយរួមទាំងរបាយការណ៍ចុងក្រោយនៃការបញ្ចប់របស់សមាសភាគនោះ ។

## មាត្រា ៧

## ការពិនិត្យមើលឡើងវិញនូវកម្មវិធីការងារ

គេត្រូវធ្វើការពិនិត្យមើលលើកម្មវិធីការងារឡើងវិញ នៅឯទីចាត់ការរបស់គណៈកម្មាធិការរួមរបស់ FTA ដើម្បីប៉ាន់ស្មានលើប្រសិទ្ធិភាពជាទូទៅរបស់វា និងដើម្បីផ្តល់នូវអនុសាសន៍នានា។ គណៈកម្មាធិការរួមរបស់ FTA អាចធ្វើការកែប្រែទៅលើកម្មវិធីការងារ និងអាចលើកមកពិចារណាលើការពិនិត្យឡើងវិញ និងធនធានដែលមាន។

## មាត្រា ៨

## ការមិនអនុវត្តន៍ នូវកថាខ័ណ្ឌ ១៧ (ការពិគ្រោះយោបល់ និងដំណោះស្រាយវិវាទ)

កថាខ័ណ្ឌ ១៧ (ការពិគ្រោះយោបល់ និងដំណោះស្រាយវិវាទ) មិនអាចអនុវត្តទៅលើបញ្ហាណាមួយដែលកើតឡើងនៅក្រោមកថាខ័ណ្ឌនេះទេ។

# ជំពូក ១៣
# កម្មសិទ្ធិបញ្ញា

## មាត្រា ១
## គោលបំណង

ភាគីនីមួយៗ ប្តេជ្ញាកាត់បន្ថយនូវឧបសគ្គក្នុងការធ្វើពាណិជ្ជកម្ម និងវិនិយោគ ដោយលើកកំពស់សមាហរណកម្មសេដ្ឋកិច្ចឱ្យបានស៊ីជម្រៅថែមទៀត តាមរយៈការបង្កើត ការប្រើប្រាស់ ការការពារ និង ការអនុវត្តកម្មសិទ្ធិបញ្ញាឱ្យបានពេញលេញប្រកបដោយប្រសិទ្ធិភាព ដោយពិចារណាទៅលើកម្រិតខុសគ្នានៃសមត្ថភាព និងការអភិវឌ្ឍសេដ្ឋកិច្ច និងភាពខុសគ្នានៃប្រព័ន្ធច្បាប់ជាតិ និងភាពចាំបាច់ ដើម្បីរក្សាបានតុល្យភាពសមស្រប រវាងម្ចាស់សិទ្ធិកម្មសិទ្ធិបញ្ញា និងផលប្រយោជន៍ស្របច្បាប់របស់អ្នកប្រើប្រាស់ ចំពោះកម្មវត្ថុ ដែលត្រូវបានការពារដោយកម្មសិទ្ធិបញ្ញា ។

## មាត្រា ២
## និយមន័យ

ក្នុងគោលបំណងនៃជំពូកនេះ :

ក. កម្មសិទ្ធិបញ្ញាសំដៅទៅលើសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល សិទ្ធិលើម៉ាក និង ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គំនូរឧស្សាហកម្ម ប្រកាសនីយបត្រតក្កកម្ម និង គំនូសនៃសៀគ្វីបង្រួមបញ្ចូលគ្នា ពូជថ្មីនៃដំណាំ និង ព័ត៌មានសម្ងាត់ ដូចមានចែងក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា និង

ខ. WIPO មានន័យថា អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ។

## មាត្រា ៣
## ការបញ្ជាក់របស់កិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា

ភាគីនីមួយៗ ប្រកាសទទួលស្គាល់សិទ្ធិ និង កាតព្វកិច្ចគ្នាទៅវិញទៅមក ស្របតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា ។

## មាត្រា ៤
## ប្រព្រឹត្តិកម្មជាតិ

១. ភាគីនីមួយៗ ត្រូវអនុលោមតាមប្រព្រឹត្តិកម្មជាតិគ្នាទៅវិញទៅមកដោយមិនលំអៀង ចំពោះការការពារ[១] កម្មសិទ្ធិបញ្ញាទៅលើជាតិសាសន៍របស់ខ្លួនឡើយ លើកលែងតែមានអញ្ញត្រកម្មដែលចែងក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា និង កិច្ចព្រមព្រៀងពហុភាគីដែលបានចុះហត្ថលេខា ក្រោមក្របខ័ណ្ឌអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

២. ភាគីនីមួយៗ អាចប្រើប្រាស់អញ្ញត្រកម្ម ដូចមានចែងក្នុងកថាខណ្ឌ ១ ខាងលើ ដែលពាក់ព័ន្ធទៅនឹងនីតិវិធីរដ្ឋបាល និង នីតិវិធីតុលាការរបស់ខ្លួន រួមបញ្ចូលទាំងការតម្រូវឱ្យប្រជាជាតិនៃភាគីដទៃទៀត ផ្តល់នូវអាសយដ្ឋានសម្រាប់ទំនាក់ទំនងនៅក្នុងដែនដីរបស់ខ្លួន ឬក៏ចាត់តាំងភ្នាក់ងារណាម្នាក់ក្នុងដែនដីរបស់ខ្លួន ក្នុងករណីដែលអញ្ញត្រកម្មនោះ :

ក. ចាំបាច់ធានាឱ្យមានអនុលោមភាពទៅតាមច្បាប់ និង បទប្បញ្ញត្តិ ដែលមិនផ្ទុយទៅនឹងជំពូកនេះ និង

ខ. មិនបង្កឱ្យមានលក្ខណៈណាមួយ ដែលរឹតត្បិតទៅលើការធ្វើពាណិជ្ជកម្ម។

## មាត្រា ៥
## សិទ្ធិអ្នកនិពន្ធ

១. ភាគីនីមួយៗត្រូវ :

ក. ផ្តល់សិទ្ធិផ្តាច់មុខទៅអោយអ្នកនិពន្ធ[២] ក្នុងការអនុញ្ញាតឱ្យផ្សព្វផ្សាយស្នាដៃរបស់ខ្លួនជាសាធារណៈតាមរយៈប្រពន្ធ័ ផ្សព្វផ្សាយមានខ្សែ ឬគ្មានខ្សែ

---

[១] សំរាប់គោលបំណងនៃកថាខណ្ឌនេះ ការការពាររាប់បញ្ចូលទាំងបញ្ហានានាដែលជះឥទ្ធិពលលើ ភាពសម្បូរបែប ការទាញយកចំណេះដឹង វិសាលភាព ការថែរក្សា និងការអនុវត្តកម្មសិទ្ធិបញ្ញាដូច ដែលមានក្នុងជំពូកនេះ។ លើសពីនេះសំរាប់គោលបំណងនៃកថាខ័ណ្ឌនេះ ការការពារក៏រាប់បញ្ចូលផងដែរនូវការហាមឃាត់ទៅលើការរំលោភនៃ វិធានការបច្ចេកវិទ្យា ដែលប្រកប ដោយប្រសិទ្ធិភាពដូចមានចែងក្នុងមាត្រា៥។

[២] សំរាប់គោលបំណងនៃជំពូកនេះ ស្នាដៃ រួមបញ្ចូលទាំងការថតបញ្ចូលជាខ្សែភាពយន្ត។

ខ. ផ្តន្ទាទោសតាមនីតិវិធីព្រហ្មទណ្ឌ និង ការដាក់ទណ្ឌកម្ម យ៉ាងហោចណាស់ក្នុងករណីដែលបុគ្គលមួយរំលោភសិទ្ធិអ្នកនិពន្ធដោយចេតនា ក្នុងគោលបំណងទាញយកអត្ថប្រយោជន៍ផ្នែកពាណិជ្ជកម្ម ឬទទួលផលហិរញ្ញវត្ថុ និង

គ. ជម្រុញមានការបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួម ដ៏សមស្របមួយ និង លើកទឹកចិត្តអង្គភាពនោះ ដើម្បីធ្វើប្រតិបត្តិការឱ្យមានប្រសិទ្ធភាព តម្លាភាពជាសាធារណៈ និង ការទទួលខុសត្រូវចំពោះសមាជិករបស់ខ្លួន។

២. ភាគីនីមួយៗត្រូវ ខិតខំប្រឹងប្រែង ៖

ក. ផ្តល់សិទ្ធិផ្តាច់មុខឱ្យអ្នកថតសម្លេង[៣] ក្នុងការអនុញ្ញាតឱ្យផ្សព្វផ្សាយជាសាធារណៈ នូវការថតសម្លេងរបស់ខ្លួនតាមរយៈប្រពន្ធ័ផ្សព្វផ្សាយមានខ្សែ ឬ គ្មានខ្សែ

ខ. ផ្តល់ការការពារតាមផ្លូវច្បាប់ឱ្យបានគ្រប់គ្រាន់ និង មធ្យោបាយផ្លូវច្បាប់ប្រកបដោយប្រសិទ្ធភាព ដើម្បីប្រឆាំងទៅនឹងការគេចវេសពីវិធានការបច្ចេកវិទ្យា[៤] ដែលបានប្រើប្រាស់ដោយម្ចាស់សិទ្ធិពាក់ព័ន្ធនឹងការប្រើសិទ្ធិអ្នកនិពន្ធរបស់ពួកគេ និង វិធានការដែលរឹតត្បិត នូវសកម្មភាពនានាដែលពាក់ព័ន្ធនឹងស្នាដៃរបស់ពួកគេ ដោយពុំមានការអនុញ្ញាត ពីម្ចាស់សិទ្ធិអ្នកនិពន្ធដែលពាក់ព័ន្ធ ឬ មិនត្រូវបានអនុញ្ញាតដោយច្បាប់ និង

គ. ផ្តន្ទាទោសតាមនីតិវិធីព្រហ្មទណ្ឌ និង ដាក់ទណ្ឌកម្មយ៉ាងហោចណាស់ ក្នុងករណីដែលបុគ្គលមួយរំលោភធ្ងន់ធ្ងរដោយចេតនា ទៅលើសិទ្ធិអ្នកនិពន្ធ ដែលច្បាប់ហាមឃាត់ ទោះបីមិនមានបំណងទាញយកអត្ថប្រយោជន៍ផ្នែកពាណិជ្ជកម្ម ឬ ទទួលផលហិរញ្ញវត្ថុ ប៉ុន្តែវាធ្វើឱ្យខូចប្រយោជន៍ធ្ងន់ធ្ងរដល់ម្ចាស់សិទ្ធិអ្នកនិពន្ធ។

---

[៣] ក្នុងករណីដែលភាគីមួយជាសមាជិក ឬ នឹងក្លាយជា សមាជិកនៃ សន្ធិសញ្ញាហ្វូណូក្រាម និង ការសម្តែងរបស់ អង្គការកម្មសិទ្ធិបញ្ញាពិភពលោក កាតព្វកិច្ចរបស់ភាគីនៅក្នុងកថាខណ្ឌនេះ ត្រូវអនុលោមទៅតាមការប្តេជ្ញាចិត្ត និងការរក្សាទុក ដែលភាគីនោះបានធ្វើឡើងក្រោមសន្ធិសញ្ញាហ្វូណូក្រាម និងការសម្តែងរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

[៤] សំរាប់គោលបំណងនៃជំពូកនេះ "វិធានការបច្ចេកវិទ្យាប្រកបដោយប្រសិទ្ធិភាព" មានន័យថា ជាបច្ចេកវិទ្យា ឧបករណ៍ ឬ សមាសភាពណាមួយដែលបានប្រើប្រាស់ដោយម្ចាស់សិទ្ធិអ្នកនិពន្ធ ដែលពាក់ពន្ធ័ទៅនឹងការប្រើប្រាស់សិទ្ធិអ្នកនិពន្ធរបស់ពួកគេ និងវិធានការដែលរឹតត្បិតនូវសកម្មភាពនានា ដែលពាក់ព័ន្ធនឹងស្នាដៃរបស់ពួកគេ ឬ ការថតសម្លេង ដែលពុំមានការអនុញ្ញាតដោយម្ចាស់សិទ្ធិសិទ្ធិអ្នកនិពន្ធដែលពាក់ព័ន្ធ ឬ មិនត្រូវបានអនុញ្ញាតដោយច្បាប់។

## មាត្រា ៦

## ការប្រើប្រាស់សូហ្វវែររបស់រដ្ឋាភិបាល

ភាគីនីមួយៗ ត្រូវបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់ខ្លួន :

ក. រក្សាច្បាប់ បទប្បញ្ញត្តិ ឬ គោលនយោបាយ ដែលរៀបចំសម្រាប់ ភ្នាក់ងាររដ្ឋាភិបាលកណ្តាលរបស់ខ្លួន ដើម្បីបន្តការប្រើប្រាស់សូហ្វវែកុំព្យូទ័រស្របច្បាប់តាមរបៀប ដែលច្បាប់អនុញ្ញាត និងអនុលោមតាមជំពូកនេះ និង

ខ. លើកទឹកចិត្តរដ្ឋាភិបាលក្នុងស្រុក និងតំបន់នីមួយៗ ដើម្បីរក្សា ឬអនុម័ត វិធានការប្រហាក់ប្រហែល ។

## មាត្រា ៧

## ម៉ាក និង ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

១. ភាគីនីមួយៗត្រូវរក្សាប្រព័ន្ធចំណាត់ថ្នាក់ម៉ាក ដែលអនុលោមទៅតាមកិច្ចព្រមព្រៀងទីក្រុងនីសស្តីអំពីចំណាត់ថ្នាក់អន្តរជាតិនៃទំនិញ និងសេវា សំរាប់ការចុះបញ្ជីម៉ាក ដែលបានធ្វើវិសោធនកម្មជាបន្តបន្ទាប់ ។

២. ភាគីនីមួយៗ ត្រូវផ្តល់សិទ្ធិការពារម៉ាក ដែលប្រកបដោយគុណភាពខ្ពស់ តាមរយៈការត្រួតពិនិត្យខ្លឹមសារម៉ាក បែបបទដាក់ពាក្យ និង តាមរយៈប្តឹងជំទាស់ និង នីតិវិធីលុបម៉ាក ។

៣. ភាគីនីមួយៗ ត្រូវការពារម៉ាក ដែលបានចុះបញ្ជីក្រោមយុត្តាធិការរបស់ខ្លួន មុនម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដោយអនុលោមទៅតាមច្បាប់ក្នុងស្រុក និង កិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា ។

៤. ភាគីនីមួយៗត្រូវទទួលស្គាល់ថា ម៉ាកសម្គាល់ភូមសាស្ត្រទំនិញ អាចត្រូវបានការពារតាមរយៈប្រព័ន្ធម៉ាក ។

## មាត្រា ៨

## ប្រភពជីវសាស្ត្រចម្រុះ ចំណេះដឹងប្រពៃណី និង ទំនៀមទំលាប់អ្នកស្រុក

អនុលោមតាមកាតព្វកិច្ចអន្តរជាតិរបស់ភាគីនីមួយៗ ភាគីនីមួយៗអាចដាក់ចេញវិធានការសមស្រប ដើម្បីការពារប្រភពជីវសាស្ត្រ ចម្រុះ ចំណេះដឹងប្រពៃណី និង ទំនៀមទំលាប់អ្នកស្រុក ។

## មាត្រា ៩

## កិច្ចសហប្រតិបត្តិការ

១. ភាគីទាំងអស់ទទួលស្គាល់ភាពខុសគ្នាខ្លាំងនៃសមត្ថភាពរបស់ភាគីមួយចំនួន លើវិស័យកម្មសិទ្ធិបញ្ញា។ ដោយយកចិត្តទុកដាក់ពីបញ្ហានេះ នៅពេលដែលភាគីមួយមិនមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការអនុវត្តជំពូកនេះ ភាគីផ្សេងទៀត ក្នុងករណីសមស្រប និងតាមសំណើ ត្រូវតែខិតខំប្រឹងប្រែងផ្តល់កិច្ចសហប្រតិបត្តិការឱ្យទៅភាគីនោះ ដើម្បីជួយអនុវត្តជំពូកនេះ ។

២. តាមសំណើរបស់ភាគីមួយ ភាគីដទៃទៀតអាចផ្តល់ជាជំនួយទៅឱ្យភាគីដែលស្នើសុំក្នុងគោលបំណង ដើម្បីលើកកំពស់ក្របខណ្ឌជាតិ ដើម្បីការទទួលបានចំណេះដឹង ការការពារ ការអនុវត្ត ការប្រើប្រាស់ និង ការបង្កើតកម្មសិទ្ធិបញ្ញា ក្នុងទស្សនៈវិស័យអភិវឌ្ឍន៍ប្រព័ន្ធកម្មសិទ្ធិបញ្ញា ដែលជំរុញមានការច្នៃប្រឌិតក្នុងស្រុក នៅក្នុងប្រទេសដែលជាភាគីស្នើសុំ។

៣. ភាគីទាំងអស់ព្រមព្រៀងលើកកំពស់កិច្ចចរចា អំពីកម្មសិទ្ធិបញ្ញា ដោយរួមបញ្ចូល :

ក. ការចាត់តាំងអង្គភាពទំនាក់ទំនងនៅតាមភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធនានា ដែលរួមបញ្ចូលអង្គភាពទំនាក់ទំនងសម្រាប់ ការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញានៅតាមព្រំដែន

ខ. ការជម្រុញទំនាក់ទំនងគ្នា រវាងអ្នកជំនាញខាងកម្មសិទ្ធិបញ្ញា ក្នុងគោលបំណងពង្រីកការយល់ដឹង ឱ្យកាន់តែទូលំទូលាយ អំពីប្រព័ន្ធកម្មសិទ្ធិបញ្ញារៀង១ខ្លួន, និង

គ. ផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងការរំលោភកម្មសិទ្ធិបញ្ញា ដែលអនុលោមទៅតាមច្បាប់ របស់ភាគីនីមួយ១។

៤. ភាគីទាំងអស់ត្រូវខិតខំប្រឹងប្រែងធ្វើកិច្ចសហប្រតិបត្តិការដើម្បីលើកកំពស់ប្រសិទ្ធិភាព និងតម្លាភាពនៃប្រព័ន្ធចុះបញ្ជី និង ប្រព័ន្ធរដ្ឋបាលកម្មសិទ្ធិបញ្ញា ដោយរួមបញ្ចូលការផ្លាស់ប្តូរព័ត៌មានទាក់ទងនឹងការអភិវឌ្ឍន៍ប្រព័ន្ធទាំងនេះ និង ការអភិវឌ្ឍន៍ការចូលទៅកាន់ប្រព័ន្ធទិន្នន័យចុះបញ្ជីជាសាធារណៈ ។

៥. ភាគីទាំងអស់ត្រូវខិតខំប្រឹងប្រែងធ្វើកិច្ចសហប្រតិបត្តិការ ដើម្បីលើកកំពស់ការអប់រំ និងចំណេះដឹង ដែលទាក់ទងទៅនឹងផលប្រយោជន៍នៃការការពារ និង ការអនុវត្តកម្មសិទ្ធិបញ្ញាប្រកបដោយប្រសិទ្ធិភាព។

៦. ភាគីទាំងអស់ត្រូវចូលរួមសហប្រតិបត្តិការលើវិធានការតាមព្រំដែន ក្នុងទស្សនៈវិស័យលុបបំបាត់ពាណិជ្ជកម្មដែលរំលោភបំពានកម្មសិទ្ធិបញ្ញា។ ភាគីដែលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ត្រូវសហការគ្នាទៅវិញទៅ

មក ក្នុងការគាំទ្រការអនុវត្តប្រកបដោយប្រសិទ្ធភាព នៃតំរូវការនានាដែលទាក់ទង ទៅនឹងវិធានការតាមព្រំដែន ដែលបានកំណត់នៅក្នុងមាត្រា ៥១ ដល់មាត្រា ៦០ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា ។

៧. ដោយទទួលស្គាល់សារៈសំខាន់នៃការសម្រេចឱ្យបានគោលបំណងនៃជំពូកនេះ ក្នុងករណីដែលភាគីណាមួយមានបំណងចូលជាសមាជិកសន្ធិសញ្ញាណាមួយខាងក្រោមនេះ ភាគីនោះអាចស្វែងរកកិច្ចសហប្រតិបត្តិការជាមួយភាគីដទៃទៀត ដើម្បីគាំទ្រដំណើរការចូលជាសមាជិករបស់ខ្លួន និង ការអនុវត្តសន្ធិសញ្ញាខាងក្រោម ៖

ក. សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ឆ្នាំ ១៩៧០

ខ. កិច្ចព្រមព្រៀងទីក្រុងស្ត្រាសបឺកស្តីពីចំណាត់ថ្នាក់ប្រកាសនីយបត្រតក្កកម្មអន្តរជាតិ ឆ្នាំ ១៩៧១

គ. សន្ធិសញ្ញាទីក្រុងប៊ុយដាប៉ែសស្តីពីការទទួលស្គាល់ជាអន្តរជាតិ នៃការតម្កល់អតិសុខុមប្រាណ សំរាប់គោលបំណងនៃនីតិវិធីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ ១៩៧៧

ឃ. ពិធីសារទាក់ទងទៅនឹងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីតស្តីពីការចុះបញ្ជីម៉ាកជាអន្តរជាតិ ឆ្នាំ ១៩៨៩

ង. សន្ធិសញ្ញាច្បាប់ប្រកាសនីយបត្រតក្កកម្ម ឆ្នាំ ២០០០

ច. អនុសញ្ញាអន្តរជាតិស្តីពីការការពារពូជថ្មីនៃដំណាំ ឆ្នាំ ១៩៩១

ឆ. កិច្ចព្រមព្រៀងពាណិជ្ជកម្មទាក់ទងកម្មសិទ្ធិបញ្ញា

ជ. សន្ធិសញ្ញាសិង្ហបុរី ស្តីពីច្បាប់ម៉ាក ឆ្នាំ ២០០៦

ឈ. សន្ធិសញ្ញា ស្តីពីសិទ្ធិអ្នកនិពន្ធរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកឆ្នាំ ១៩៩៦

ញ. សន្ធិសញ្ញា ស្តីពីការសម្តែង និង ហ្វូណូក្រាមរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ឆ្នាំ ១៩៩៦

៨. តាមសំណើ និងការពិចារណាដោយសមរម្យ ភាគីនីមួយៗត្រូវខិតខំប្រឹងប្រែងធ្វើកិច្ចសហប្រតិបត្តិការក្នុងការគាំទ្រភាគីណាមួយ ក្នុងការអនុវត្តប្រព័ន្ធរួម[៥] មួយនៃការចុះបញ្ជីម៉ាក។

៩. រាល់កិច្ចសហប្រតិបត្តិការអនុលោមតាមមាត្រានេះ គឺយោងទៅតាមធនធានដែលមាន។

[៥] ប្រព័ន្ធរួមនៃម៉ាកមិនកម្រិតទៅលើ វិសាលភាពនៃម៉ាក ដែលអាចចុះបញ្ជីបាន ហើយម៉ាកដែលអនុញ្ញាតអោយចុះបញ្ជីបាន លុះត្រាតែវាមានលក្ខណៈខុសគ្នានៃទំនិញ ឬ សេវា ដូចជាទ្រង់ទ្រាយ រូបភាពនៃសំបកវេចខ្ចប់ ម៉ាកដែលមានពណ៌មួយ ឬ មានពណ៌ចំរុះ សម្លេង និងក្លិន។

## មាត្រា ១០

## តម្លាភាព

១. ភាគីនីមួយៗ ត្រូវធានាថា ច្បាប់ និង បទប្បញ្ញត្តិរបស់ខ្លួនដែលអនុវត្តជាទូទៅ ទាក់ទងទៅនឹងភាពសម្បូរបែប វិសាលភាព ការទទួលបាន ការអនុវត្ត និង ការទប់ស្កាត់នៃការរំលោភកម្មសិទ្ធិបញ្ញា ត្រូវបង្កើតឱ្យមានជាសាធារណៈ យ៉ាងហោចណាស់ជាភាសាជាតិ នៃភាគីនោះ ឬជាភាសាអង់គ្លេស។ ភាគីនីមួយៗ ត្រូវខិតខំប្រឹងប្រែងដាក់អោយមាន ជាសាធារណៈ នូវសេចក្តីសម្រេចចុងក្រោយរបស់តុលាការ និង វិធានរដ្ឋបាល ដែលពាក់ព័ន្ធទៅនឹងបញ្ហាដែលបាន និយាយខាងលើ យ៉ាងហោចណាស់ក៏បានជាភាសាជាតិរបស់ខ្លួន ឬជាភាសាអង់គ្លេស។

២. យោងតាមកថាខណ្ឌ ១ ភាគីនីមួយៗត្រូវខិតខំបង្កើតព័ត៌មានឱ្យមានជាសាធារណៈ ជាភាសាអង់គ្លេស និង ផ្សព្វផ្សាយតាមប្រព័ន្ធអាំងទែណែត។

៣. ភាគីនីមួយៗត្រូវខិតខំបង្កើតប្រព័ន្ធទិន្នន័យ នៃសិទ្ធិម៉ាកដែលបានចុះបញ្ជី និង ម៉ាកដែលបានព្យួរទុកនៅក្នុង យុត្តាធិការរបស់ខ្លួន ដាក់នៅលើប្រព័ន្ធអាំងទែណែត។

## មាត្រា ១១

## ការទទួលស្គាល់សម័យអន្តរកាល
## ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទាក់ទងកម្មសិទ្ធិបញ្ញា

អ្វីដែលមានចែងក្នុងជំពូកនេះ មិនត្រូវធ្វើបដិបញ្ញត្តិទៅនឹងសម័យអន្តរកាលណាមួយ ដែលត្រូវអនុវត្តនៃកិច្ច ព្រមព្រៀងពាណិជ្ជកម្មទាក់ទងកម្មសិទ្ធិបញ្ញា ដែលត្រូវបានយល់ព្រម ឬ អាចនឹងយល់ព្រមដោយក្រុមប្រឹក្សាទិដ្ឋភាព កិច្ចព្រមព្រៀងពាណិជ្ជកម្ម ទាក់ទងកម្មសិទ្ធិបញ្ញា ដែលបានបង្កើតឡើងតាមមាត្រា ៤ នៃកិច្ចព្រមព្រៀងអង្គការ ពាណិជ្ជកម្មពិភពលោក ទាំងមុន និង ក្រោយពីការចូលជាធរមានរបស់កិច្ចព្រមព្រៀងនេះ។

## មាត្រា ១២

## គណៈកម្មការកម្មសិទ្ធិបញ្ញា

១. ដោយទទួលស្គាល់សារៈសំខាន់នៃការសម្រេចគោលបំណងនៃជំពូកនេះ ភាគីទាំងអស់ត្រូវបង្កើតគណៈកម្មការ កម្មសិទ្ធិបញ្ញា រួមមានអ្នកតំណាងរបស់ភាគីនានា ដើម្បីត្រួតពិនិត្យមើលការអនុវត្ត និងការគ្រប់គ្រងនៃជំពូកនេះ។

២. គណៈកម្មការកម្មសិទ្ធិបញ្ញាត្រូវជួបប្រជុំគ្នាប្រចាំឆ្នាំ ឬតាមការកំណត់រវាងគ្នារបស់ភាគីទាំងឡាយ ។ កិច្ចប្រជុំអាចធ្វើឡើងដោយទល់មុខគ្នា ឬ តាមមធ្យោបាយផ្សេងៗទៀត ដែលកំណត់ឡើងដោយភាគីទាំងអស់ ។

៣. គណៈកម្មការកម្មសិទ្ធិបញ្ញា ត្រូវកំណត់ការងារ របស់ខ្លួន ដោយអនុលោមតាមជំពូកនេះ ។

៤. គណៈកម្មការកម្មសិទ្ធិបញ្ញា ត្រូវកំណត់កម្មវិធីការងារអាទិភាពរបស់ខ្លួន ដែលរៀបចំដោយភាគីទាំងអស់ ។

៥. ក្នុងពេលកំពុងបំពេញមុខងាររបស់ខ្លួន គណៈកម្មការកម្មសិទ្ធិបញ្ញា អាចប្រើប្រាស់យន្តការដែលមានស្រាប់ ឬបង្កើតយន្តការថ្មី ដើម្បីធ្វើឱ្យប្រសើរឡើង និងលើកកំពស់ការចរចារស្តីពីបញ្ហាកម្មសិទ្ធិបញ្ញា រវាងភាគីទាំងអស់ រួមទាំង ការផ្តល់កាលានុវត្តភាពសម្រាប់អ្នកដែលមានការពាក់ព័ន្ធ ដើម្បីផ្សារភ្ជាប់ជាមួយភាគីទាំងអស់លើបញ្ហានេះ ។

៦. ភាគីនីមួយៗ ត្រូវជូនដំណឹងទៅឱ្យគណៈកម្មការកម្មសិទ្ធិបញ្ញាជាប្រចាំឆ្នាំ ស្តីពីដំណើរការរីកចម្រើនចំពោះការប្តេជ្ញាចិត្តរបស់ខ្លួន ដែលមានចែងក្នុងមាត្រា ៥ (សិទ្ធិអ្នកនិពន្ធ) និងវឌ្ឍនភាពដែលទាក់ទងទៅនឹងការចូលជាសមាជិកសន្ធិសញ្ញា ដូចមានចែងក្នុងមាត្រា ៩.៧ (សហប្រតិបត្តិការ) ។ សេចក្តីជូនដំណឹងទាំងអស់ ត្រូវបញ្ជូនឱ្យគណៈកម្មការកម្មសិទ្ធិបញ្ញា យ៉ាងហោចណាស់ ៣០ ថ្ងៃ មុនកិច្ចប្រជុំប្រចាំឆ្នាំលើកទី១ របស់គណៈកម្មការកម្មសិទ្ធិបញ្ញា ។

# ជំពូក ១៤
# ការប្រកួតប្រជែង

## មាត្រា ១
## គោលការណ៍គ្រឹះ

១- ភាគីទទួលស្គាល់នូវសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការ ស្តីពីការជំរុញផ្នែកប្រកួតប្រជែង ប្រសិទ្ធិភាពសេដ្ឋកិច្ច សុខុមាលភាពអ្នកប្រើប្រាស់ និង កាត់បន្ថយការអនុវត្តន៍ប្រឆាំងនឹងការប្រកួតប្រជែង ។

២- ភាគីទទួលស្គាល់ភាពខុសគ្នាសំខាន់ៗនៃសមត្ថភាពរវាងប្រទេសសមាជិកអាស៊ាន អូស្ត្រាលី និង ណូវែលហ្សេឡង់ នៅក្នុងវិស័យនយោបាយប្រកួតប្រជែង ។

៣- ភាគីគោរពសិទ្ធិអធិបតេយ្យភាពភាគីនីមួយៗ ដើម្បីអភិវឌ្ឍន៍ រៀបចំ គ្រប់គ្រង និងអនុវត្តច្បាប់ និងនយោបាយស្តីពីការប្រកួតប្រជែងរបស់ប្រទេសនីមួយៗ ។

៤- នៅក្នុងជំពូកនេះមិនតម្រូវឱ្យភាគីម្ខាងអភិវឌ្ឍន៍ការប្រកួតប្រជែងពិសេស ដើម្បីតម្រូវការអនុវត្តន៍នៃការប្រឆាំងនឹងការប្រកួតប្រជែង ឬការពារភាគីណាមួយពីការអនុម័តនយោបាយនៅក្នុងវិស័យផ្សេងៗ ដូចជា ដើម្បីជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច ។

## មាត្រា ២
## សហប្រតិបត្តិការ

១- ភាគីអាចភ្ជាប់ចំណងកិច្ចសហប្រតិបត្តិការណ៍ដូចមានចែងក្នុងមាត្រា១ លើវិស័យប្រកួតប្រជែង ដែលរួមមាន :

(ក) ផ្លាស់ប្តូរបទពិសោធន៍ដែលទាក់ទងនឹងការជំរុញ និងការអនុវត្តន៍ច្បាប់ និងនយោបាយប្រកួតប្រជែង

(ខ) ផ្លាស់ប្តូរព័ត៌មានជាសាធារណៈស្តីពីច្បាប់ និងនយោបាយប្រកួតប្រជែង

(គ) ផ្លាស់ប្តូរមន្ត្រីក្នុងគោលបំណង ដើម្បីចូលរួមវគ្គបណ្តុះបណ្តាល

(ឃ) ផ្លាស់ប្តូរទីប្រឹក្សា និងជំនាញការទាក់ទងនឹងច្បាប់ និងនយោបាយប្រកួតប្រជែង

(ង) ការចូលរួមនៃមន្ត្រីក្នុងនាមជា គ្រូបង្រៀន/ទីប្រឹក្សា/អ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីច្បាប់ និងនយោបាយប្រកួតប្រជែង

(ច) ការចូលរួមនៃមន្ត្រីក្នុងកម្មវិធីជួយឧបត្ថម្ភ

(ឆ) សកម្មភាពផ្សេងៗទាក់ទងនឹងសេចក្តីផ្តើមនៃច្បាប់ប្រកួតប្រជែង និង

(ជ) បែបបទផ្សេងៗនៃសហប្រតិបត្តិការណ៍បច្ចេកទេស យោងតាមការឯកភាពរបស់ភាគី

២- នៅពេលដែលការប្រតិបត្តិជំពូកនេះត្រូវបានហាមឃាត់ដោយការបង្ខំ ប្រទេសអូស្ត្រាលី និង ណូវែល ហ្សេឡង់ អាចផ្តល់នូវកិច្ចសហប្រតិបត្តិការដែលពួកគេគិតថាសមហេតុផល ដើម្បីជួយប្រទេសសមាជិកអាស៊ាន។ កិច្ចសហប្រតិបត្តិការ គឺជាកម្មវត្ថុនៃទំនាក់ទំនងនយោបាយប្រកួតប្រជែង ដែលតម្រូវឱ្យកំណត់ធនធាន និង ធនធានដែលអាចមាន ដោយគោរពច្បាប់ និងបទប្បញ្ញត្តិរបស់ភាគី។

## មាត្រា ៣
## ចំណុចទំនាក់ទំនង

ដើម្បីធានាថា សហប្រតិបត្តិការណ៍ផ្នែកបច្ចេកទេសក្នុងជំពូកនេះកើតឡើងតាមគោលការណ៍គ្រឹះ ភាគី ត្រូវរៀបចំចំនុចទំនាក់ទំនងសំរាប់សហប្រតិបត្តិការផ្នែកបច្ចេកទេស និងការផ្លាស់ប្តូរព័ត៌មានក្នុងជំពូកនេះ។

## មាត្រា ៤
## ការមិនអនុវត្តន៍យន្តការដោះស្រាយវិវាទ

នីតិវិធីនៃការដោះស្រាយវិវាទនៅក្នុងកិច្ចព្រមព្រៀងនេះ មិនត្រូវអនុវត្តចំពោះបញ្ហាណាដែលកើតឡើង ក្នុងជំពូកនេះ។

172

# ជំពូក ១៥
# បទបញ្ញត្តិទូទៅ និងការលើកលែង

## មាត្រា ១
## ការលើកលែងទូទៅ

១. គោលបំណងរបស់ជំពូក ២ (ពាណិជ្ជកម្មទំនិញ) ជំពូក ៣ (វិធានប្រភពដើម) ជំពូក ៤ (នីតិវិធីគយ) ជំពូក ៥ (វិធានការអនាម័យ និងភូតគាមអនាម័យ) និង ជំពូក ៦ (ស្តង់ដារ បទបញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតំលៃទទួលស្គាល់គ្នា) មាត្រា ២០ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និង ពាណិជ្ជកម្ម ឆ្នាំ ១៩៩៤ (GATT 1994) និងត្រូវយកមកអនុវត្ត ហើយនឹងត្រូវយកមកដាក់នៅក្នុងផ្នែកនៃកិច្ចព្រមព្រៀងនេះ mutatis mutandis ។

២. គោលបំណងរបស់ជំពូក ៨ (ពាណិជ្ជកម្មសេវាកម្ម) ជំពូក ៩ (ការបំលាស់ទីរូបវន្តបុគ្គល) និង ជំពូក ១១ (ការវិនិយោគ). មាត្រា ១៤ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម រួមបញ្ចូលទាំង លេខយោងនឹងត្រូវយកមកអនុវត្ត ហើយនិងត្រូវយកមកដាក់នៅក្នុងផ្នែកនៃកិច្ចព្រមព្រៀងនេះ mutatis mutandis ។

៣. គោលបំណងនៃកិច្ចព្រមព្រៀងនេះ សមាជិកនីមួយៗទទួលស្គាល់ថា វិធានការដែលអនុលោមទៅតាមមាត្រា ២០ (f) នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ឆ្នាំ១៩៩៤ រួមទាំង វិធានការសំខាន់ៗ ដើម្បីទប់ស្កាត់នូវការរក្សាទុកសម្បត្តិជាតិ ឬវិធានការដាក់លាក់នៃប្រវត្តិសាស្ត្រ ឬវាយតំលៃបុរាណវិទ្យា ឬវិធានការសំខាន់ៗ ដើម្បីគាំទ្រវិចិត្រសិល្បៈជាតិ ។

៤. គោលបំណងនៃជំពូក ៨ (ពាណិជ្ជកម្មសេវាកម្ម) ហើយជំពូក ១១ (ការវិនិយោគ) តំរូវឱ្យមិនអនុវត្តតាមលក្ខណៈមួយ ដែលបំពារបំពាន ឬការរើសអើងមិនសមហេតុផលរវាងសមាជិកនានា ដែលមានលក្ខណៈដូចគ្នា ឬក៏បង្ហាញពីការរិតត្បិតលើពាណិជ្ជកម្មសេវាកម្ម ឬវិនិយោគ គ្មានអ្វីនៅក្នុងកថាភាគទាំងនេះត្រូវបកស្រាយដើម្បីទប់ស្កាត់ការអនុវត្តន៍ ឬដាក់ឱ្យអនុវត្តដោយវិធានការចាំបាច់របស់សមាជិកណាមួយ ដើម្បីទប់ស្កាត់នូវការរក្សាទុកសម្បត្តិជាតិ ឬវិធានការដាក់លាក់នៃប្រវត្តិសាស្ត្រ ឬវាយតំលៃបុរាណវិទ្យា ឬ វិធានការសំខាន់ៗ ដើម្បីគាំទ្រវិចិត្រសិល្បៈជាតិ ។

៥. សមាជិកនីមួយៗត្រូវប្រកាន់យកតាមទស្សនៈ កិច្ចពិគ្រោះយោបល់ ដើម្បីឈានទៅឯកភាពគ្នាកែសំរួលចំនុចចាំបាច់ ដោយតំរូវឱ្យរក្សាតុល្យភាពការសន្យាទាំងអស់ ដែលបានដាក់ចេញដោយសមាជិកនិមួយៗ ក្រោមជំពូក ៨

(ពាណិជ្ជកម្មសេវាកម្ម) និងជំពូក ១១ (ការវិនិយោគ) ប្រសិនបើមានការស្នើដោយសមាជិកណាមួយ ដែលប៉ះពាល់ដោយសារវិធានការនានា នៅត្រង់កថាខ័ណ្ឌ ៤ ។

## មាត្រា ២
## ធានាលើការលើកលែង

១. គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ដែលត្រូវបកស្រាយអត្ថន័យ ៖

(ក) តំរូវឱ្យសមាជិកនីមួយៗ ផ្តល់នូវពត៌មាននានាឱ្យគេដឹងឮ ដែលគិតថាវាផ្ទុយទៅនឹងការធានាផលប្រយោជន៍សំខាន់ៗ ។

(ខ) ទប់ស្កាត់សមាជិកនិមួយៗ ពីការចាត់វិធានការណាមួយ ដែលគិតថាចាំបាច់សំរាប់ការពារដល់ការធានាផលប្រយោជន៍សំខាន់ៗ ។

(i) ពាក់ពន្ធ័នឹងការចែងចែកសម្ភារៈ ឬក៏សម្ភារៈ ដែលពួកគេប្រមូលបាន

(ii) ពាក់ពន្ធ័នឹងចរាចរណ៍គ្រឿងសព្វាវុធ គ្រាប់រំសេវ និងការធ្វើសង្គ្រាម និងការធ្វើចរាចរទំនិញផ្សេងទៀត ឬវត្ថុធាតុដើមផ្សេងៗ ឬក៏ទាក់ទងនឹងការផ្គត់ផ្គង់សេវាកម្មនានា ដូចជា ការអនុវត្តផ្ទាល់ ឬប្រយោលក្នុងបំណងសំរាប់ផ្គត់ផ្គង់ ឬផ្តល់គ្រឿងចំបាំងដល់ការបង្កើតទ័ព ។

(iii) ធ្វើដូច្នេះ ដើម្បីទប់ស្កាត់នូវការរិះគន់ហេដ្ឋារចនាសម្ពន្ធ័សាធារណៈ រួមមានការទំនាក់ទំនងហេដ្ឋារចនាសម្ព័ន្ធថាមពល និងទឹក បានមកពីការខិតខំគិតទុក សំរាប់បំណងឱ្យបាត់បង់នូវសមត្ថភាព ឬខូចខាតដល់ហេដ្ឋារចនាសម្ពន្ធ័នានា ។

(iv) យកពេលប្រកាសអាសន្នជាតិ ឬសង្គ្រាម ឬក៏ប្រកាសអាសន្នផ្សេងទៅដាក់ក្នុងទំនាក់ទំនង ជាអន្តរជាតិ ។

(គ) ទប់ស្កាត់សមាជិកនីមួយៗ ពីការដាក់វិធានការនានា ដោយយកតាមការអនុវត្តន៍កថាខ័ណ្ឌអង្គការសហប្រជាជាតិ ដើម្បីការពារសន្តិភាព និងសន្តិសុខអន្តរជាតិ ។

២. គណៈកម្មការចំរុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ត្រូវតែជូនដំណឹង ដើម្បីបង្កើនវិធានការពេញលេញ ដែលអាចធ្វើទៅបាន ក្រោមកថាខណ្ឌ ១ (ក) និង (គ) ហើយនឹងការសំរេចចុងក្រោយរបស់គេ ។

## មាត្រា ៣
## វិធានការពន្ធដារ

១. លើកលែងតែអ្វីដែលមានចែងក្នុងមាត្រានេះ ប្រការដែលគ្មាននៅក្នុងកិច្ចព្រមព្រៀងនេះ នឹងត្រូវអនុវត្តតាមវិធានការពន្ធដារនានា ។

២. កិច្ចព្រមព្រៀងនេះ គ្រាន់តែផ្តល់សិទ្ធិ ឬដាក់កាតព្វកិច្ចផ្សេងៗ ឱ្យគោរពទៅតាមវិធានការពន្ធដារនានា ដែល :

(ក) សិទ្ធិទទួលខុសត្រូវ និងកាតព្វកិច្ច គឺត្រូវប្រមូលយក និងប្រតិបត្តិតាមកិច្ចព្រមព្រៀង WTO

(ខ) ប្រមូល ឬឱ្យបង់ពន្ធដារ តាមមាត្រា ៨ (ការបញ្ជូន) នៃជំពូក ១១ (វិនិយោគ) ឬ

(គ) ប្រមូល ឬយកពន្ធតាមមាត្រា ៩ (ការដកហូតយក និងការទូទាត់) នៃជំពូក ១១ (វិនិយោគ) ។

៣. នៅពេលដែលកថាខណ្ឌ ២ (ខ) ឬ (គ) យកមកអនុវត្តតាមច្បាប់គោលការណ៍ នោះផ្នែក ខ (ការវិវាទវិនិយោគរវាងសមាជិកមួយ និងអ្នកវិនិយោគ) នៃជំពូក ១១ (ការវិនិយោគ) ត្រូវអនុវត្តតាមច្បាប់វិធានការពន្ធដារ ។

៤. ប្រសិនបើមានជំលោះ នៅក្នុងមាត្រា ១៨.១ (វិសាលភាព និងនិយមន័យ) នៃជំពូក ១១ (វិនិយោគ) ដែលពាក់ព័ន្ធនឹងវិធានការពន្ធដារ គឺសមាជិកពាក់ព័ន្ធនីមួយៗ រួមទាំងអ្នកតំណាងការិយាល័យពន្ធដាររបស់គេ ត្រូវតែប្រកាន់យកកិច្ចពិគ្រោះយោបល់ផងគ្នា។ តុលាការកាត់ក្តី បង្កើតឡើងបានដោយអនុលោមតាមផ្នែក ខ (ការវិវាទវិនិយោគរវាងសមាជិកមួយ និងអ្នកវិនិយោគ) នៃជំពូក ១១ (វិនិយោគ) ត្រូវតែព្រមព្រៀងគ្នាតាមការពិចារណាដ៏ម៉ត់ចត់ ដើម្បីសំរេចយកចំនុចរួមទៅតាមសមាជិកនីមួយៗ ដូចនឹងអ្វីដែលចោទសួរតាមវិធានការពន្ធដារ ។ គោលបំណង នៃមាត្រា ២៥.៧ (រៀបចំតុលាការវិនិច្ឆ័យ) នៃជំពូក ១១ (វិនិយោគ) ត្រូវតែអនុវត្តតាមច្បាប់គោលការណ៍ mutatis mutandis ។

៥. គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ នឹងត្រូវប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ច នៃសមាជិកនានា ក្រោមអនុសញ្ញាពន្ធដារ ដែលត្រូវបង្ខំឱ្យគេចចេញពីការពិន័យពន្ធដារទ្វេដងរវាងសមាជិកនីមួយៗ។ នៅក្នុងករណី ដែលផ្ទុយនឹងវិធានពន្ធដាររវាងកិច្ចព្រមព្រៀងនេះ និងអនុសញ្ញាពន្ធដារ បន្ទាប់មកត្រូវតែអនុវត្តដូចគ្នា។ កិច្ចពិគ្រោះយោបល់នានា រវាងភាគីពាក់ព័ន្ធ ចំពោះអ្វីដែលផ្ទុយនឹងវិធានការពន្ធដារ ត្រូវតែឱ្យអាជ្ញាធរមានសមត្ថកិច្ចពន្ធដារអនុវត្តតាមច្បាប់ក្នុងស្រុក និងបទបញ្ញត្តិផ្សេងៗរបស់សមាជិកនីមួយៗ។ ការស្នើសុំសំរាប់កិច្ចពិគ្រោះយោបល់ ត្រូវតែយកមកដោះស្រាយតាមរយៈការិយាល័យទំនាក់ទំនង ដែលបានចាត់តាំងតាមមាត្រា ២ (ការទំនាក់ទំនង) នៃកថាភាគ ១៦ ។

៦. គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ តម្រូវឱ្យសមាជិកមួយផ្តល់នូវផលប្រយោជន៍ដល់សមាជិកមួយផ្សេងទៀត តាមប្រព្រឹត្តកម្មការអនុគ្រោះពិសេស ដែលបានមកពីអ្វីដែលមាន ឬការព្រមព្រៀងគ្នាជាបន្តបន្ទាប់ ជាមួយនឹងការគេចចេញពីការជាប់ពន្ធដារទ្វេដង ឬពី ខ ចែងនៃការគេចពន្ធទ្វេដង នៃកិច្ចព្រមព្រៀងអន្តរជាតិ ឬធ្វើឡើងដោយសមាជិកដែលបានចងកាតព្វកិច្ច។

៧. គោលបំណងនៃមាត្រានេះ គឺវិធានការពន្ធដារមិនដាក់បញ្ចូលនៅក្នុងពន្ធនាំចូល ឬពន្ធគយ។

## មាត្រា ៤
## វិធានការការពារតុល្យភាពចំណាយ

១. នៅពេលដែលសមាជិកមួយមានបញ្ហាតុល្យភាពចំណាយធ្ងន់ធ្ងរ និងការលំបាកហិរញ្ញវត្ថុពីខាងក្រៅ ឬក្រោមការគំរាមគំហែង គឺអាច :

(ក) ក្នុងករណីពាណិជ្ជកម្មទំនិញ ដោយយោងតាមកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្ម និងពន្ធគយ ឆ្នាំ ១៩៩៤ និងការយោគយល់គ្នាស្តីពីខចែងតុល្យភាពចំណាយ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្ម និងពន្ធគយ ឆ្នាំ១៩៩៤ ដូចមានក្នុងឧបសម្ព័ន្ធ ១ របស់កិច្ចព្រមព្រៀង ដែលអនុមត័លើការរឹតត្បិតវិធានការនាំចូល។

(ខ) ក្នុងករណីពាណិជ្ជកម្មសេវាកម្ម គឺអនុវត្ត ឬរឹតត្បិតពាណិជ្ជកម្មសេវាកម្ម ដែលអាចមានលើការសន្យាជាក់លាក់ រួមទាំងការចំណាយ ឬការផ្ទេរបញ្ជូនសំរាប់សកម្មភាពពាណិជ្ជកម្មពាក់ពន្ធ័ និងការសន្យាផ្តល់ឱ្យ។

(គ) ក្នុងករណីវិនិយោគ គឺអនុវត្ត ឬរឹតត្បិតលើការចំណាយ ឬផ្ទេរបញ្ជូនការវិនិយោគ ដូចដែលមានបង្ហាញនៅក្នុងមាត្រា ២ (ក) (និយមន័យ) នៃជំពូក ១១ (ការវិនិយោគ)។

២. ការរឹតត្បិតនានា ដែលបានអនុវត្ត ឬរក្សាទុកនៅក្រោមកថាខណ្ឌ ១ (ខ) ឬ (គ) ត្រូវ :

(ក) ឱ្យស្របគ្នាជាមួយនឹងមាត្រា នៃកិច្ចព្រមព្រៀងរូបិយវត្ថុអន្តរជាតិ (IMF)

(ខ) ជៀសវាងការខូចខាតដែលមិនចាំបាច់ ទៅលើអត្ថប្រយោជន៍ពាណិជ្ជកម្ម សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃសមាជិកណាមួយផ្សេងទៀត។

(គ) មិនឱ្យលើសពីសេចក្តីត្រូវការមាននៅក្នុងករណី ដែលបានបង្ហាញនៅក្នុងកថាខណ្ឌ ១

(ឃ) ដំណើរការបណ្តោះអាសន្ន និងជាជំហានៗ ដូចស្ថានភាពដែលកែរសំរួលក្នុងកថាខណ្ឌ ១

(ង) មូលដ្ឋានអនុវត្តមិនរើសអើង ដូចដែលមិនឱ្យមានសមាជិកណាមួយ មានភាពអនុគ្រោះតិចជាងសមាជិកណាមួយទៀត ឬមិនមែនជាសមាជិក

៣. អនុវត្តតាមច្បាប់ពាណិជ្ជកម្ម និងវិនិយោគ

(ក) ទទួលស្គាល់ថា គំនាបពិសេសលើតុល្យភាពចំណាយនៃសមាជិកមួយ នៅក្នុងដំណើរនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ឬបំលាស់ប្តូរសេដ្ឋកិច្ច អាចនឹងតំរូវឱ្យប្រើប្រាស់នូវការដាក់កំរិតនានា ដើម្បីទប់ទល់រក្សានូវកំរិតសេដ្ឋកិច្ចបំរុងមធ្យម សំរាប់អនុវត្តកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច ឬការបំលាស់ប្តូរសេដ្ឋកិច្ច ។

(ខ) នៅក្នុងការសំរេចលើទង្វើនៃការរិតត្បិត សមាជិកមួយអាចផ្តល់អាទិភាពឱ្យវិស័យសេដ្ឋកិច្ច ដែលជាវិស័យសំខាន់បំផុតដល់សេដ្ឋកិច្ច ឬកម្មវិធីអភិវឌ្ឍន៍របស់គេ។ ទោះបីយ៉ាងណាក៏ដោយ ការរិតត្បិតនានា នឹងមិនត្រូវបានអនុវត្ត ឬរក្សាទុកសំរាប់គោលបំណងរារាំងដល់វិស័យសំខាន់ណាមួយ ។

៤. ការរិតត្បិតនីមួយៗ បានអនុវត្ត ឬរក្សាទុកដោយសមាជិកមួយ តាមកថាខណ្ឌ ១ ឬការកែប្រែណាមួយ ត្រូវតែបញ្ជាក់ឱ្យបានឆាប់ដល់សមាជិកដទៃទៀត ។

៥. សមាជិកមួយ ដែលកំពុងអនុវត្ត ឬរក្សាទុកនូវការរិតត្បិតនានាក្រោមកថាខណ្ឌ ១ ត្រូវ :

(ក) ករណីវិនិយោគ ឆ្លើយតបទៅសមាជិកដទៃទៀតណាមួយ តាមការស្នើសុំពិគ្រោះយោបល់ទៅលើការរិតត្បិតដែលបានអនុវត្ត។ ប្រសិនបើកិច្ចពិគ្រោះយោបល់មិនធ្វើដូច្នេះ នោះវាប្រាសចាកពីកិច្ចព្រមព្រៀងនេះ ។

(ខ) ករណីពាណិជ្ជកម្មសេវាកម្ម ប្រសិនបើកិច្ចពិគ្រោះយោបល់ពាក់ពន្ធ័នឹងការអនុវត្តន៍លើការរិតត្បិតដែលមិនមាននៅក្នុង WTO នោះត្រូវតែមានកិច្ចពិគ្រោះយោបល់រួមជាបន្ទាន់ ជាមួយសមាជិកណាមួយ ប្រសិនបើមានសមាជិកមួយស្នើសុំ ។

## មាត្រា ៥
## សិទ្ធិសញ្ញា Waitangi

១. ចែងថា វិធានការនានាមិនប្រើប្រាស់មានន័យជាអាជ្ញាកណ្តាល ឬការរើអើងមិនសមរម្យ ដើម្បីប្រឆាំងបុគ្គលណាមួយ នៃសមាជិកដទៃទៀត ឬដាក់ការរិតត្បិតលើពាណិជ្ជកម្មទំនិញ ឬសេវាកម្ម គ្មានអ្វីនៅក្នុងកិច្ច ព្រមព្រៀងនេះ ត្រូវរារាំងដល់ការអនុវត្តនី ដូចដែលវិធានការរបស់ប្រទេសណូវែលហ្សេឡង់ ដែលគិតថា សំខាន់សំរាប់អនុវត្តផ្តល់ភាពអនុគ្រោះដល់ជនជាតិភាគតិចម៉ូរី (Maori) ក្នុងការអនុវត្តក្របខណ្ឌច្បាប់ នៃកិច្ចព្រមព្រៀងនេះ រួមទាំង ការបំពេញកាតព្វកិច្ចតាមសិទ្ធិសញ្ញា Waitangi ។

២. សមាជិកនីមួយៗ ឯកភាពថា ការបកស្រាយសិទ្ធិសញ្ញា Waitangi រួមមាន ដូចជាសិទ្ធិ និងកាតព្វកិច្ច ដែលមាននៅកិច្ចព្រមព្រៀងនេះ មិនមែនជាប្រធានបទនៃ ៥ ចែងសំរាប់ដោះស្រាយជំលោះនៃកិច្ចព្រមព្រៀងនេះទេ ។ កថាភាគ ១៧ (ការពិគ្រោះយោបល់ និងការដោះស្រាយជំលោះ) ត្រូវអនុវត្តតាមបែបផ្សេងពីមាត្រានេះ ។ តុលាការកាត់ក្តីមួយបានបង្កើតឡើងដោយអនុលោមតាមមាត្រា ១១ (ការបង្កើត និងការកោះប្រជុំ តុលាការកាត់ក្តីឡើងវិញ) នៃកថាភាគ ១៧ (កិច្ចពិគ្រោះយោបល់ និងការដោះស្រាយជំលោះ) អាចនឹងស្នើសុំ ដើម្បីគ្រាន់តែពិចារណា លើវិធានការណាមួយ (ដូចមានក្នុងកថាខណ្ឌ ១) ដែលវាផ្ទុយនឹងសិទ្ធិរបស់គេ នៃកិច្ចព្រមព្រៀងនេះ ។

# ជំពូក ១៦
# បទប្បញ្ញត្តិនៃការរៀបចំស្ថាប័ន

## មាត្រា ១
## គណៈកម្មាធិការចំរុះសម្រាប់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី

១. បណ្តាភាគី តាមរយៈនេះ បង្កើតគណៈកម្មាធិការចំរុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (គណៈកម្មាធិការចំរុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី) រួមមានតំណាងពីបណ្តាភាគី ។

២. មុខងាររបស់គណៈកម្មាធិការចំរុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ត្រូវមាន :

(ក) រំលឹកឡើងវិញការអនុវត្ត និង ការប្រតិបត្តិនៃកិច្ចព្រមព្រៀងនេះ

(ខ) ពិចារណា និងផ្តល់អនុសាសន៍ទៅបណ្តាភាគីនូវការកែប្រែទៅនឹងកិច្ចព្រមព្រៀងនេះ

(គ) ណែនាំ និង សម្របសម្រួលការងារនៃបណ្តាស្ថាប័ន ដែលបានបង្កើតបន្ថែម អនុលោមទៅតាមកិច្ចព្រមព្រៀងនេះ

(ឃ) ណែនាំ ទីណាដែលសមរម្យ សម្រេច និង ផ្តល់អនុសាសន៍នៃបណ្តាស្ថាប័ន ដែលបានបង្កើតបន្ថែម អនុលោមទៅតាមកិច្ចព្រមព្រៀងនេះ

(ង) ពិចារណាបញ្ហាដទៃណាមួយដែលអាចប៉ះពាល់ទៅនឹងការប្រតិបត្តិកិច្ចព្រមព្រៀងនេះ ឬ ផ្ទុកទៅលើគណៈកម្មាធិការចំរុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដោយបណ្តាភាគី. និង

(ច) បំពេញការងារនៅរាល់មុខងារដទៃណាមួយ ដែលបណ្តាភាគីអាចព្រមព្រៀង ។

៣. ក្នុងការបំពេញមុងងាររបស់វា គណៈកម្មាធិការចំរុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាចបង្កើតស្ថាប័នជំនួយបន្ថែម រួមទាំងក្រុមការងារ Ad hoc និង ចាត់តាំងពួកគេទៅតាមការងារស្តីពីបញ្ហាដោយឡែក ឬផ្តល់ការទទួលខុសត្រូវទៅស្ថាប័នជំនួយដែលបានបង្កើតអនុលោមទៅតាមកិច្ចព្រមព្រៀងនេះ រួមមាន :

(ក) គណៈកម្មាធិការទំនិញដែលបានបង្កើតអនុលោមទៅតាមមាត្រា ១១ (គណៈកម្មាធិការស្តីពីពាណិជ្ជកម្មទំនិញ) នៃជំពូក ២ (ពាណិជ្ជកម្មទំនិញ) ។

(i) អនុគណៈកម្មាធិការវិធានដើមកំណើត ដែលបានបង្កើតអនុលោមទៅតាមមាត្រា ១៨ (អនុគណៈកម្មាធិការស្តីពីវិធានដើមកំណើត) នៃជំពូក ៣ (វិធានដើមកំណើត) ។

(ii) អនុគណៈកម្មាធិការអនាម័យ និង ភូតគាមអនាម័យដែលបានបង្កើតឡើងអនុលោមទៅតាមមាត្រា ១០ (បណ្តាកិច្ចប្រជុំក្នុងចំណោមបណ្តាភាគីស្តីពីបញ្ហាអនាម័យ និង ភូតគាមអនាម័យ) នៃជំពូក ៥ (វិធានការអនាម័យ និង ភូតគាមអនាម័យ) និង

(iii) អនុគណៈកម្មាធិការស្តង់ដារ បទបញ្ញាបច្ចេកទេស និង ការវាយតម្លៃអនុលោមភាពអនុលោមទៅតាមមាត្រា ១៣ (អនុគណៈកម្មាធិការស្តង់ដារ បទបញ្ញាបច្ចេកទេស និងនីតិវិធីអនុលោមភាព) នៃជំពូក ៦ (គណៈកម្មាធិការស្តង់ដារ បទបញ្ញាបច្ចេកទេស និងការវាយតម្លៃអនុលោមភាព) ។

(ខ) គណៈកម្មាធិការសេវាកម្ម ដែលបានបង្កើតអនុលោមទៅតាមមាត្រា ២៤ (គណៈកម្មាធិការស្តីពីពាណិជ្ជកម្មសេវា) នៃជំពូក ៨ (ពាណិជ្ជកម្មសេវាកម្ម) ។

(គ) គណៈកម្មាធិការវិនិយោគ ដែលបានបង្កើតអនុលោមទៅតាមមាត្រា ១៧ (គណៈកម្មាធិការស្តីពីវិនិយោគ) នៃជំពូក ១១ (វិនិយោគ), និង

(ឃ) គណៈកម្មាធិការកម្មសិទ្ធិបញ្ញា ដែលបានបង្កើតអនុលោមទៅតាមមាត្រា ១២ (គណៈកម្មាធិការស្តីពីកម្មសិទ្ធិបញ្ញា) នៃជំពូក ១៣ (កម្មសិទ្ធិបញ្ញា) ។

៤. គណៈកម្មាធិការចំរុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ត្រូវបង្កើតវិធាន និងនីតិវិធីរបស់ខ្លួននៅក្នុងកិច្ចប្រជុំលើកទីមួយរបស់ខ្លួន ។

៥. លើកលែងតែបណ្តាភាគីព្រមព្រៀងផ្សេងពីនេះ គណៈកម្មាធិការចំរុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រៀបចំប្រជុំលើកទីមួយ របស់ខ្លួនក្នុងកំឡុងមួយឆ្នាំបន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ។ បណ្តាកិច្ចប្រជុំបន្ទាប់ទៀត ត្រូវតែរៀបចំទៅតាមទម្លាប់ដូចដែលបណ្តាភាគីអាចកំណត់ទៅវិញទៅមក និងដូចដែលចាំបាច់ទៅតាមមុខងាររបស់វាក្រោមកិច្ចព្រមព្រៀងនេះ ។ គណៈកម្មាធិការចំរុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីត្រូវរៀបចំប្រជុំឆ្លាស់គ្នានៅក្នុងប្រទេសសមាជិកអាស៊ាន និង អូស្ត្រាលី និងណូវែលហ្សេឡង់ លើកលែងតែបណ្តាភាគីព្រមព្រៀងផ្សេងពីនេះ ។ កិច្ចប្រជុំពិសេសនៃគណៈកម្មាធិការចំរុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាចរៀបចំប្រជុំទៅតាមការព្រមព្រៀង ដោយបណ្តាភាគី ក្នុងកំឡុង ៣០ ថ្ងៃ បន្ទាប់ពីការស្នើសុំដោយភាគីមួយ ។

៦. គណៈកម្មាធិការចំរុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីត្រូវ រាយការណ៍ជាប្រចាំទៅកិច្ចប្រជុំពិគ្រោះរបស់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងរដ្ឋមន្ត្រីពាណិជ្ជកម្មអូស្ត្រាលី និង រដ្ឋមន្ត្រីពាណិជ្ជកម្មណូវែលហ្សេឡង់ តាមរយៈកិច្ចប្រជុំ ឧត្តមមន្ត្រីសេដ្ឋកិច្ច ។

## មាត្រា ២

## ទំនាក់ទំនង

បណ្ដាភាគីនីមួយៗត្រូវ ចាត់តាំងចំណុចទំនាក់ទំនង ដើម្បីសម្របសម្រួលទំនាក់ទំនងក្នុងចំណោមបណ្ដាភាគីចំពោះបញ្ហាដែលពាក់ព័ន្ធទៅកិច្ចព្រមព្រៀងនេះ ។ រាល់ទំនាក់ទំនងផ្លូវការ ត្រូវតែធ្វើឡើងជាភាសាអង់គ្លេស ។

# ជំពូក ១៧
# ការពិគ្រោះ និងការដោះស្រាយវិវាទ

## ផ្នែក ក
## បទប្បញ្ញត្តិផ្តើម

### មាត្រា ១
### គោលបំណង

គោលបំណងនៃជំពូកនេះគឺ ផ្តល់ប្រសិទ្ធិភាព សមត្ថភាព និងតំលាភាពនៃដំណើរការសំរាប់ការពិគ្រោះ និងដោះស្រាយវិវាទដែលកើតឡើងក្រោមកិច្ចព្រមព្រៀងនេះ ។

### មាត្រា ២
### និយមន័យ

សម្រាប់គោលបំណងនៃជំពូកនេះ និយមន័យខាងក្រោមត្រូវអនុវត្ត លើកលែងតែអត្ថបទតម្រូវផ្សេងពីនេះ :

(ក) **ភាគីប្តឹងតវ៉ា** មានន័យថា ភាគី ឬបណ្តាភាគីណាមួយ ដែលស្នើសុំការពិគ្រោះយោបល់ក្រោមមាត្រា ៦ (ការពិគ្រោះយោបល់)

(ខ) **វិវាទកើតឡើងក្រោមកិច្ចព្រមព្រៀងនេះ** មានន័យថា ការប្តឹងតវ៉ាដែលធ្វើដោយភាគីមួយពាក់ព័ន្ធទៅនឹងវិធានការប៉ះពាល់ដល់ការប្រតិបត្តិ ការអនុវត្តន៍ ឬបែបបទផ្សេងៗនៃកិច្ចព្រមព្រៀងនេះ ដោយហេតុនោះ ផលប្រយោជន៍ណាមួយកើតឡើងទៅលើភាគីប្តឹងតវ៉ាដោយផ្ទាល់ ឬ ដោយប្រយោលក្រោមកិច្ចព្រមព្រៀងនេះ ត្រូវបានចាត់ជាមោឃៈភាព ឬបង្អាក់ ឬមិនបានសម្រេចទៅនឹងកម្មវត្ថុនៃកិច្ចព្រមព្រៀងនេះ ដែលជាលទ្ធផលពីភាគីត្រូវឆ្លើយតបខកខានមិនបានបំពេញកាតព្វកិច្ច[១] នៅក្រោមកិច្ចព្រមព្រៀងនេះ[២] ។

(គ) **បណ្តាភាគីនៃវិវាទ** មានន័យថា ភាគីប្តឹងតវ៉ា និង ភាគីត្រូវឆ្លើយតប ។

---

[១] ខកខានមិនបានបំពេញកាតព្វកិច្ចរួមមានទាំងការអនុវត្តដោយភាគី ត្រូវឆ្លើយតបនូវរាល់វិធានការណាមួយ ដែលខ្ទាស់ទៅនឹងបណ្តាកាតព្វកិច្ចនៅក្រោមកិច្ចព្រមព្រៀងនេះ ។

[២] ការប្តឹងតវ៉ាដែលមិនប្រព្រឹត្តិល្មើសមិនអនុញ្ញាតក្រោមកិច្ចព្រមព្រៀងនេះ ។

(ឃ) **ភាគីត្រូវឆ្លើយតប** មានន័យថា ភាគីណាមួយដែលការស្នើសុំសំរាប់ពិគ្រោះយោបល់បានធ្វើឡើងក្រោមមាត្រា ៦ (ការពិគ្រោះយោបល់), និង

(ង) **ភាគីទីបី** មានន័យថា ភាគីដែលបានជូនពត៌មានពីផលប្រយោជន៍ពាណិជ្ជកម្មជាដុំកំភួន ឬ ផលប្រយោជន៍ដុំកំភួននៅក្នុងបញ្ហាយោងតាមមាត្រា ៦.៧ ( ការពិគ្រោះ) ឬ មានត្រា ១០.១ (បណ្តាភាគីទីបី) ។

## មាត្រា ៣
## វិសាលភាព និងការគ្រប់ដណ្តប់

១. លើកលែងតែមានការចែងផ្សេងក្នុងកិច្ចព្រមព្រៀងនេះ ជំពូកនេះត្រូវអនុវត្តដើម្បីចៀសវាង ឬ ដោះស្រាយវិវាទកើតឡើងក្រោមកិច្ចព្រមព្រៀងនេះ។ ជំពូកនេះមិនត្រូវបានអនុវត្ត ចំពោះការដោះស្រាយវិវាទកើតឡើងក្រោមជំពូក ៥ (វិធានការអនាម័យ និង ភូតគាមអនាម័យ) ជំពូក ១០ (ពាណិជ្ជកម្មអេឡិចត្រូនិច) ជំពូក ១២ (សហប្រត្តិបត្តិការសេដ្ឋកិច្ច) និង ជំពូក ១៤ (ការប្រកួតប្រជែង) ។

២. ជំពូកនេះត្រូវអនុវត្តចំពោះប្រធានបទនៃបទប្បញ្ញត្តិសំខាន់ និងបន្ថែមស្តីពីការដោះស្រាយវិវាទដែលមាននៅក្នុងបណ្តាជំពូកដទៃទៀតនៃកិច្ចព្រមព្រៀងនេះ។

៣. ប្រធានបទនៃមាត្រា ៥ (ការជ្រើសរើសវេទិកា) ជំពូកនេះគឺដោយមិនខូចខាតទៅនឹងសិទ្ធិរបស់ភាគីមួយក្នុងការឧបាស្រ័យទៅនឹងនីតិវិធីដោះស្រាយវិវាទ មានក្រោមកិច្ចព្រមព្រៀងដទៃទៀតដែលជាភាគីមួយ។

៤. ជំពូកនេះ អាចអនុវត្តដោយគោរពទៅតាមវិធានការប៉ះពាល់បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ដែលប្រកាន់យកដោយរដ្ឋាភិបាល ឬអាជ្ញាធរកណ្តាល តំបន់ ឬក្នុងស្រុកនៅក្នុងដែនដីរបស់ភាគីមួយ។

## មាត្រា ៤
## បទប្បញ្ញត្តិទូទៅ

១. កិច្ចព្រមព្រៀងនេះ ត្រូវបកស្រាយអនុលោមទៅតាមបណ្តាវិធាន ដែលជាទម្លាប់នៃសិទ្ធិសញ្ញាបកស្រាយនៃអន្តរជាតិសាធារណៈ។

២. រាល់ការជូនពត៌មាន ការស្នើសុំ និងការឆ្លើយតបត្រូវធ្វើដោយអនុលោមទៅតាមជំពូកនេះ ត្រូវជាលាយលក្ខណ៍អក្សរ។

៣. បណ្តាភាគីនៃវិវាទ ត្រូវបានជំរុញនៅគ្រប់ដំណាក់កាលនៃវិវាទ ធ្វើការខិតខំប្រឹងប្រែង ដើម្បីឈានទៅរកដំណោះស្រាយវិវាទព្រមព្រៀងទៅវិញទៅមក។ ទីណាដែលដំណោះស្រាយវិវាទព្រមព្រៀងទៅវិញទៅមកបានឈានដល់ពាក្យស័ព្ទ និង លក្ខខណ្ឌនៃការព្រមព្រៀងត្រូវតែជូនពត៌មានទៅបណ្តាភាគីដទៃទៀត។

៤. លើកលែងតែមានចែងដោយឡែក ពេលវេលាដែលមានផ្តល់នៅក្នុងជំពូកនេះអាចកែប្រែដោយ មានការព្រមព្រៀងទៅវិញទៅមកដោយបណ្តាភាគីនៃវិវាទ ដោយផ្តល់ថាការកែប្រែណាមួយមិនត្រូវខូចខាតសិទ្ធិរបស់ភាគីទីបី អនុលោមទៅតាមមាត្រា ១០ (បណ្តាភាគីទីបី)។

## មាត្រា ៥
## ការជ្រើសរើសវេទិកា

១. ទីណាដែលវិវាទពាក់ព័ន្ធទៅនឹងបញ្ហាណាមួយកើតឡើងក្រោមកិច្ចព្រមព្រៀងនេះ និងក្រោមកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀតដែលបណ្តាភាគីនៃវិវាទជាភាគី ភាគីប្តឹងតវ៉ាអាចជ្រើសរើសវេទិកា ដើម្បីថ្លែងពីបញ្ហា និង វេទិកានោះត្រូវប្រើប្រាស់សំរាប់ជាវេទិកាដទៃទៅនឹងបញ្ហានោះ។

២. សំរាប់គោលបំណងនៃមាត្រានេះ ភាគីប្តឹងតវ៉ាអាចចាត់ទុកថា ជាអ្នកជ្រើសរើសវេទិកា ដើម្បីដោះស្រាយវិវាទពេលដែលត្រូវបានស្នើឱ្យបង្កើតសាលាក្តី អនុលោមទៅតាមមាត្រា ៨ (សំណើដើម្បីបង្កើតសាលាក្តី) ឬ សំណើក្នុងការបង្កើតនៃ ឬបញ្ជូនបញ្ហាទៅ ដូចគ្នាទៅនឹងគណៈវិនិច្ឆ័យដោះស្រាយវិវាទ នៅក្រោមកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀត។

៣. មាត្រានេះមិនអាចអនុវត្តបាន ទីណាដែលបណ្តាភាគីនៃវិវាទបានឯកភាពជាលាយលក្ខណ៍អក្សរថា មាត្រានេះមិនត្រូវអនុវត្តចំពោះវិវាទដោយឡែក។

# ផ្នែក ខ
# បទប្បញ្ញត្តិពិគ្រោះយោបល់

## មាត្រា ៦
## ការពិគ្រោះយោបល់

១. ភាគីណាមួយអាចស្នើសុំការពិគ្រោះយោបល់ជាមួយភាគីដទៃណាមួយទៀត ដោយគោរពតាមទៅនឹងវិវាទណាមួយដែលកើតឡើងក្រោមកិច្ចព្រមព្រៀងនេះ។ ភាគីត្រូវឆ្លើយតបត្រូវពិចារណាទៅនឹងការស្នើសុំពិគ្រោះយោបល់ ដែលធ្វើដោយភាគីប្តឹងតវ៉ា និងត្រូវផ្តល់ឱកាសសមរម្យសំរាប់ការពិគ្រោះយោបល់នោះ។

២. ការស្នើសុំពិគ្រោះយោបល់ណាមួយ ត្រូវផ្តល់មូលហេតុក្នុងការស្នើសុំ រួមបញ្ចូលទាំងការកំណត់វិធានការនៃបញ្ហា និងប្រាប់ពីមូលដ្ឋានច្បាប់នៃការប្តឹងតវ៉ា។

៣. ទាំងច្បាប់ចំលង ទាំងការស្នើសុំ ត្រូវផ្តល់តំណាលគ្នាទៅបណ្តាភាគី។ ភាគីត្រូវឆ្លើយតប ត្រូវជូនដំណឹងពីការទទួលការស្នើសុំជាបន្ទាន់តាមមធ្យោបាយជូនពតិមានទៅបណ្តាភាគី ដោយប្រាប់ពីកាលបរិច្ឆេទនៃការទទួលការស្នើសុំ។

៤. ភាគីត្រូវឆ្លើយតបត្រូវ លើកលែងតែមានការព្រមព្រៀងទៅវិញទៅមក ឆ្លើយទៅនឹងការស្នើសុំក្នុងរយៈពេលប្រាំពីរថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួល នឹងត្រូវចូលពិគ្រោះក្នុងរយៈពេលមិនលើសពី :

(ក) ដប់ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការទទួលការស្នើសុំ ក្នុងករណីបន្ទាន់ រួមទាំងករណីដែលពាក់ព័ន្ធដល់ទំនិញឆាប់ស្អុយរលួយ ឬ

(ខ) សាមសិបថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការទទួលការស្នើសុំទៅនឹងរាល់បញ្ហាដទៃទៀត។

៥. ប្រសិនបើភាគីត្រូវឆ្លើយតប មិនបានចូលពិគ្រោះក្នុងរយៈពេលដែលមានបញ្ជាក់នៅក្នុងកថាខ័ណ្ឌ ៤ ឬ រយៈពេលដែលព្រមព្រៀងទៅវិញទៅមក ភាគីត្រូវឆ្លើយតបអាចដំណើរការផ្ទាល់ស្នើសុំបង្កើតសាលាក្តី អនុលោមទៅតាមមាត្រា ៨ (ការស្នើសុំសំរាប់ការបង្កើតសាលាក្តី)។

៦. បណ្តាភាគីនៃវិវាទ ត្រូវខិតខំប្រឹងប្រែងដើម្បីឈានទៅរកដំណោះស្រាយដែលពេញចិត្តទៅវិញទៅមកតាមរយៈការពិគ្រោះ។ ក្នុងន័យនេះបណ្តាភាគីនៃវិវាទត្រូវ :

(ក) ផ្តល់ពតិមានគ្រប់គ្រាន់ដែលអាចពិនិត្យបញ្ហាបានពេញលេញ រួមបញ្ចូលទាំងវិធានការនៃបញ្ហា ដែលប៉ះពាល់ដល់ការអនុវត្ត ឬ បែបបទនៃកិច្ចព្រមព្រៀងនេះ។

(ខ) ប្រព្រឹត្តិជាសម្ងាត់នៅរាល់ពតិមាន ឬ កម្មសិទ្ធិ ដែលបានផ្លាស់ប្តូរនៅក្នុងការពិគ្រោះ លើមូលដ្ឋានដូចគ្នា ដែលភាគីផ្តល់ពតិមាន និង

(គ) បើអាចទៅរួច ធ្វើឱ្យអាចរកបានចំពោះការពិគ្រោះនូវបុគ្គលភ្នាក់ងាររដ្ឋាភិបាល ឬស្ថាប័នច្បាប់ ដែលទទួលបន្ទុកចំពោះ និង/ឬ អ្នកជំនាញទៅនឹងបញ្ហាក្រោមការពិគ្រោះ។

៧. នៅពេលដែលភាគីដទៃមួយ មិនមែនភាគីនៃវិវាទ ពិចារណាថា នោះមានផលប្រយោជន៍ពាណិជ្ជកម្មជុំកំភួននៅក្នុងការពិគ្រោះ ភាគីនោះអាចជូនពត៌មានទៅបណ្តាភាគីនៃវិវាទក្នុងរយៈពេលប្រាំពីរថ្ងៃ បន្ទាប់ពីសេចក្តីជូនដំណឹងនៃការស្នើសុំពិគ្រោះ តាមការសម្រេចរបស់គេក្នុងការចូលរួមពិគ្រោះ។ សេចក្តីជូនដំណឹងនោះ ត្រូវផ្តល់ទៅបណ្តាភាគីក្នុងពេលតែមួយ។ ភាគីនោះអាចចូលរួមក្នុងការពិគ្រោះ ប្រសិនបើ បណ្តាភាគីនៃវិវាទព្រមព្រៀង។

## មាត្រា ៧
## ការសម្រុះសម្រួល ការស្រុះស្រួល និងសន្ធានកម្ម

១. បណ្តាភាគីនៃវិវាទអាច គ្រប់ពេលវេលាព្រមព្រៀងទៅនឹងការសម្រុះសម្រួល ការស្រុះស្រួល និងសន្ធានកម្ម។ នីតិវិធីសម្រុះសម្រួល ស្រុះស្រួល និងសន្ធានកម្ម អាចចាប់ផ្តើមគ្រប់ពេលវេលា និងបញ្ចប់គ្រប់ពេលវេលា។

២. ប្រសិនបើភាគីនៃវិវាទបានព្រមព្រៀង នីតិវិធីសម្រុះសម្រួល ស្រុះស្រួល និងសន្ធានកម្ម អាចបន្តនៅពេលដែលបញ្ហាកំពុងតែពិនិត្យដោយសាលាក្តីដែលបានបង្កើត ឬ ចូលប្រជុំវិញក្រោមជំពូកនេះ។

៣. ទម្រង់ការនៃការសម្រុះសម្រួល ការស្រុះស្រួល និងសន្ធានកម្ម និងដោយឡែក គោលជំហរដែលប្រកាន់យកដោយបណ្តាភាគីនៃវិវាទក្នុងរយៈពេលទម្រង់ការត្រូវរក្សាទុកជាសម្ងាត់ និងមិនប៉ះពាល់ដល់សិទ្ធិនៃភាគីវិវាទណាមួយនៅក្នុងទម្រង់ការបន្ត ឬ ទម្រង់ការដទៃទៀត។

## ផ្នែក គ
## បទប្បញ្ញត្តិការវិនិច្ឆ័យ

## មាត្រា ៨
## ការស្នើសុំសំរាប់បង្កើតសាលាក្តី

១. ភាគីប្តឹងតវ៉ាអាចស្នើសុំបង្កើតសាលាក្តី ដើម្បីពិចារណាទៅលើបញ្ហាប្រសិនបើ :

(ក) ភាគីប្តឹងតវ៉ាមិនចូលរួមក្នុងការពិគ្រោះ អនុលោមទៅតាមមាត្រា ៦.៤ (ការពិគ្រោះ) ឬ

(ខ) ប្រសិនបើការពិគ្រោះខកខានក្នុងការដោះស្រាយវិវាទក្នុងកំឡុង :

(i) ២០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការស្នើសុំពិគ្រោះក្នុងករណីបន្ទាន់ រួមទាំងករណី ដែលពាក់ព័ន្ធដល់ទំនិញឆាប់ស្អុយរលួយ ឬ

(ii) ៦០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលការស្នើសុំពិគ្រោះ ដែលពាក់ព័ន្ធទៅនឹងបញ្ហាដទៃ ឬ

(iii) រយៈពេលទាំងនោះដូចដែលបណ្តាភាគីនៃវិវាទអាចព្រមព្រៀង ។

២. ការស្នើសុំដែលបានធ្វើអនុលោមទៅតាមកថាខណ្ឌ ១ ត្រូវបញ្ជាក់វិធានការដោយឡែកទៅ នឹងបញ្ហា និង ផ្តល់លំអិតពីកត្តាជាក់ស្តែង និងមូលដ្ឋានច្បាប់នៃការប្តឹងតវ៉ា (រួមបញ្ចូលទាំងបណ្តាបទប្បញ្ញត្តិ នៃកិច្ចព្រមព្រៀងនេះ ដើម្បីបង្ហាញទៅសាលាក្តី) គ្រប់គ្រាន់ក្នុងការបង្ហាញច្បាស់លាស់ពីបញ្ហា ។

៣. ច្បាប់ចំលងទាំងអស់នៃការស្នើសុំត្រូវផ្តល់តំណាលគ្នាទៅបណ្តាភាគី ។ ភាគីត្រូវឆ្លើយតប ត្រូវជូនពត៌មាន បន្ទាប់ពីបានទទួលការស្នើសុំតាមការជូនដំណឹងទៅភាគីទាំងអស់ ដើម្បីបញ្ជាក់ពីកាលបរិច្ឆេទនៃការទទួលការស្នើសុំ ។

៤. ទីណាដែលការស្នើសុំបានធ្វើឡើងអនុលោមទៅតាមកថាខណ្ឌ ១ សាលាក្តីត្រូវតែបង្កើត អនុលោមទៅតាមមាត្រា ១១ (បង្កើត និងចូលប្រជុំវិញរបស់សាលាក្តី) ។

## មាត្រា ៩
## ឧម្រង់សម្រាប់អ្នកប្តឹងតវ៉ាច្រើន

១. នៅពេលដែលមានភាគីលើសពីមួយ ស្នើសុំបង្កើតសាលាក្តីដែលពាក់ព័ន្ធទៅនឹងបញ្ហាដូចគ្នា សាលាក្តីតែមួយអាចបង្កើត ដើម្បីពិនិត្យទៅលើបណ្តឹងតវ៉ាទាំងនោះ ប្រសិនបើបណ្តាភាគីនៃវិវាទព្រមព្រៀង ។ បណ្តាភាគីនៃវិវាទអាចស្វែងរកការបង្កើតសាលាក្តីមួយពេលដែលអាចធ្វើទៅបាន ។

២. សាលាក្តីតែមួយ ត្រូវរៀបចំការពិនិត្យ និងបង្ហាញពីការស្វែងរកឃើញ ដែលទាំងនោះសិទ្ធិរបស់បណ្តាភាគីនៃវិវាទ ត្រូវបានពេញចិត្ត ការដែលមានសាលាក្តីដោយឡែកពិនិត្យរាល់ការប្តឹងតវ៉ា ជាវិធីសាស្ត្រដែលមិនអន់ខ្សោយ ។

៣. ប្រសិនបើសាលាក្តីច្រើនជាងមួយបានបង្កើតឡើងដើម្បីពិនិត្យទៅលើការប្តឹងតវ៉ាដែលពាក់ព័ន្ធ ទៅនឹងបញ្ហាដូចបណ្តាភាគីនៃវិវាទអាចនឹងត្រូវធ្វើឱ្យប្រាកដថា មនុស្សដែលជាអាជ្ញាកណ្តាលដូចគ្នានៅគ្រប់សាលាក្តី ។ បណ្តាសាលាក្តីត្រូវពិគ្រោះឱ្យប្រាកដថា តាមលទ្ធភាពដែលអាចធ្វើទៅបាន កម្មវិធីនៃដំណើរការសាលាក្តីត្រូវដូចគ្នា ។

## មាត្រា ១០
## ភាគីទីបី

១. ភាគីណាមួយដែលមានចំណាប់អារម្មណ៍ជាដុំកំភួន ទៅនឹងបញ្ហាមុនពេលសាលាក្តីអាចជូនពត៌មានទៅបណ្តាភាគីនៃវិវាទនៃចំណាប់អារម្មណ៍នេះ មិនឱ្យតិចជាងដប់ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួល ដោយភាគីត្រូវឆ្លើយតបទៅនឹងការស្នើសុំចំពោះ Compliance Review Tribunal អនុលោមទៅតាមមាត្រា ១៦ (Compliance Review) ។ ការជូនពត៌មាននោះត្រូវតែផ្តល់ដំណាលគ្នាទៅគ្រប់បណ្តាភាគី ។ ភាគីណាមួយជូនដំណឹងពីការចាប់អារម្មណ៍ជាដំកំភួនត្រូវមានសិទ្ធិ និងកាតព្វកិច្ចនៃភាគីទីបី ។

២. ភាគីទីបីត្រូវទទួល ការផ្តល់ដោយបណ្តាភាគីនៃវិវាទ កិច្ចប្រជុំជាដុំកំភួនដំបូងរបស់សាលាក្តី ជាមួយនឹងបណ្តាភាគីនៃវិវាទ ។

៣. ភាគីទីបីត្រូវមានឱកាសក្នុងការសរសេរជាលាយលក្ខណ៍អក្សរយ៉ាងតិចមួយ ផ្តល់ទៅសាលាក្តី និងត្រូវមានឱកាសក្នុងសាវនាការសាលាក្តី នៅក្នុងកិច្ចប្រជុំជាដុំកំភួនដំបូងជាមួយនឹងបណ្តាភាគីនៃវិវាទ ។

៤. បណ្តាភាគីនៃវិវាទអាចឯកភាពក្នុងការផ្តល់សិទ្ធិបន្ថែម ទៅបណ្តាភាគីទីបីពាក់ព័ន្ធទៅនឹងការចូលរួមទម្រង់ការសាលាក្តី ។ ក្នុងការផ្តល់សិទ្ធិបន្ថែម បណ្តាភាគីនៃវិវាទអាចដាក់លក្ខខណ្ឌខ្លះ ។ លើកលែងតែមានការព្រមព្រៀងដោយបណ្តាភាគីនៃវិវាទ សាលាក្តីមិនត្រូវផ្តល់សិទ្ធិបន្ថែមទៅបណ្តាភាគីទីបីពាក់ព័ន្ធ ទៅនឹងការចូលរួមក្នុងទម្រង់ការសាលាក្តី ។

៥. ប្រសិនបើភាគីទីបីពិចារណាថា វិធានការដែលមានជាប្រធានបទនៃទម្រង់ការសាលាក្តី ប៉ះពាល់ ឬខូចខាតផលប្រយោជន៍នៅក្រោមកិច្ចព្រមព្រៀងនេះ ភាគីអាចឧបាស្រ័យទៅនីតិវិធីដោះស្រាយវិវាទក្រោមកិច្ចព្រមព្រៀងនេះ ។

## មាត្រា ១១
## បង្កើត និងប្រជុំឡើងវិញសាលាក្តី

១. សាលាក្តីដែលបានស្នើសុំ អនុលោមទៅតាមមាត្រា ៨ ( ការស្នើសុំសំរាប់បង្កើតសាលាក្តី) ត្រូវបង្កើតដោយយោងទៅតាមមាត្រានេះ ។

២. លើកលែងតែបណ្តាភាគីនៃវិវាទព្រមព្រៀងផ្សេង សាលាក្តីត្រូវរួមមានអាជ្ញាកណ្តាលបីរូប ។ រាល់ការតែងតាំង និងការជ្រើសរើសអាជ្ញាកណ្តាលក្រោមមាត្រានេះ ត្រូវតែប្រតិបត្តិតាមពេញលេញជាមួយនឹងតម្រូវការក្នុងកថាខណ្ឌ ៩ និង ១០ ។

៣. ក្នុងកំឡុងប្រាំថ្ងៃនៃកាលបរិច្ឆេទទទួលការស្នើសុំក្រោមមាត្រា ៨ (ការស្នើសុំសំរាប់បង្កើតសាលាក្តី) បណ្តាភាគីនៃវិវាទត្រូវចូលរួមពិគ្រោះក្នុងគំនិតឈានទៅរកការព្រមព្រៀងលើទម្រង់ការ សំរាប់សមាសធាតុសាលាក្តី ដោយយកចិត្តទុកដាក់ទៅលើកត្តាជាក់ស្តែង បច្ចេកទេស និងច្បាប់នៃវិវាទ។ បណ្តាភាគីនៃវិវាទអាចព្រមព្រៀងក្នុងការប្រើប្រាស់ទម្រង់ការណាមួយ ដែលមានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ របស់ជំពូកនេះស្តីពីទម្រង់ការសម្រាប់សមាសធាតុសាលាក្តី។ ទម្រង់ការណាមួយសំរាប់សមាសធាតុសាលាក្តី ដែលបានព្រមព្រៀងក្រោមកថាខណ្ឌនេះ ត្រូវប្រើប្រាស់ សម្រាប់សមាសធាតុសាលាក្តី និងត្រូវប្រើប្រាស់ សម្រាប់គោលបំណងនៃកថាខណ្ឌ ១២ និង ១៣ ។

៤. ប្រសិនបើបណ្តាភាគីវិវាទមិនមានលទ្ធភាព ក្នុងការឈានទៅរកការព្រមព្រៀងលើទម្រង់ការសម្រាប់សមាសធាតុសាលាក្តីក្នុងកំឡុង ១៥ ថ្ងៃ នៃកាលបរិច្ឆេទទទួលការស្នើសុំដែលបានផ្តល់នៅក្នុងកថាខណ្ឌ ៣ ភាគីណាមួយនៃវិវាទអាចគ្រប់ពេលវេលាបន្ទាប់ពីនោះ ជូនពត៌មានទៅបណ្តាភាគីនៃវិវាទថា មានបំណងចង់ប្រើទម្រង់ការដែលមានចែងនៅក្នុងកថាខណ្ឌ ៥ ទៅ ៧ ។ នៅពេលដែលការជូនពត៌មាន នោះត្រូវបានធ្វើឡើង សាលាក្តីត្រូវមានសមាសធាតុអនុលោមទៅតាមកថាខណ្ឌ ៥ ទៅ ៧ ។

៥. ភាគីប្តឹងតវ៉ា ឬ បណ្តាភាគីត្រូវតែងតាំងអាជ្ញាកណ្តាលមួយរូបក្នុងកំឡុងដប់ថ្ងៃនៃការបរិច្ឆេទ ទទួលសេចក្តីជូនពត៌ដែលមានចែងទៅក្នុងកថាខណ្ឌ ៤ ។ ភាគីត្រូវឆ្លើយតប ត្រូវតែងតាំងអាជ្ញាកណ្តាល មួយរូបក្នុងកំឡុង ២០ ថ្ងៃ នៃកាលបរិច្ឆេទទទួលសេចក្តីជូនពត៌មានដែលមានចែងនៅក្នុងកថាខណ្ឌ ៤ ។

៦. ទៅតាមការចាត់តាំងអាជ្ញាកណ្តាលយោងតាមកថាខណ្ឌ ៥ បណ្តាភាគីនៃវិវាទត្រូវព្រមព្រៀង ទៅលើការចាត់តាំងអាជ្ញាកណ្តាលទីបី ដែលជាអ្នកបំរើជាប្រធានសាលាក្តី ។ ដើម្បីចូលរួមក្នុងការឈានទៅរកការព្រមព្រៀងនេះ បណ្តាភាគីនៃវិវាទនីមួយៗអាចផ្តល់ទៅបណ្តាភាគីវិវាទដទៃទៀតនូវបញ្ជីអ្នក ដែលត្រូវ ជ្រើសរើសបីរូបសម្រាប់ការតែងតាំងរបស់ប្រធានសាលាក្តី ។ ប្រសិនបើបណ្តាភាគីនៃវិវាទមិនទាន់ព្រមព្រៀងលើប្រធានសាលាក្តី ក្នុង

កំឡុង ១៥ ថ្ងៃ នៃការតែងតាំងអាជ្ញាកណ្តាលលើកទីពីរ អាជ្ញាកណ្តាល ដែលតែងតាំងទាំងពីររូបត្រូវជ្រើសរើស ដោយការព្រមព្រៀងរួមអាជ្ញាកណ្តាលទីបី ដែលជាប្រធានសាលាក្តី ។

៧. ប្រសិនបើអាជ្ញាកណ្តាលទាំងបីមិនទាន់ត្រូវបានចាត់តាំងក្នុងកំឡុង ៤៥ ថ្ងៃ នៃកាលបរិច្ឆេទទទួលសេចក្តីជូនពតិមាន យោងទៅតាមកថាខណ្ឌ ៤ ភាគីនៃវិវាទណាមួយអាចស្នើទៅអគ្គនាយកនៃអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីចាត់តាំងអ្នកដែលនៅសេសសល់ នៅក្នុងកំឡុង ១៥ ថ្ងៃខាងមុខ។ បញ្ជីអ្នកត្រូវបានជ្រើសរើស ណាមួយដែលផ្តល់ក្រោមកថាខណ្ឌ ៦ នឹងត្រូវផ្តល់ទៅអគ្គនាយកអង្គការពាណិជ្ជកម្មពិភពលោក និងអាចប្រើសម្រាប់តម្រូវការចាត់តាំង។

៨. កាលបរិច្ឆេទនៃការបង្កើតសាលាក្តីត្រូវតែជាកាលបរិច្ឆេទនៃការចាត់តាំងអាជ្ញាកណ្តាលចុងក្រោយ ។

៩. អាជ្ញាកណ្តាលទាំងអស់ត្រូវ :

(ក) មានជំនាញ ឬ បទពិសោធន៍ច្បាប់ពាណិជ្ជកម្មអន្តរជាតិ បញ្ហាផ្សេងដែលគ្របដណ្តប់ ដោយកិច្ចព្រមព្រៀងនេះ ឬ ការដោះស្រាយវិវាទផ្សេងៗដែលកើតឡើងពីបណ្តាកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិ

(ខ) ត្រូវបានជ្រើសរើសដោយម៉ត់ចត់ដោយផ្អែកលើ កម្មវត្ថុ ភាពទុកចិត្តបាន និង យុត្តិធម៌

(គ) ត្រូវឯករាជ្យ និងមិនត្រូវទាក់ទង ឬ ទទួលយកការណែនាំពីភាគីណាមួយនៃវិវាទ

(ឃ) មិនត្រូវប្រព្រឹត្តិទៅនឹងបញ្ហាទៅតាមសមត្ថភាពណាមួយ និង

(ង) បង្ហាញទៅ បណ្តាភាគីនៃវិវាទ ពតិមានដែលអាចកើតមានចម្ងល់ ទៅនឹងឯករាជ្យភាព ឬ ជាភាពមិនលំអៀង។

១០. លើកលែងតែភាគីនៃវិវាទព្រមព្រៀង អាជ្ញាកណ្តាលមិនត្រូវជាជនជាតិនៃភាគីមួយនៃវិវាទ។ បន្ថែមពីនោះ ប្រធានសាលាក្តីមិនត្រូវមានទីលំនៅក្នុងដែនដីរបស់ភាគីមួយនៃវិវាទ។

១១. អាជ្ញាកណ្តាលត្រូវតែបំរើទៅតាមសមត្ថភាពបុគ្គល និងមិនមែនជាតំណាងពីស្ថាប័នរដ្ឋ ព្រមទាំងមិនមែនជាតំណាងពីស្ថាប័នណាមួយ។ បណ្តាភាគីមិនត្រូវផ្តល់ការណែនាំ ទាំងមិនត្រូវមានឥទ្ធិពលទៅលើពួកគេ ដោយបុគ្គល ដែលពាក់ព័ន្ធទៅនឹងបញ្ហាមុនសាលាក្តី។

១២. ប្រសិនបើអាជ្ញាកណ្តាលចាត់តាំងក្រោមមាត្រានេះលាឈប់ ឬ មិនអាចមានលទ្ធភាពបន្ត អាជ្ញាកណ្តាលរង ត្រូវចាត់តាំងទៅតាមលំនាំដូច សម្រាប់ការចាត់តាំងអាជ្ញាកណ្តាលដើម និងមានអំណាច និងការងារទាំងអស់នៃអាជ្ញាកណ្តាលចាស់ ។ ការងាររបស់សាលាក្តីអាចពន្យារក្នុងដំណាក់កាលចាត់តាំង អាជ្ញាកណ្តាលរង ។

១៣. ទីណាដែលសាលាក្តីប្រជុំឡើញវិញក្រោមមាត្រា ១៦ (Compliance Review) ឬ មាត្រា ១៧ (ការទូទាត់សង និង ព្យួរសម្បទាន ឬ កាតព្វកិច្ចដទៃ) បើអាចទៅបាន សាលាក្តីប្រជុំឡើងវិញត្រូវមានអាជ្ញាកណ្តាលដូចអាជ្ញាកណ្តាលដើម ។ ទីណាដែលមិនអាចទៅបាន ការផ្លាស់ប្តូរអាជ្ញាកណ្តាល ត្រូវតែចាត់តាំងទៅតាមលំនាំដូចសំរាប់ការចាត់តាំងអាជ្ញាកណ្តាលដើម និងត្រូវមានអំណាច និងការងាររបស់អាជ្ញាកណ្តាលដើម ។

## មាត្រា ១២
## មុខងារសាលាក្តី

១. សាលាក្តីត្រូវធ្វើការប្រមាណគោលដៅនៃបញ្ហាមុន រួមមានទាំងទិសដៅប៉ាន់ប្រមាណដូចជា :

(ក) ការពិតរបស់ករណី

(ខ) ភាពអាចអនុវត្តបាននៃបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ដែលបានដកស្រង់ដោយបណ្តាភាគីនៃវិវាទ

(គ) ពិនិត្យមើលថាតើភាគីត្រូវឆ្លើយតបខកខានមិនបំពេញកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះ ។

២. សាលាក្តីត្រូវមានលក្ខខណ្ឌការងារ លើកលែងតែបណ្តាភាគីនៃវិវាទព្រមព្រៀងផ្សេងពីនេះក្នុងកំឡុង ២០ថ្ងៃ ចាប់ពីកាលបរិច្ឆេទនៃការបង្កើតសាលាក្តី :

"ពិនិត្យទៅតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃកិច្ចព្រមព្រៀងនេះ បញ្ហាដែលយោងទៅតាមការស្នើសុំបង្កើតសាលាក្តី ដែលបានធ្វើឡើងដោយអនុលោមទៅតាមមាត្រា ៨ (ការស្នើសុំសម្រាប់បង្កើតសាលាក្តី) និងត្រូវធ្វើការស្វែងរក និងប្រសិនបើអាចទៅបាន ធ្វើការសុំយោបល់ដែលមានផ្តល់នៅក្នុងកិច្ចព្រមព្រៀងនេះ ។"

សាលាក្តីត្រូវស្វែងរកឱ្យឃើញ ទៅតាមកិច្ចព្រមព្រៀងនេះ ។

៣. សាលាក្តីត្រូវធ្វើរបាយការណ៍ :

(ក) ផ្នែកពិពណ៌នាដោយសង្ខេបពីជម្លោះរបស់បណ្តាភាគីនៃវិវាទ និងបណ្តាភាគីទីបី

(ខ) ស្វែងរកការពិតនៃករណី និងភាពអាចអនុវត្តបានចំពោះបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ

(គ) ស្វែងរកមើលថា តើភាគីត្រូវឆ្លើយតបបានខកខានក្នុងការបំពេញកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះ និង

(ឃ) មូលហេតុនៃការរកឃើញនៅក្នុងកថាខណ្ឌរង (ខ) និង គ) ។

៤. ក្នុងការបន្ថែមទៅនឹងកថាខណ្ឌ ៣ អាចរួមបញ្ចូលទាំងរបាយការណ៍ និងការរកឃើញរបស់វា ជាមួយនឹងការចូលរួមជាមួយការស្នើរបស់ភាគីនៃវិវាទ។ សាលាក្តីអាចស្នើតាមវិធីសាស្ត្រដែលភាគីត្រូវឆ្លើយតបអាចអនុវត្តបាននៅការស្វែងរកឃើញ ។

៥. លើកលែងតែភាគីនៃវិវាទព្រមព្រៀងផ្សេងពីនេះ សាលាក្តីត្រូវផ្អែកទៅលើរបាយការណ៍របស់ខ្លួនដោះស្រាយលើបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ និងផ្តល់ និងជម្លោះរបស់បណ្តាភាគីនៃវិវាទ។ សាលាក្តីត្រូវធ្វើការរកឱ្យឃើញ និងស្នើយោបល់ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះតែប៉ុណ្ណោះ ។

៦. បណ្តាភាគីទីបីដែលចាប់អារម្មណ៍ និងបណ្តាភាគីដទៃទាំងនោះត្រូវយកចិត្តទុកដាក់ឱ្យបានពេលលេញលើទម្រង់ការសាលាក្តី ការផ្តល់ដោយបណ្តាភាគីទីបីត្រូវតែមានចែងនៅក្នុងរបាយការណ៍របស់សាលាក្តី ។

៧. ការរកឃើញ និងការផ្តល់យោបល់របស់សាលាក្តី មិនអាចបន្ថែម ឬ លុបចោលសិទ្ធិ និងកាតព្វកិច្ចដែលមានផ្តល់នៅក្នុងកិច្ចព្រមព្រៀងនេះ ឬ កិច្ចព្រមព្រៀងអន្តរជាតិដទៃទៀត ។

៨. សាលាក្តីត្រូវពិគ្រោះជាប្រចាំជាមួយបណ្តាភាគីនៃវិវាទ និងផ្តល់ឱកាសគ្រប់គ្រាន់សម្រាប់អភិវឌ្ឍដំណោះស្រាយពេញចិត្តទៅវិញទៅមកទៅនឹងវិវាទ ។

៩. សាលាក្តីប្រជុំឡើងវិញក្រោមជំពូកនេះ ត្រូវបំពេញមុខងារដែលពាក់ព័ន្ធជាមួយនឹង Compliance Review ក្រោមមាត្រា ១៦ (Compliance Review) និងសើរើឡើងវិញកំរិតនៃការព្យួរសម្បទាន ឬ កាតព្វកិច្ចដទៃក្រោមមាត្រា ១៧ (ការទូទាត់សង និងការព្យួរសម្បទាន ឬ កាតព្វកិច្ចដទៃទៀត) ។ កថាខណ្ឌ ១ ដល់ ៣ មិនត្រូវអនុវត្តចំពោះសាលាក្តីប្រជុំឡើងវិញក្រោមមាត្រា ១៦ (Compliance Review) និង មាត្រា ១៧ (ការទូទាត់សង និងការព្យួរសម្បទាន ឬ កាតព្វកិច្ចដទៃទៀត) ។

១០. សាលាក្តីត្រូវធ្វើការរកឱ្យឃើញដោយឯកភាពទូទៅ ដោយផ្តល់ថាទីណាដែលសាលាក្តីមិនអាចឈានទៅរកឯកភាពទូទៅ គឺអាចរកឃើញដោយធ្វើការបោះឆ្នោតដោយសំលេងភាគច្រើន ។

## មាត្រា ១៣
## ទម្រង់ការសាលាក្តី

១. សាលាក្តីដែលបង្កើតអនុលោមទៅតាមមាត្រា ១១ (ការបង្កើត និងប្រជុំឡើងវិញសាលាក្តី) ត្រូវតែប្រកាន់ភ្ជាប់ទៅនឹងជំពូកនេះ ។ សាលាក្តីត្រូវអនុវត្តវិធាននៃទម្រង់ការដែលមានចែងនៅក្នុងឧបសម្ព័ន្ធ នៃជំពូកនេះស្តីពីវិធានសំរាប់ទម្រង់ការសាលាក្តី (ឧសម្ព័ន្ធស្តីពីវិធាននៃទម្រង់ការ) លើកលែងតែភាគីនៃវិវាទព្រមព្រៀងផ្សេងពីនេះ ។ ទៅតាមការស្នើដោយភាគីមួយនៃវិវាទ ឬទៅតាមដើមគំនិតរបស់ខ្លួន សាលាក្តីអាច បន្ទាប់ពីពិគ្រោះជាមួយបណ្តាភាគីនៃវិវាទ អនុម័តវិធានបន្ថែមនៃទម្រង់ការ ដែលមិនមានជម្លោះទៅនឹងបទប្បញ្ញត្តិនៃជំពូកនេះ ឬ ទៅនឹងឧសម្ព័ន្ធនៃវិធានទម្រង់ការ ។

២. សាលាក្តីប្រជុំឡើងវិញក្រោមមាត្រា ១៦ (Compliance Review) ឬ មាត្រា ១៧ (ការទូទាត់សង និងការព្យួរសម្បទាន ឬ កាតព្វកិច្ចដទៃទៀត) អាចបង្កើតទម្រង់ការដោយផ្ទាល់ដែលមិនមានជម្លោះទៅនឹងជំពូកនេះ ឬ ទៅនឹងឧសម្ព័ន្ធនៃវិធានទម្រង់ការ ដោយពិគ្រោះជាមួយបណ្តាភាគីនៃវិវាទ ដែលធ្វើឡើងយ៉ាងសមរម្យពីជំពូកនេះ ឬ ទៅនឹងឧសម្ព័ន្ធនៃវិធានទម្រង់ការ ។

**តារាងពេលវេលា**

៣. បន្ទាប់ពីពិគ្រោះជាមួយបណ្តាភាគីនៃវិវាទ សាលាក្តីត្រូវឆាប់ដូចដែលអនុវត្តជាក់ស្តែង និង តាមពេលណាដែលអាចធ្វីទៅបានក្នុងកំឡុង ១៥ ថ្ងៃ បន្ទាប់ពីបង្កើតសាលាក្តីកំណត់តារាងពេលវេលាជាក់លាក់សំរាប់ដំណើរការសាលាក្តី។ ដំណើរការសាលាក្តី ចាប់ពីកាលបរិច្ឆេទនៃការបង្កើតសាលាក្តីរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍ចុងក្រោយត្រូវទៅតាមវិធានទូទៅ មិនលើសពីរយៈពេលប្រាំបួនខែ លើកលែងតែភាគីនៃវិវាទព្រមព្រៀងផ្សេងពីនេះ ។

៤. ដូចគ្នាទៅនឹង Compliance Review Tribunal re-convened អនុលោមទៅតាមមាត្រា ១៦ (Compliance Review) ត្រូវឆាប់ដូចដែលអនុវត្តជាក់ស្តែង និងតាមពេលណាដែលអាចទៅបានក្នុងកំឡុង ១៥ ថ្ងៃ បន្ទាប់ពីប្រជុំឡើងវិញ កំណត់តារាងពេលវេលាជាក់លាក់ សម្រាប់ដំណើរការ Compliance review ដោយយកចិត្តទុកដាក់ទៅលើពេលវេលាបញ្ជាក់នៅក្នុងមាត្រា ១៦ (Compliance Review) ។

**ទម្រង់ការសាលាក្តី**

៥. ទម្រង់ការសាលាក្តីត្រូវផ្តល់ភាពទន់ភ្លន់គ្រប់គ្រាន់ ដើម្បីធានាលើរបាយការណ៍គុណភាពខ្ពស់ ដោយមិនជ្រុលពន្យារដំណើរការសាលាក្តី ។

៦. ការពិភាក្សារបស់សាលាក្តីត្រូវតែជាសម្ងាត់ ។ បណ្តាភាគីនៃវិវាទ និងបណ្តាភាគីទីបី ត្រូវមានវត្តមានតែនៅពេលដែលអញ្ជើញដោយសាលាក្តីដើម្បីបង្ហាញមុនពេលសាលាក្តី។ សាលាក្តីត្រូវរក្សា សវនាការដោយបិទជិតលើកលែងតែភាគីនៃវិវាទព្រមព្រៀងផ្សេងពីនេះ ។ គ្រប់បទបង្ហាញ និងសន្ទរកថា ត្រូវធ្វើឡើងដោយមានវត្តមានរបស់បណ្តាភាគីនៃវិវាទ ។ មិនត្រូវមានការទំនាក់ទំនងជាមួយសាលាក្តីពាក់ព័ន្ធនឹងបញ្ហាកំពុងតែស្ថិតនៅក្នុងការពិចារណា ។

**ការផ្តល់**

៧. ភាគីមួយនៃវិវាទ ត្រូវមានឱកាសក្នុងការសរសេរភាពជាក់ស្តែងរបស់ករណី ការជំទាស់ និងការជំទាស់តប ។ តារាងពេលវេលាដែលកំណត់ដោយសាលាក្តី ត្រូវរួមបញ្ចូលឱ្យច្បាស់លាស់កាលកំណត់ សម្រាប់ការផ្តល់ដោយបណ្តាភាគីនៃវិវាទ និងបណ្តាភាគីទីបី ។

**សវនាការ**

៨. តារាងពេលវេលាដែលកំណត់ដោយសាលាក្តីត្រូវផ្តល់យ៉ាងតិចសវនាការម្តង សម្រាប់បណ្តាភាគី នៃវិវាទដើម្បីបង្ហាញករណីរបស់ពួកគេទៅសាលាក្តី ។ តាមវិធានទូទៅ តារាងពេលវេលាមិនត្រូវឱ្យមានសវនាការលើសពីពីរ លើកលែងតែមានព្រឹត្តិការណ៍ពិសេស ។

៩. ទីកន្លែងសម្រាប់សវនាការ ត្រូវសម្រេចដោយព្រមព្រៀងទៅវិញទៅមករវាងបណ្តាភាគីនៃវិវាទ ។ ប្រសិនបើមិនមានការព្រមព្រៀង ទីកន្លែងត្រូវតែឆ្លាស់គ្នារវាងរាជធានីរបស់បណ្តាភាគីវិវាទ ដែលសវនាការទី១ ត្រូវប្រព្រឹត្តិទៅនៅក្នុងរាជធានីរបស់ភាគីត្រូវឆ្លើយតប ។

**ការសម្ងាត់**

១០. ការសរសេរផ្តល់ទៅសាលាក្តីត្រូវតែរក្សាជាសម្ងាត់ ប៉ុន្តែត្រូវធ្វើឱ្យរកបានទៅបណ្តាភាគីនៃវិវាទ ។ មិនមានភាគីនៃវិវាទត្រូវបានរារាំងពីសន្ទរកថាបង្ហាញពីជំហររបស់គេទៅសាធារណៈដោយផ្តល់ថា មិនមានការបង្ហាញពីពតិមានដែលកំណត់ថាសម្ងាត់ដោយភាគីមួយនៃវិវាទ ឬ ភាគីទីបី ។ បណ្តាភាគីនៃវិវាទ បណ្តាភាគីទីបី និង សាលាក្តីត្រូវប្រព្រឹត្តិជាសម្ងាត់នូវពតិមានដែលបានផ្តល់ដោយភាគីមួយនៃវិវាទ ទៅសាលាក្តីដែលភាគីនោះ បានចាត់ទុកថា ជាសម្ងាត់។ ភាគីមួយនៃវិវាទត្រូវ នៅពេលដែលមានការស្នើសុំដោយ ភាគីមួយផ្តល់ពតិមានសង្ខេបដែលមិនសម្ងាត់ នៅក្នុងការសរសេរផ្តល់ដែលសម្រាប់ បង្ហាញទៅសាធារណៈ ។

**ពតិមានបន្ថែម និង ការណែនាំបច្ចេកទេស**

១១. បណ្តាភាគីនៃវិវាទ និង បណ្តាភាគីទីបីត្រូវឆ្លើយតបជាប្រញាប់ និងពេញលេញទៅនឹងការស្នើសុំណាមួយ ដោយសាលាក្តី ចំពោះពត៌មានដែលសាលាក្តីពិចារណាថាសំខាន់ និងសមរម្យ ។

១២. សាលាក្តីអាចសាកសួររកពត៌មាន និងការណែនាំបច្ចេកទេសពីបុគ្គល ឬស្ថាប័នដែលខ្លួនយល់ថា សមរម្យ ។ យ៉ាងណាក៏ដោយ មុនពេលធ្វើដូចនេះ សាលាក្តីត្រូវសាកសួរយោបល់ពីបណ្តាភាគីនៃវិវាទ ។ ទីណាដែលបណ្តាភាគីនៃវិវាទព្រមព្រៀងថា សាលាក្តីមិនអាចសាកសួរពត៌មានបន្ថែម ឬ ការណែនាំបច្ចេកទេស សាលាក្តីមិនត្រូវធ្វើដូចនេះឡើយ ។ សាលាក្តីត្រូវផ្តល់ឱ្យបណ្តាភាគីនៃវិវាទនូវពត៌មាន ឬ ការណែនាំ បច្ចេកទេសដែលទទួលបាន និងឱកាសសម្រាប់ផ្តល់អនុសាសន៍ ។

**របាយការណ៍**

១៣. សាលាក្តីត្រូវផ្តល់ទៅបណ្តាភាគីនៃវិវាទនូវរបាយការណ៍តំបូង ទៅតាមការតម្រូវ ដែលមានបញ្ជាក់នៅក្នុងមាត្រា ១២.៣ ( មុខងាររបស់សាលាក្តី ) ។

១៤. របាយការណ៍ដំបូងត្រូវផ្តល់យ៉ាងតិចបួនសប្តាហ៍ មុនកាលកំណត់ សម្រាប់បញ្ចប់ របាយការណ៍ចុងក្រោយ ។ សាលាក្តីត្រូវផ្តល់ឱកាសគ្រប់គ្រាន់ទៅបណ្តាភាគីនៃវិវាទដើម្បីរំលឹកឡើងវិញនូវរបាយការណ៍ដំបូង ទាំងមូលមុនពេលបញ្ចប់ និងរួមបញ្ចូលការពិភាក្សាទៅលើអនុសាសន៍ណាមួយ ដែលបានធ្វើឡើងដោយបណ្តាភាគីនៃវិវាទ នៅក្នុងរបាយការណ៍ចុងក្រោយ ។

១៥. របាយការណ៍ដំបូង និងចុងក្រោយរបស់សាលាក្តីត្រូវព្រាងដោយមិនមានវត្តមានរបស់បណ្តាភាគី នៃវិវាទ ។ គំនិតដែលបញ្ចេញនៅក្នុងរបាយការណ៍របស់សាលាក្តីដោយសមាជិកម្នាក់ត្រូវតែអនាមិក ។

១៦. សាលាក្តីត្រូវផ្តល់របាយការណ៍ចុងក្រោយរបសខ្លួន ទៅបណ្តាភាគីទាំងអស់ក្នុងរយៈពេលប្រាំពីរថ្ងៃបន្ទាប់ពីរាយការណ៍ទៅបណ្តាភាគីវិវាទ និងគ្រប់ពេលវេលា ក្រោយពីពេលនោះមកភាគីមួយនៃវិវាទអាចរាយការណ៍ដែលអាចរកបានសាធារណៈ ក្នុងគោលបំណងការពារនូវពត៌មានសម្ងាត់ដែលមានក្នុងរបាយការណ៍នោះ ។

## មាត្រា ១៥
## ការព្យួរ និងបញ្ឈប់ទម្រង់ការ

១. បណ្តាភាគីនៃវិវាទអាចព្រមព្រៀងថា នឹងព្យួរការងារនៅក្នុងពេលណាមួយសំរាប់រយៈពេល ដែលមិនលើសពី ១២ ខែ ពីកាលបរិច្ឆេទនៃការព្រមព្រៀង ។ នៅក្នុងរយៈពេលនោះការព្យួរទម្រង់ការ សាលាក្តី ត្រូវតែបន្ត

នៅពេលដែលមានការស្នើសុំដោយភាគីវិវាទណាមួយ ។ ប្រសិនបើការងារសាលាក្តីត្រូវបានបន្តព្យួរលើសពី ១២ ខែ អំណាចនៃការបង្កើតសាលាក្តីត្រូវតែអស់សុពលភាព លើកលែងតែបណ្តាភាគីនៃវិវាទព្រមព្រៀងផ្សេងពីនេះ ។

២. បណ្តាភាគីនៃវិវាទអាចព្រមព្រៀងក្នុងការបញ្ឈប់ទម្រង់ការសាលាក្តី នៅក្នុងស្ថានការណ៍ដែលបានរកឃើញដំណោះស្រាយទៅនឹងវិវាទដោយពេញចិត្តទៅវិញទៅមក ។

៣. មុនពេលដែលសាលាក្តីបង្ហាញពីរបាយការណ៍ចុងក្រោយ ថាអាចនៅក្នុងដំណាក់កាលណា ក៏ដោយនៃទម្រង់ការ ស្នើទៅបណ្តាភាគីនៃវិវាទថា វិវាទត្រូវបានដោះស្រាយដោយអធ្យាស្រ័យ ។

៤. បណ្តាភាគីនៃវិវាទត្រូវជូនពតិមានទៅភាគីដទៃទៀតថា សាលាក្តីត្រូវបានព្យួរ បញ្ឈប់ ឬអំណាចរបស់ខ្លួនត្រូវអស់សុពលភាពអនុលោមទៅតាមកថាខណ្ឌ ១ ។

## ផ្នែក ឃ

## បទប្បញ្ញត្តិអនុវត្ត

### មាត្រា ១៥

### ការអនុវត្ត

១. ទីណាដែលសាលាក្តីរកឃើញថា ភាគីត្រូវឆ្លើយតប ខកខានក្នុងការបំពេញកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះភាគីត្រូវឆ្លើយតបត្រូវប្រតិបត្តិតាមកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះ ។

២. ក្នុងកំឡុង ៣០ ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទបង្ហាញរបាយការណ៍ចុងក្រោយរបស់សាលាក្តី ទៅបណ្តាភាគីនៃវិវាទ ភាគីដែលត្រូវឆ្លើយតបត្រូវជូនពតិមានទៅភាគីប្តឹងតវ៉ា :

(ក) គោលបំណងនៃការគោរពទៅតាមការអនុវត្តន៍ រួមបញ្ចូលទាំងការកំណត់ពីសកម្មភាព ដែលអាចអនុវត្ត ដើម្បីប្រតិបត្តិតាមកាតព្វកិច្ចនៅក្នុងកថាខណ្ឌ ១ ។

(ខ) ការអនុវត្តន៍ទាំងនោះអាចចាប់ផ្តើមភ្លាម១ និង

(គ) ប្រសិនបើការអនុវត្តមិនអាចចាប់ផ្តើមភ្លាម១ ពេលវេលាសមរម្យមួយដែលភាគីត្រូវឆ្លើយតបអាចត្រូវការសំរាប់ការអនុវត្តន៍ ។

៣. ប្រសិនបើមិនធ្លាប់មានការអនុវត្តនីភ្លាម១ជាមួយនឹងកាតព្វកិច្ច ដែលមាននៅក្នុងកថាខណ្ឌ ១ ភាគី ត្រូវឆ្លើយតប ត្រូវមានពេលវេលាសមរម្យសំរាប់ធ្វើដូចនោះ។

៤. ប្រសិនបើតម្រូវទៅតាមពេលវេលាសមរម្យ វាអាចនៅពេលណាដែលអាចព្រមព្រៀងទៅវិញទៅមកដោយបណ្តាភាគីនៃវិវាទ។ ទីណាដែលបណ្តាភាគីនៃវិវាទមិនមានការព្រមព្រៀងទៅលើពេលវេលាសមរម្យ ក្នុងកំឡុង ៤៥ ថ្ងៃ នៃកាលបរិច្ឆេទបង្ហាញរបាយការណ៍ចុងក្រោយរបស់សាលាក្តីទៅបណ្តាភាគីនៃវិវាទ ភាគីណាមួយនៃវិវាទ អាចស្នើសុំទៅប្រធានសាលាក្តីដើម្បីកំណត់ពេលវេលា។ លើកលែងតែបណ្តាភាគីនៃវិវាទព្រមព្រៀងផ្សេង ការស្នើសុំត្រូវធ្វើឡើងមិនឱ្យតិចជាង ១២០ ថ្ងៃ ពីកាលបរិច្ឆេទនៃការបង្ហាញរបាយការណ៍ចុងក្រោយរបស់សាលាក្តី ទៅបណ្តាភាគីនៃវិវាទ។

៥. ទីណាដែលការស្នើសុំដែលបានធ្វើអនុលោមទៅតាមកថាខណ្ឌ ៤ ប្រធានសាលាក្តីត្រូវបង្ហាញ ទៅបណ្តាភាគីនៃវិវាទជាមួយនឹងរបាយការណ៍ដែលមានការកំណត់ពីពេលវេលាសមរម្យ និងមូលហេតុនៃការកំណត់នោះ ក្នុងកំឡុង ៤៥ ថ្ងៃ នៃកាលបរិច្ឆេទស្នើសុំ។

៦. ដូចដែលមាននៅក្នុងគោលការណ៍ណែនាំ ពេលវេលាដែលសមរម្យកំណត់ដោយប្រធានសាលាក្តីមិនត្រូវលើស ១៥ ខែ ពីកាលបរិច្ឆេទនៃការបង្ហាញរបាយការណ៍ចុងក្រោយរបស់សាលាក្តីទៅបណ្តាភាគីវិវាទ។ យ៉ាងណាមិញ ពេលវេលាសមរម្យអាចខ្លីជាង ឬ វែងជាង ដោយផ្អែកទៅលើហេតុការណ៍ ជាក់លាក់ណាមួយ។

## មាត្រា ១៦

## Compliance Review

១. ទីណាដែលបណ្តាភាគីនៃវិវាទមិនមានការព្រមព្រៀងទៅលើភាពដែលមានស្រាប់ ឬ ភាពជាប់លាប់នៃវិធានការនៃកិច្ចព្រមព្រៀងនេះប្រព្រឹត្តិតាមកាតព្វកិច្ចនៅក្នុងមាត្រា ១៥.១ (ការអនុវត្ត) វិវាទទាំងនោះត្រូវសំរេចតាមរយៈបណ្តឹងសើរើ ទៅសាលាក្តីប្រជុំឡើងវិញ សម្រាប់គោលបំណង (សាលាឧទ្ធរណ៍)[៣]។ លើកលែងតែមានការចែងជាក់លាក់នៅក្នុងជំពូកនេះ សាលាឧទ្ធរណ៍អាចចាប់ផ្តើមទៅតាមការស្នើសុំរបស់ភាគីវិវាទណាមួយ។

២. ការស្នើសុំនោះអាចធ្វើឡើងបន្ទាប់ពីមុនពេលកំណត់តែប៉ុណ្ណោះនៃ :

(ក) ការផុតកំណត់នៃពេលវេលាសមរម្យ ឬ

---

[៣] ការពិគ្រោះក្រោមមាត្រា ៦ (ការពិគ្រោះ) មិនតម្រូវចំពោះទម្រង់ការទាំងនោះ។

(ខ) ការជូនពត៌មានទៅភាគីប្តឹងតវ៉ាដោយភាគីត្រូវឆ្លើយតបថា បានប្រព្រឹត្តិតាមកាតព្វកិច្ចនៅក្នុងមាត្រា ១៥.១ (ការអនុវត្តន៍) ។

៣. សាលាឧទ្ធរណ៍អាចធ្វើការប៉ាន់ប្រមាណមើលពីបញ្ហាមុន រួមទាំងការប៉ាន់ប្រមាណមើលលើ :

(ក) ទ្រង់ទ្រាយពិតនៃការអនុវត្តសកម្មដោយភាគីត្រូវឆ្លើយតប និង

(ខ) ថាតើភាគីត្រូវឆ្លើយតបបានប្រព្រឹត្តិតាមកាតព្វកិច្ចនៅក្នុងមាត្រា ១៥.១ (ការអនុវត្តន៍)

៤. សាលាឧទ្ធរណ៍ត្រូវធ្វើរបាយការណ៍ :

(ក) រៀបរាប់សង្ខេបពីផ្នែកជម្លោះរបស់បណ្តាភាគីនៃវិវាទ និងបណ្តាភាគីទីបី ។

(ខ) រកឱ្យឃើញការពិតនៃករណី និង

(គ) រកឱ្យឃើញថាតើភាគីត្រូវឆ្លើយតបបានប្រព្រឹត្តិតាមកាតព្វកិច្ចនៅក្នុងមាត្រា ១៥.១ (ការអនុវត្ត) ។

៥. សាលាឧទ្ធរណ៍ត្រូវ ទីណាដែលអាចបាន ផ្តល់នូវរបាយការណ៍ដំបូងទៅបណ្តាភាគីនៃវិវាទក្នុងកំឡុង ៧៥ ថ្ងៃ នៃកាលបរិច្ឆេទចូលប្រជុំវិញ និងរបាយការណ៍ចុងក្រោយ ១៥ ថ្ងៃបន្ទាប់។ ពេលដែលសាលាឧទ្ធរណ៍ពិចារណាថា មិនអាចផ្តល់របាយការណ៍ទៅនឹងពេលវេលានោះ គឺត្រូវផ្តល់ទៅបណ្តាភាគីនៃវិវាទជាលាយលក្ខណ៍អក្សរពីមូលហេតុ និងប៉ាន់ស្មានពេលវេលាដែលនឹងត្រូវផ្តល់របាយការណ៍ ។

៦. ទីណាដែលសាលាក្តីត្រូវបានស្នើឡើងសំរាប់ប្រជុំឡើងវិញអនុលោមទៅតាមកថាខណ្ឌ ១ គឺ ត្រូវប្រជុំឡើងវិញក្នុងកំឡុង ១៥ ថ្ងៃ នៃកាលបរិច្ឆេទស្នើសុំ។ រយៈពេលចាប់តាំងពីកាលបរិច្ឆេទនៃការស្នើសុំទៅសាលាក្តី ដើម្បីប្រជុំឡើងវិញ ដើម្បីផ្តល់របាយការណ៍ចុងក្រោយមិនត្រូវលើសពី ១២០ ថ្ងៃ លើកលែងតែមាត្រា ១១.១២ (ការបង្កើតសាលាក្តីប្រជុំឡើងវិញ) អនុវត្ត ឬ បណ្តាភាគីនៃវិវាទព្រមព្រៀងផ្សេងពីនេះ ។

## មាត្រា ១៧

## ការទូទាត់សង និងពន្យារសម្បទាន ឬ កាតព្វកិច្ចដទៃទៀត

១. ការទូទាត់សង និងពន្យារសម្បទាន ឬ កាតព្វកិច្ចដទៃទៀតជាវិធានការបណ្តោះអាសន្នអាចរកបាននៅពេលដែលភាគីត្រូវឆ្លើយតប មិនប្រតិបត្តិតាមកាតព្វកិច្ចនៅក្រោមមាត្រា ១៥.១ (ការអនុវត្តន៍) ។ ទោះជាយ៉ាងណាក៏ដោយ ទាំងការទូទាត់សង ទាំងការពន្យារសម្បទាន ឬកាតព្វកិច្ចដទៃទៀត ត្រូវតែផ្អែកទៅលើកាតព្វកិច្ចក្រោម

មាត្រា ១៥.១ (ការអនុវត្ត) ។ ការទូទាត់សងគឺដោយស្ម័គ្រចិត្ត និងប្រសិនបើឱ្យ ត្រូវតែស្របទៅតាមកិច្ចព្រមព្រៀងនេះ ។

២. ទីណាដែលហេតុការណ៍ទាំងនេះកើតមាន :

(ក) ភាគីឆ្លើយតប ត្រូវជូនពតិមានទៅភាគីប្តឹងតវ៉ាថា វាមិនមានបំណងក្នុងការប្រតិបត្តិតាមកាតព្វកិច្ចនៅក្នុងមាត្រា ១៥. ១ (ការអនុវត្តន៍) ឬ

(ខ) ការខកខានមិនប្រតិបត្តិតាមទៅនឹងកាតព្វកិច្ចនៅក្នុងមាត្រា ១៥.១ (ការអនុវត្តន៍) បានបង្កើតយោងទៅតាមមាត្រា ១៦ (Compliance Review) ។

ភាគីត្រូវឆ្លើយតបត្រូវ ប្រសិនបើមានការស្នើដោយភាគីប្តឹងតវ៉ា ចូលចរចាក្នុងគំនិតអភិវឌ្ឍ ការទូទាត់សងដែលអាចទទួលយកបានទៅវិញទៅមក ។

៣. ប្រសិនបើការទូទាត់សងមិនមានការពេញចិត្ត ដូចដែលបានព្រមព្រៀងក្នុងកំឡុង ៣០ ថ្ងៃ នៃកាលបរិច្ឆេទស្នើសុំ ដែលបានធ្វើក្រោមកថាខណ្ឌ ២ ភាគីប្តឹងតវ៉ាអាច គ្រប់ពេលវេលាបន្ទាប់ពីជូនពតិមានទៅភាគីត្រូវឆ្លើយតប និងបណ្តាភាគីដទៃទៀតដែលមានបំណងក្នុងការពន្យារការអនុវត្ត ទៅភាគីត្រូវឆ្លើយតបនូវសម្បទាន ឬកាតព្វកិច្ចដទៃ មានតម្លៃស្មើទៅនឹងកំរិតមោឃៈភាព និងខូចខាត ត្រូវមានសិទ្ធិចាប់ផ្តើមពន្យារសម្បទាន ឬ កាតព្វកិច្ចដទៃ ៣០ ថ្ងៃ បន្ទាប់ពីការទទួលការជូនពតិមាន ។

៤. សិទ្ធិក្នុងការពន្យារសម្បទាន ឬកាតព្វកិច្ចដែលកើតឡើងក្រោមកថាខណ្ឌ ៣ មិនត្រូវបានប្រើទីណា :

(ក) ការរំលឹកឡើងវិញកំពុងតែដំណើរការអនុលោមទៅតាមកថាខណ្ឌ ៨. ឬ

(ខ) ការឈានទៅដល់ដំណោះស្រាយដែលព្រមព្រៀងទៅវិញទៅមក ។

៥. ការជូនពតិមានដែលបានធ្វើនៅក្រោមកថាខណ្ឌ ៣ ត្រូវបញ្ជាក់ពីកំរិតសម្បទាន ឬ កាតព្វកិច្ចដទៃដែលភាគីប្តឹងតវ៉ាស្នើសម្រាប់ការពន្យារ និងជំពូក និងផ្នែកដែលពាក់ព័ន្ធទៅនឹងសម្បទាន ឬកាតព្វកិច្ច ។

៦. ក្នុងការពិចារណាថា សម្បទាន ឬកាតព្វកិច្ចដើម្បីពន្យារ ភាគីប្តឹងតវ៉ាអាចអនុវត្តគោលការណ៍ ដូចខាងក្រោម :

(ក) ដំបូងបង្អស់ភាគីប្តឹងតវ៉ាត្រូវស្វែងរកការពន្យារសម្បទាន ឬ កាតព្វកិច្ចដទៃ ចំពោះវិស័យដូច ឬវិស័យដែលបានប៉ះពាល់ដោយវិធានការ និង

(ខ) ភាគីប្តឹងតវ៉ាអាចពន្យារសម្បទាន ឬ កាតព្វកិច្ចដទៃចំពោះវិស័យដទៃ ប្រសិនបើ ពិចារណាឃើញថា វាមិនអាចប្រព្រឹត្តិបាន ឬ ប៉ះពាល់ដល់ការពន្យារសម្បទាន ឬ កាតព្វកិច្ច ចំពោះវិស័យដូច។

៧. កំរិតនៃការពន្យារសម្បទាន ឬ កាតព្វកិច្ចដទៃ ត្រូវតែមានតម្លៃស្មើទៅនឹងកំរិតនៃ មោឃៈភាព និង ខូចខាត។

៨. ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលពត៌មានដែលបានធ្វើក្រោមកថាខណ្ឌ ៣ ប្រសិនបើភាគីត្រូវឆ្លើយតបបដិសេធទៅនឹងកំរិតស្នើសុំពន្យារ ឬ ពិចារណាថាគោលការណ៍ដែលមានចែងនៅក្នុងកថាខណ្ឌ ៦ មិនប្រតិបត្តិតាមភាគីត្រូវឆ្លើយតបអាចស្នើសុំទៅសាលាក្តី ដើម្បីប្រជុំឡើងវិញដើម្បីរកឱ្យឃើញបញ្ហា។ សាលាក្តីត្រូវផ្តល់ការថ្លឹងប្រមាណទៅបណ្តាភាគីនៃវិវាទក្នុងកំឡុង ៣០ ថ្ងៃ នៃកាលបរិច្ឆេទការប្រជុំឡើងវិញនោះ។ ទីណាដែលសាលាក្តីត្រូវបានស្នើសុំឱ្យប្រជុំឡើងវិញ អនុលោមទៅ តាមកថាខណ្ឌនេះ លើកលែងតែមាត្រា ១១.១២ (ការបង្កើត និងប្រជុំឡើងវិញរបស់សាលាក្តី) អនុវត្ត។

៩. ការពន្យារសម្បទាន ឬ កាតព្វកិច្ចដទៃត្រូវតែបណ្តោះអាសន្ន និងមិនត្រូវអនុវត្តរហូតដល់ពេលវេលាដែលកាតព្វកិច្ចនៅក្នុងមាត្រា ១៥.១ (ការអនុវត្ត) ត្រូវបានអនុវត្តជាមួយនឹង ឬ ឈានទៅដល់ដំណោះស្រាយពេញចិត្តទៅវិញទៅមក។

១០. ទីណាដែលសិទ្ធិសំរាប់ការពន្យារសម្បទាន ឬ កាតព្វកិច្ចដទៃត្រូវបានអនុវត្តក្រោមមាត្រានេះ ប្រសិនបើ ភាគីត្រូវឆ្លើយតបពិចារណាថា :

(ក) កំរិតនៃសម្បទាន ឬ កាតព្វកិច្ចដទៃពន្យារដោយភាគីប្តឹងតវ៉ា មិនមានតម្លៃស្មើទៅនឹងកំរិតនៃ មោឃៈភាព និង ខូចខាត ឬ

(ខ) វាបានអនុវត្តទៅតាមកាតព្វកិច្ចនៅក្នុងមាត្រា ១៥. ១ (ការអនុវត្ត)។

វាអាចស្នើសុំទៅសាលាក្តីប្រជុំឡើងវិញដើម្បីពិនិត្យបញ្ហា[៤] ។

---

[៤] ទីណាដែលសាលាឧទ្ធរណ៍សម្រេចថា វិធានការដែលបានអនុវត្តដើម្បីប្រតិបត្តិតាម មិនសមស្របទៅនឹងកិច្ចព្រមព្រៀងនេះ វាអាចទៅលើការស្នើសុំថ្លឹងប្រមាណថា កំរិតនៃការពន្យារសម្បទានដែលមានស្រាប់អាចយកបាន និងបើមិនអាចត្រូវធ្វើការថ្លឹងប្រមាណកំរិតដែលអាចយកបាន។

១១. ទីណាដែលសាលាក្តីប្រជុំឡើងវិញអនុលោមទៅតាមកថាខ័ណ្ឌ ១០ (ក) កថាខ័ណ្ឌ ៨ ត្រូវអនុវត្ត។ ទីណាដែលសាលាក្តីប្រជុំឡើងអនុលោមទៅតាមកថាខ័ណ្ឌ ១០ (ខ) មាត្រា ១៦.៣ ដល់ ១៦. ៥ (Compliance Review) ត្រូវអនុវត្ត។

## ផ្នែក ១

## អវសានបញ្ញត្តិ

## មាត្រា ១៨

## ប្រព្រឹត្តិកម្មពិសេស និងដោយឡែកពាក់ព័ន្ធសមាជិកអាស៊ានថ្មី

១. នៅគ្រប់ដំណាក់កាលនៃការកំណត់មូលហេតុវិវាទ និងនីតិវិធីដោះស្រាយវិវាទ ពាក់ព័ន្ធទៅនឹងសមាជិកថ្មីអាស៊ាន ការពិចារណាដោយអាណិតអាសូរដោយឡែកត្រូវផ្តល់ទៅតាមស្ថានភាពពិសេស ចំពោះសមាជិកថ្មីអាស៊ាន។ ដោយហេតុនេះ បណ្តាភាគីត្រូវអនុវត្តដោយបន្ថយនៅក្នុងការលើកឡើងនៃបញ្ហាក្រោមនីតិវិធីនេះ ដែលពាក់ព័ន្ធទៅនឹងភាគីដែលជាប្រទេសអភិវឌ្ឍន៍តិចតួច។ ប្រសិនបើ មោឃៈភាព និងការខូចខាតត្រូវបានរកឃើញ មកពីវិធានដែលបានប្រើប្រាស់ដោយភាគីដែលជាប្រទេសអភិវឌ្ឍន៍តិចតួច ភាគីប្តឹងតវ៉ាមួយ អាចអនុវត្តការបន្ធូរបន្ថយបញ្ហាពាក់ព័ន្ធគ្រប់ដណ្តប់ក្រោមមាត្រា ១៧ (ការទូរទាត់ សង និងពន្យារសម្បទាន ឬ កាតព្វកិច្ចដទៃ) ឬ កាតព្វកិច្ចដទៃអនុលោមទៅតាមនីតិវិធីទាំងនេះ។

២. ទីណាដែលភាគីវិវាទមួយ ឬច្រើនជាសមាជិកថ្មីអាស៊ាន របាយការណ៍របស់សាលាក្តីត្រូវបញ្ជាក់ច្បាស់លាស់ ពីទម្រង់រឿងរ៉ាវដែលបានអនុវត្តពាក់ព័ន្ធទៅនឹងបទប្បញ្ញត្តិស្តីពីប្រព្រឹត្តិកម្មពិសេស និងដោយឡែកសម្រាប់សមាជិកអាស៊ានថ្មី ត្រូវជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ ដែលត្រូវបានលើកឡើងដោយសមាជិកអាស៊ានថ្មីនៅក្នុងមូលហេតុនៃនីតិវិធីដោះស្រាយវិវាទ។

## មាត្រា ១៩

## សោហ៊ុយចំណាយ

១. លើកលែងតែបណ្តាភាគីនៃវិវាទព្រមព្រៀង ភាគីនីមួយៗនៃវិវាទត្រូវទទួលបន្ទុកលើសោហ៊ុយនៃការចាត់តាំងអាជ្ញាកណ្តាល និងសោហ៊ុយចំណាយផ្ទាល់ខ្លួន និងសោហ៊ុយផ្លូវច្បាប់។

២. លើកលែងតែបណ្តាភាគីនៃវិវាទព្រមព្រៀង សោហ៊ុយសម្រាប់ប្រធានសាលាក្តី និងសោហ៊ុយចំណាយដទៃទៀត ពាក់ព័ន្ធទៅនឹងការរៀបចំទម្រង់ការ ត្រូវចំណាយស្មើគ្នាដោយបណ្តាភាគីនៃវិវាទ ។

## មាត្រា ២០

## ចំណុចទំនាក់ទំនង

១. ភាគីនីមួយៗត្រូវជ្រើសតាំងចំណុចទំនាក់ទំនងសំរាប់ជំពូកនេះ និងត្រូវជូនពត៌មានទៅបណ្តាភាគីដទៃលំអិតពីចំណុចទំនាក់ទំនងនេះក្នុងកំឡុង ៣០ ថ្ងៃ នៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ។ ភាគីនីមួយៗ ត្រូវជូនពត៌ទៅបណ្តាភាគីដទៃនៃការផ្លាស់ប្តូរចំណុចទំនាក់ទំនង ។

២. ការស្នើសុំណាមួយ ផ្តល់ជាលាយលក្ខណ៍អក្សរ ឬ ឯកសារដទៃពាក់ព័ន្ធទៅនឹងទម្រង់ការណាមួយអនុលោមទៅតាមជំពូកនេះ ត្រូវជូនដល់ភាគីពាក់ព័ន្ធ ឬ បណ្តាភាគីតាមរយៈចំណុចទំនាក់ទំនងដែលបានចាត់តាំងជាអ្នកត្រូវផ្តល់ពត៌មានបញ្ជាក់នៃការទទួលឯកសារជាលាយលក្ខណ៍អក្សរទាំងនោះ ។

## មាត្រា ២១

## ភាសា

១. រាល់ទម្រង់ការអនុលោមទៅតាមជំពូកនេះត្រូវរៀបចំជាភាសាអង់គ្លេស ។

២. ឯកសារណាមួយដែលបានផ្តល់ សម្រាប់ប្រើប្រាស់នៅក្នុងទម្រង់ការអនុលោមទៅតាមជំពូក នេះត្រូវជាភាសាអង់គ្លេស។ ប្រសិនបើឯកសារដើមណាមួយមិនមែនជាភាសាអង់គ្លេស ភាគីមួយដែលផ្តល់ឱ្យសម្រាប់ប្រើនៅក្នុងទម្រង់ការ ត្រូវផ្តល់ការបកប្រែឯកសារនោះជាភាសាអង់គ្លេស ។

## ឧបសម្ព័ន្ធស្តីពីវិធាន នៃនីតិវិធីសំរាប់ទម្រង់ការសាលាក្តី

១. ឯកសារយោងណាមួយបានធ្វើឡើងនៅក្នុងវិធានទាំងនេះទៅនឹងមាត្រាមួយ គឺជាឯកសារយោងសមរម្យទៅនឹងមាត្រានៅក្នុងជំពូក ១៧ (ការពិគ្រោះ និងដោះស្រាយវិវាទ) ។

**តារាងពេលវេលា**

២. បន្ទាប់ពីពិគ្រោះជាមួយបណ្តាភាគីវិវាទ សាលាក្តីត្រូវកាន់តែឆាប់ប្រតិបត្តិបាន និងពេលណាដែលអាចធ្វើទៅបានក្នុងកំឡុង ១៥ ថ្ងៃ បន្ទាប់ពីបង្កើតសាលាក្តី កំណត់តារាងពេលវេលាសម្រាប់ដំណើរការសាលាក្តី ។

ដំណើរការសាលាក្តី ពីកាលបរិច្ឆេទនៃការបង្កើត រហូតដល់កាលបរិច្ឆេទនៃរបាយការណ៍ចុងក្រោយត្រូវដូចវិធានទូទៅ មិនលើសពីរយៈពេលប្រាំបួនខែ លើកលែងតែបណ្តាភាគីនៃវិវាទព្រមព្រៀងផ្សេងពីនេះ ។

៣. ក្នុងការកំណត់តារាងពេលវេលា សម្រាប់ដំណើរការសាលាក្តី សាលាក្តីត្រូវផ្តល់ពេលវេលាគ្រប់គ្រាន់ សម្រាប់បណ្តាភាគីនៃវិវាទរៀបចំការផ្តល់ជូនរបស់គេ ។ សាលាក្តីត្រូវចាត់កាលកំណត់សម្រាប់ការសរសេរផ្តល់ដោយបណ្តាភាគីនៃវិវាទ និងគេត្រូវគោរពទៅតាមកាលកំណត់នោះ ។ របាយការណ៍ដំបូង ត្រូវផ្តល់ឱ្យបានយ៉ាងតិចបំផុត បួនសប្តាហ៍មុនកាលកំណត់ សម្រាប់បញ្ចប់របាយការណ៍ចុងក្រោយ ។

៤. សាលាក្តីត្រូវបញ្ចេញទៅបណ្តាភាគីនៃវិវាទនូវរបាយការណ៍ចុងក្រោយក្នុងកំឡុង ១៨០ ថ្ងៃ ពីកាលបរិច្ឆេទនៃការបង្កើតសាលាក្តី ។ ក្នុងករណីបន្ទាន់ រួមទាំងការពាក់ព័ន្ធទៅនឹងទំនិញឆាប់ពុកផុយរលួយ សាលាក្តីត្រូវមានបំណងក្នុងការចេញរបាយការណ៍ទៅបណ្តាភាគីនៃវិវាទក្នុងកំឡុង ៩០ ថ្ងៃ ពីកាលបរិច្ឆេទនៃការបង្កើត ។ ពេលណាដែលសាលាក្តីពិចារណាថា មិនអាចបញ្ចេញរបាយការណ៍ចុង ក្រោយក្នុងកំឡុង ១៨០ថ្ងៃ ឬ ក្នុងកំឡុង ៩០ ថ្ងៃ ក្នុងករណីបន្ទាន់ ត្រូវផ្តល់ពត៌មានទៅបណ្តាភាគី នៃវិវាទជាលាយលក្ខណ៍អក្សរពីមូលហេតុនៃការយឺតយ៉ាវរួម ជាមួយនឹងការប៉ាន់ស្មានពេលវេលា ដែលអាចចេញរបាយការណ៍ ។

៥. ពេលវេលាណាមួយដែលអាចអនុវត្តបាន ទម្រង់ការសាលាក្តីពន្យារចំពោះរយៈពេលដែលចាប់ផ្តើមនៅចំកាលបរិច្ឆេទដែលសមាជិកណាមួយនៃសាលាក្តីលាឈប់ ឬ គ្មានលទ្ធភាពក្នុងការបំពេញការងារ និងបញ្ចប់នៅចំកាលបរិច្ឆេទដែលសមាជិកជំនួសត្រូវបានចាត់តាំង ។

៦. លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះដោយបណ្តាភាគីនៃវិវាទ សាលាក្តីអាចពិគ្រោះជាមួយបណ្តាភាគីនៃវិវាទ កែប្រែពេលវេលាដែលអាចអនុវត្តបាន នៅក្នុងទម្រង់ការសាលាក្តី និងអាចធ្វើទម្រង់ការដទៃ ឬកែខែរដ្ឋបាលដូចដែលអាចតម្រូវនៅក្នុងទម្រង់ការ ។

**ការប្រតិបត្តិនៃសាលាក្តី**

៧. ប្រធានសាលាក្តីត្រូវធ្វើជាប្រធានគ្រប់កិច្ចប្រជុំ ។ សាលាក្តីអាចផ្តល់អំណាចទៅឱ្យប្រធាន ដើម្បីធ្វើការងាររដ្ឋបាល និងទម្រង់ការសម្រេច ។

៨. លើកលែងតែមានការផ្តល់ផ្សេងនៅក្នុងឧបសម្ព័ន្ធនេះ សាលាក្តីអាចរៀបចំធុរកិច្ចដោយគ្រប់មធ្យោបាយរួមទាំង ទូរស័ព្ទ ទូរសារ និងមធ្យោបាយដទៃណាមួយនៃការទំនាក់ទំនងអេឡិចត្រូនិច ។

៩. មានតែសមាជិកនៃសាលាក្តីអាចមានចំណែកនៅក្នុងការពិភាក្សារបស់សាលាក្តី ។

១០. សាលាក្តីអាច ពិគ្រោះជាមួយបណ្តាភាគីនៃវិវាទ រក្សាចំនួនជំនួយការ អ្នកបកប្រែ អ្នកកត់ត្រា ដែលបានចាត់តាំងដូចដែលតម្រូវសំរាប់ទម្រង់ការ និងអនុញ្ញាតឱ្យពួកគេមានវត្តមានក្នុងដំណើរការពិគ្រោះ។ ការរៀបចំណាមួយ ដែលបានបង្កើតដោយសាលាក្តីអាចកែប្រែដោយការព្រមព្រៀងរបស់បណ្តាភាគីនៃវិវាទ។

១១. ការពិភាក្សារបស់សាលាក្តីត្រូវតែជាសម្ងាត់។ សមាជិករបស់សាលាក្តី និងបុគ្គលដែលរក្សា ដោយសាលាក្តីត្រូវរក្សាការសម្ងាត់នៃទម្រង់ការសាលាក្តី និងការពិភាក្សា។

១២. មិនត្រូវមានទំនាក់ទំនងណាមួយមុន *(ex parte)* ជាមួយសាលាក្តីពាក់ព័ន្ធទៅនឹងបញ្ហា ក្រោមការពិចារណារបស់សាលាក្តី។

១៣. បណ្តាភាគីទីបីដែលមានចំណាប់អារម្មណ៍ និងបណ្តាភាគីដទៃទៀត ត្រូវយកចិត្តទុកដាក់នៅក្នុងរយៈពេលនៃទម្រង់ការសាលាក្តី។

**ការសរសេរផ្តល់ និង ឯកសារដទៃ**

១៤. ភាគីណាមួយនៃវិវាទ អាចបញ្ជូនទៅសាលាក្តីនៃការផ្តល់តំបូងជាលាយលក្ខណ៍អក្សរដោយ ដាក់នូវការពិតរបស់ករណី និងជម្លោះរបស់វា។ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះដោយបណ្តាភាគី ភាគីប្តឹងតវ៉ាត្រូវបញ្ជូនការផ្តល់តំបូងទៅសាលាក្តី និងទៅភាគីត្រូវឆ្លើយតបក្នុងកំឡុង ១៤ ថ្ងៃ បន្ទាប់ពីការបរិច្ឆេទនៃការបង្កើតសាលាក្តី។ ភាគីត្រូវឆ្លើយតបត្រូវបញ្ជូនការផ្តល់តំបូងទៅសាលាក្តី និងទៅភាគីប្តឹងតវ៉ាក្នុងកំឡុង ២១ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលការផ្តល់តំបូងរបស់ភាគីប្តឹងតវ៉ា។ ការសរសេរផ្តល់បន្តបន្ទាប់ ត្រូវផ្តល់ដំណាលគ្នា។

១៥. ភាគីមួយនៃវិវាទត្រូវបញ្ជូនការសរសេរផ្តល់មិនឱ្យតិចជាងបួនច្បាប់ទៅសាលាក្តី និងមួយច្បាប់ទៅបណ្តាភាគីនៃវិវាទ។ បណ្តាភាគីទីបី ត្រូវទទួលការផ្តល់របស់បណ្តាភាគីនៃវិវាទនៃសារៈសំខាន់របស់សវនាការដំបូង។

១៦. ដោយគោរពទៅតាមការស្នើសុំណាមួយ កំណត់ត្រា ឬ ឯកសារដទៃពាក់ព័ន្ធទៅនឹងទម្រង់ការសាលាក្តី ដែលមិនគ្របដណ្តប់ដោយវិធាន ១៤ និង ១៥ ភាគីនីមួយៗនៃវិវាទអាចបញ្ជូនច្បាប់ចំលងនៃឯកសារ ទៅភាគីដទៃនៃវិវាទដោយទូរសារ អ៊ីម៉ែល ឬមធ្យោបាយបញ្ជូនអេឡិចត្រូនិចដទៃ។

១៧. ភាគីមួយនៃវិវាទអាច គ្រប់ពេលវេលាកែតម្រូវកំហុសតិចតួចនៃសហជម្មិកនៅក្នុងការស្នើសុំកំណត់ត្រា ការសរសេរផ្តល់ ឬ ឯកសារដទៃ ពាក់ព័ន្ធទៅនឹងទម្រង់ការសាលាក្តី ដោយបញ្ជូនឯកសារថ្មីបញ្ជាក់ច្បាស់ពីការកែប្រែ។

*សវនាការ*

១៨. នៅក្នុងសវនាការជុំកំភូនតំបូងជាមួយនឹងបណ្តាភាគីនៃវិវាទ ភាគីនីមួយៗនៃវិវាទត្រូវបង្ហាញការពិតនៃករណី និងជម្លោះរបស់ខ្លួន ។ ភាគីប្តឹងតវ៉ាត្រូវបង្ហាញពីជំហរដំបូងរបស់ខ្លួន ។ បណ្តាភាគីនៃវិវាទត្រូវឱ្យឱកាសសំរាប់សេចក្តីថ្លែងការណ៍ ជាមួយនិងការបង្ហាញសេចក្តីថ្លែងការណ៍របស់ភាគីប្តឹង តវ៉ាមុន ។

១៩. បណ្តាភាគីទីបីទាំងអស់ត្រូវបានអញ្ជើញ ដើម្បីបង្ហាញពីគំនិតនៅក្នុងសម័យប្រជុំដោយឡែក នៃសវនាការជុំកំភូនដំបូងដែលបានរៀបចំសំរាប់គោលបំណងនោះ ។ បណ្តាភាគីទីបីអាចបង្ហាញនៅក្នុងរយៈពេលកិច្ចប្រជុំទាំងមូល ។

២០. បណ្តាភាគីនៃវិវាទ និងបណ្តាភាគីទីបី ត្រូវធ្វើឱ្យរកបាននូវការសរសេរនៃសេចក្តីថ្លែងការណ៍ ដោយមាត់សម្រាប់សាលាក្តី និងឆ្លើយតបទៅនឹងសំណួរដែលបានធ្វើនៅក្នុងសវនាការជាមួយនិង សាលាក្តី ។

**ពត៌មានដែលអាចរកបាន**

២១. ការសរសេរផ្តល់ទៅសាលាក្តីត្រូវប្រព្រឹត្តិជាសម្ងាត់ ប៉ុន្តែត្រូវធ្វើឱ្យអាចរកបានដោយបណ្តាភាគីនៃវិវាទ ។ គ្មានភាគីនៃវិវាទត្រូវ រារាំងពីការបង្ហាញសេចក្តីថ្លែងការណ៍ពីគោលជំហររបស់ខ្លួនទៅសាធារណៈ ដោយផ្តល់ថាទាំងនោះមិនមែនបង្ហាញពត៌មានដែលចាត់ទុកថាសម្ងាត់ដោយបណ្តាភាគីនៃវិវាទ ឬភាគីទីបី ។ បណ្តាភាគីនៃវិវាទភាគីទីបី និងសាលាក្តី ត្រូវប្រព្រឹត្តិពតិជាសម្ងាត់ពត៌មានដែលបាន ផ្តល់ដោយ ភាគីដែលកំណត់ថាជាសម្ងាត់ ។ ភាគីមួយនៃវិវាទត្រូវ តាមការស្នើសុំរបស់ភាគីដទៃ ផ្តល់ជាសង្ខេបមិនមែនសម្ងាត់នៃពត៌មានដែលមាននៅក្នុងការសរសេរផ្តល់ថា ជាពត៌មានអាចបង្ហាញទៅសាធារណៈ ។

**ប្រមូលផ្តុំពត៌មាន**

២២. បណ្តាភាគីនៃវិវាទ និងបណ្តាភាគីទីបីត្រូវឆ្លើយតបបន្ទាន់ និងពេញលេញទៅការស្នើសុំណាមួយដោយសាលាក្តីដែលពត៌មាននោះសាលាក្តីពិចារណាថាសំខាន់ និងសមរម្យ ។

២៣. សាលាក្តីអាចស្វែងរកពត៌មាន និងណែនាំបច្ចេកទេសពីបុគ្គល ឬ ស្ថាប័ន ដែលយល់ថាសមរម្យ ។ យ៉ាងណាក៏ដោយ មុនពេលធ្វើដូចនោះ សាលាក្តីត្រូវស្នើសុំយោបល់ពីបណ្តាភាគីនៃវិវាទ ។ ទីណា ដែលបណ្តាភាគីនៃវិវាទព្រមព្រៀងថា សាលាក្តីមិនត្រូវស្វែងរកពត៌មានបន្ថែម ឬ ណែនាំបច្ចេកទេស សាលាក្តីមិនត្រូវធ្វើដូច្នោះឡើយ ។ សាលាក្តីត្រូវផ្តល់ទៅបណ្តាភាគីនៃវិវាទជាមួយនិងពត៌មានណាមួយ ឬ ការណែនាំណាមួយ ដែលខ្លួនទទួល និងឱកាសសំរាប់ផ្តល់អនុសាសន៍ ។

**របាយការណ៍**

២៤. សាលាក្តីត្រូវផ្តល់ទៅបណ្តាភាគីនៃវិវាទនូវរបាយការណ៍ដំបូង ជូបទៅនឹងតម្រូវការដែលបានបញ្ជាក់នៅក្នុងមាត្រា ១២.៣ ( មុខងាររបស់សាលាក្តី) ។

២៥. របាយការណ៍ដំបូងត្រូវផ្តល់យ៉ាងតិច ០៤ សប្តាហ៍ មុនកាលកំណត់ សំរាប់ការបញ្ចប់របាយការណ៍ចុងក្រោយ ។ សាលាក្តីត្រូវផ្តល់ឱកាសគ្រប់គ្រាន់ទៅបណ្តាភាគីនៃវិវាទក្នុងការពិនិត្យឡើងវិញនូវរបាយការណ៍ទាំងមូលមុនពេលបញ្ចប់ និងត្រូវបញ្ចូលរាល់យោបល់រាល់ការពិភាក្សាធ្វើឡើងដោយបណ្តាភាគីនៃវិវាទ នៅក្នុងរបាយការណ៍ចុងក្រោយ ។

២៦. របាយការណ៍ដំបូង និងរបាយការណ៍ចុងក្រោយរបស់សាលាក្តីត្រូវព្រាងដោយមិនមានវត្តមានរបស់បណ្តាភាគីនៃវិវាទ។ មតិ យោបល់ ដែលបានលើកឡើងនៅក្នុងរបាយការណ៍របស់សាលាក្តីដោយបុគ្គលជាសមាជិកត្រូវតែអនាមិក។

**ទីកន្លែង**

២៧. ទីកន្លែងសវនាការសាលាក្តី ត្រូវតែសម្រេចដោយការព្រមព្រៀងទៅវិញទៅមក រវាងបណ្តាភាគីនៃវិវាទ។ ប្រសិនបើមិនមានការព្រមព្រៀង ទីកន្លែងត្រូវតែឆ្លាស់គ្នារវាងរាជធានីរបស់បណ្តាភាគីនៃវិវាទ ជាមួយនិងសវនាការដំបូងត្រូវតែប្រព្រឹត្តិនៅក្នុងរាជធានីរបស់ភាគីប្តឹងតវ៉ា។

**លាភការ និងទូទាត់ចំណាយ**

២៨. សាលាក្តីត្រូវរក្សាទុកនូវបញ្ជី និងផ្តល់គណនីចុងក្រោយនៃរាល់ខ្ទង់ចំណាយទូទៅដែលកើតមានឡើងពាក់ព័ន្ធទៅនឹងទម្រង់ការ រាប់បញ្ចូលទាំង បានចំណាយសំរាប់ជំនួយការ អ្នកកត់ត្រាដែលបានចាត់តាំង ឬបុគ្គលដទៃទៀតដែលខ្លួនបានរក្សាទុក អនុលោមទៅតាមមាត្រា ១០។

## ឧបសម្ព័ន្ធស្តីពីនីតិវិធីជម្រើសសំរាប់សមាសធាតុសាលាក្តី

ដូចដែលបានផ្តល់នៅក្នុងមាត្រា ១១.៣ ( ការបង្កើត និង ប្រជុំឡើងវិញរបស់សាលាក្តី) បណ្តាភាគីនៃវិវាទអាចព្រមព្រៀងក្នុងការប្រើប្រាស់នីតិវិធីជម្រើសខាងក្រោម ឬ ការប្រែប្រួលរបស់វា សម្រាប់គោលបំណងនៃសមាសធាតុសាលាក្តី។

**ជម្រើសនីតិវិធី ក**

១. ភាគីប្តឹងតវ៉ា និងភាគីត្រូវឆ្លើយតបត្រូវចាត់តាំងអាជ្ញាកណ្តាលមួយរូបក្នុងកំឡុង (រយៈពេលដែលព្រមព្រៀងដោយបណ្តាភាគីនៃវិវាទ) នៃការបរិច្ឆេទទទួលការស្នើសុំបង្កើតសាលាក្តី។ ប្រសិនបើភាគីណាមួយ ខកខានក្នុងការចាត់តាំងអាជ្ញាកណ្តាលទៅក្នុងរយៈពេលនោះ នោះអាជ្ញាកណ្តាលដែលចាត់តាំងដោយភាគីដទៃ ត្រូវប្រតិបត្តិតែម្នាក់ឯងនៃសាលាក្តី។

២. ទីណាដែលអាជ្ញាកណ្តាលពីររូបត្រូវបានចាត់តាំងទៅតាមកថាខណ្ឌ ១ បណ្តាភាគីនៃវិវាទត្រូវចាត់តាំងដោយការព្រមព្រៀងរួមទៅនឹងអាជ្ញាកណ្តាលទីបី ដែលជាអ្នកត្រូវធ្វើប្រធានសាលាក្តី។ ប្រសិនបើបណ្តាភាគីវិវាទមិនទាន់បានចាត់តាំងប្រធានសាលាក្តីក្នុងកំឡុង (រយៈពេលដែលព្រមព្រៀងដោយបណ្តាភាគីនៃវិវាទ) នៃការចាត់តាំងអាជ្ញាកណ្តាលទីពីរ អាជ្ញាកណ្តាលពីររូបដែលបានចាត់តាំងទៅតាមកថាខណ្ឌ ១ ត្រូវចាត់តាំងដោយព្រមព្រៀងរួមអាជ្ញាកណ្តាលទីបី ដែលជាអ្នកត្រូវធ្វើប្រធានសាលាក្តី ប្រសិនបើប្រធានសាលាក្តីមិនទាន់ត្រូវបានចាត់តាំងដោយអាជ្ញាកណ្តាលក្នុងកំឡុង (រយៈពេលព្រមព្រៀងដោយបណ្តាភាគី) នៃការចាត់តាំងអាជ្ញាកណ្តាលទីពីរ អគ្គនាយកនៃអង្គការពាណិជ្ជកម្មពិភពលោក ត្រូវតាមការស្នើសុំរបស់ភាគីណាមួយនៃវិវាទ ចាត់តាំងប្រធានសាលាក្តីក្នុងកំឡុង (រយៈពេលព្រមព្រៀងដោយបណ្តាភាគីនៃវិវាទ) នៃការស្នើសុំនោះ។

**ជម្រើសនីតិវិធី ខ**

១. ភាគីប្តឹងតវ៉ា និងភាគីឆ្លើយតប អាចចាត់តាំងអាជ្ញាកណ្តាលមួយក្នុងកំឡុង (រយៈពេលព្រមព្រៀងដោយបណ្តាភាគី) នៃកាលបរិច្ឆេទទទួលការស្នើសុំបង្កើតសាលាក្តី។

២. បណ្តាភាគីនៃវិវាទត្រូវព្រមព្រៀងលើការចាត់តាំងនៃអាជ្ញាកណ្តាលទីបីក្នុងកំឡុង (រយៈពេលព្រមព្រៀងដោយបណ្តាភាគីនៃវិវាទ) នៃការចាត់តាំងអាជ្ញាកណ្តាលទីបី ដែលជាអ្នកត្រូវធ្វើប្រធានសាលាក្តី។ ប្រសិនបើការចាត់តាំងទាំងបីមិនទាន់បានធ្វើក្នុងកំឡុង (រយៈពេលព្រមព្រៀងដោយបណ្តាភាគីនៃវិវាទ) ការចាត់តាំងចាំបាច់ត្រូវធ្វើទៅតាមការស្នើសុំរបស់ភាគីវិវាទណាមួយ ដោយអគ្គនាយកអង្គការពាណិជ្ជកម្មពិភពលោក ក្នុងកំឡុងខាងមុខ (រយៈព្រមព្រៀងដោយបណ្តាភាគីនៃវិវាទ)។

**ជម្រើសនីតិវិធី គ**

១. ក្នុងកំឡុង (រយៈពេលព្រមព្រៀងដោយបណ្តាភាគីនៃវិវាទ) នៃកាលបរិច្ឆេទទទួលការស្នើសុំបង្កើតសាលាក្តី ភាគីនីមួយៗនៃវិវាទអាចផ្តល់ទៅបណ្តាភាគីដទៃនៃវិវាទ នូវបញ្ជីអ្នកដែលត្រូវជ្រើសរើស សំរាប់ចាត់តាំងជាអាជ្ញាកណ្តាល រួមបញ្ចូលយ៉ាងតិចបំផុតបុគ្គលពីររូប ដែលសាកសមសំរាប់ចាត់តាំងជាប្រធាន។ បណ្តាភាគីនៃវិវាទត្រូវ

បន្ទាប់ពីនោះ ពិគ្រោះគ្នាលើសមាសធាតុនៃសាលាក្តីក្នុងគោលបំណងចាត់តាំងអាជ្ញាកណ្តាល ចេញពីបញ្ជីអ្នកដែលត្រូវជ្រើសរើស ។

២. ប្រសិនបើអាជ្ញាកណ្តាលមិនទាន់ត្រូវបានចាត់តាំងក្នុងកំឡុង (រយៈពេលព្រមព្រៀងដោយបណ្តាភាគីនៃវិវាទ) នៃការស្នើសុំបង្កើតសាលាក្តី អាជ្ញាកណ្តាលដែលនៅសេសសល់ ត្រូវចាត់តាំងទៅតាមការស្នើសុំរបស់ភាគីណាមួយនៃវិវាទ ដោយជ្រើសរើសយកបន្តបន្ទាប់ពីបញ្ជីអ្នកដែលត្រូវជ្រើសរើសដោយឡែក សំរាប់គោលបំណងនេះ នៃបញ្ជីអ្នកដែលត្រូវជ្រើសរើសដោយឡែកសំរាប់ចាត់តាំងប្រធាន ឬ អាជ្ញាកណ្តាលធម្មតា ។

# ជំពូក ១៨
# បទបញ្ញត្តិចុងក្រោយ

## មាត្រា ១
## ឧបសម្ព័ន្ធ សេចក្ដីបន្ថែម និងលេខយោង

ឧបសម្ព័ន្ធ សេចក្ដីបន្ថែម និងលេខយោងទាំងឡាយ គឺជាផ្នែកនៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា ២
## ទំនាក់ទំនងទៅកិច្ចព្រមព្រៀងផ្សេងទៀត

១- ភាគីនីមួយៗ បញ្ជាក់បន្ថែមទៀតពីសិទ្ធិ និងកាតព្វកិច្ច នៅក្រោមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក (WTO) និងកិច្ចព្រមព្រៀងផ្សេងទៀត ដែលភាគីទាំងនោះជាហត្ថលេខី ។

២- គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយ ដើម្បីដកហូតសិទ្ធ ឬកាតព្វកិច្ចពីភាគីមួយនៅក្រោមកិច្ចព្រមព្រៀង WTO និងកិច្ចព្រមព្រៀងផ្សេងទៀត ដែលភាគីទាំងនោះជាហត្ថលេខី ។

៣- ក្នុងករណីដែលមានភាពមិនស្របគ្នាណាមួយរវាងកិច្ចព្រមព្រៀងនេះ និងកិច្ចព្រមព្រៀងផ្សេងទៀត ដែលមានភាគីពីរ ឬច្រើនជាហត្ថលេខី ភាគីនីមួយៗត្រូវពិគ្រោះយោបល់គ្នាភ្លាមៗ ដើម្បីស្វែងរកដំណោះស្រាយឱ្យមានការពេញចិត្តទាំងសងខាង ។

៤- គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវរារាំងដល់ប្រទេសជាសមាជិកអាស៊ានណាមួយ ពីការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវាកម្ម វិនិយោគ និង/ឬ វិស័យកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនានា ជាមួយប្រទេសសមាជិកអាស៊ានមួយ ឬច្រើន និង/ឬអូស្ត្រាលី និង/ឬ ណូវែលហ្សេឡង់ ។

៥- បទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ មិនត្រូវយកទៅអនុវត្តទៅលើកិច្ចព្រមព្រៀងណាមួយ ក្នុងបណ្ដាប្រទេសសមាជិកអាស៊ាន។ បទបញ្ញត្តិ នៃកិច្ចព្រមព្រៀងនេះ មិនត្រូវអនុវត្តទៅលើកិច្ចព្រមព្រៀងផ្សេងៗ ដែលពាក់ពន្ធ័នឹងប្រទេសសមាជិកអាស៊ានណាមួយ និង/ឬ ប្រទេសអូស្ត្រាលី និង/ឬ ណូវែលហ្សេឡង់ ដរាបណាបានព្រមព្រៀងដោយភាគីណាមួយនៃកិច្ចព្រមព្រៀង ។

### មាត្រា ៣

### វិសោធនកម្ម ឬ ស្ថានការណ៍កិច្ចព្រមព្រៀងអន្តរជាតិ

ប្រសិនបើកិច្ចព្រមព្រៀងអន្តរជាតិណាមួយ ឬបទបញ្ញត្តិមួយយោងនៅក្នុងកិច្ចព្រមព្រៀងនេះ (ឬភ្ជាប់ជាមួយកិច្ចព្រមព្រៀងនេះ) បានធ្វើវិសោធនកម្ម នោះភាគីនីមួយៗ ត្រូវតែពិគ្រោះយោបល់ទៅលើអ្វីដែលចាំបាច់ ធ្វើវិសោធនកម្មក្នុងកិច្ចព្រមព្រៀង លើកលែងតែកិច្ចព្រមព្រៀងមានអ្វីផ្សេងក្រៅពីនេះ ។

### មាត្រា ៤

### ការផ្សព្វផ្សាយពត៌មាន

លើកលែងតែអ្វីផ្តល់ដោយកិច្ចព្រមព្រៀងនេះ គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងដែលតំរូវឱ្យភាគីណាមួយផ្តល់នូវពត៌មានសំងាត់ ការផ្សព្វផ្សាយនិងត្រូវការពារតាមការអនុវត្តន៍ដោយច្បាប់ ឬពត៌មានអ្វីផ្សេងពីនេះ គឺវាផ្ទុយនឹងផលប្រយោជន៍សាធារណៈ ឬដែលនឹងខូចប្រយោជន៍ពាណិជ្ជកម្មនៃសហគ្រិន វិស័យសាធារណៈ ឬឯកជន ។

### មាត្រា ៥

### ការសំងាត់

លើកលែងតែបានផ្តល់ដោយកិច្ចព្រមព្រៀងនេះ ភាគីមួយផ្តល់ពត៌មានជូនទៅភាគីមួយផ្សេងទៀតដោយយោងតាមកិច្ចព្រមព្រៀងនេះ និងរៀបចំពត៌មានតាមបែបសំងាត់ ហើយភាគីដទៃទៀតត្រូវរក្សានូវពត៌មានសំងាត់នេះ ។ ពត៌មានទាំងនេះ នឹងប្រើប្រាស់សំរាប់តែគោលបំណងជាក់លាក់ និងមិនត្រូវផ្សព្វផ្សាយដោយពុំមានការអនុញ្ញាតត្រឹមត្រូវពីភាគីដែលផ្តល់ពត៌មាន លើកលែងតែភាគីដែលទទួលពត៌មាន ផ្តល់នូវពត៌មានតាមបណ្តឹងតុលាការត្រឹមត្រូវតាមច្បាប់នៅក្នុងស្រុក ។

### មាត្រា ៦

### វិសោធនកម្ម

កិច្ចព្រមព្រៀងនេះអាចនឹងធ្វើវិសោធនកម្ម តាមការសរសេរយល់ព្រមពីភាគីនិមួយៗ ហើយវិសោធនកម្មទាំងនេះ នឹងត្រូវចូលជាធរមានតាមកាលបរិច្ឆេទ ដែលបានព្រមព្រៀងដោយភាគីទាំងនេះ ។

## មាត្រា ៧
## ការចូលជាធរមាន

១- ភាគីនិមួយៗត្រូវជូនដំណឹងទៅភាគីដទៃផ្សេងទៀត ដោយសរសេរជាលាយលក្ខអក្សរ នៅពេលដែលបញ្ចប់នូវបែបបទក្នុងស្រុកសំរាប់ឱ្យកិច្ចព្រមព្រៀងនេះចូលជាធរមាន។ កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមាននៅថ្ងៃទី១ ខែកក្កដា ឆ្នាំ ២០០៩ សំរាប់ភាគីណាមួយដែលបានធ្វើការជូនដំណឹងថា ប្រទេសអូស្ត្រាលី ណូវែលហ្សេឡង់ និងប្រទេសសមាជិកអាស៊ានចំនួន ៤ យ៉ាងតិច បានជូនដំណឹងតាមកាលបរិច្ឆេទនេះ។

២- ប្រសិនបើកិច្ចព្រមព្រៀងនេះ មិនចូលជាធរមាននៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៩ កិច្ចព្រមព្រៀងចូលជាធរមានសំរាប់តែភាគីណា ដែលបានជូនដំណឹងយោងតាមកថាខណ្ឌ១ ៦០ ថ្ងៃ ក្រោយពីកាលបរិច្ឆេទដែលប្រទេសអូស្ត្រាលី ណូវែលហ្សេឡង់ និងប្រទេសសមាជិកអាស៊ាន ៤ យ៉ាងតិច ដែលបានធ្វើការជូនដំណឹងយោងតាមកថាខណ្ឌ១។

៣- ក្រោយពីការចូលជាធរមាននៃកិច្ចព្រមព្រៀង អនុលោមតាមកថាខណ្ឌ ១ ឬ កថាខ័ណ្ឌ២ កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមានសំរាប់ភាគីណាមួយ រយៈពេល ៦០ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងតាមកថាខណ្ឌ ១។

## មាត្រា ៨
## ការដកចេញ និងការបញ្ចប់

១- ភាគីមួយ អាចនឹងដកចេញពីកិច្ចព្រមព្រៀងនេះ តាមការផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខអក្សរជាលាក់ទៅឱ្យភាគីដទៃទៀត ក្រោយពី ៦ ខែ។

២- កិច្ចព្រមព្រៀងនេះ នឹងត្រូវបញ្ចប់ ប្រសិនបើផ្អែកតាមកថាខណ្ឌ ១ :

(ក) ប្រទេសអូស្ត្រាលី ដកចេញ

(ខ) ប្រទេសណូវែលហ្សេឡង់ ដកចេញ ឬ

(គ) កិច្ចព្រមព្រៀងនេះ ចូលជាធរមានដោយប្រទេសជាសមាជិកអាស៊ាន តិចជាង ៤។

## មាត្រា ៩
## ការពិនិត្យឡើងវិញ

ភាគីទាំងអស់ត្រូវធ្វើការពិនិត្យឡើងវិញជាទូទៅនូវកិច្ចព្រមព្រៀង រួមជាមួយនឹងទស្សនៈដាក់ចេញនូវទិសដៅបន្តទៀតនៅឆ្នាំ ២០១៦ និងរៀងរាល់ ៥ ឆ្នាំបន្ទាប់មក លើកលែងតែមានការព្រមព្រៀងណាផ្សេងដោយភាគីនិមួយៗ ។

បានចុះហត្ថលេខា នៅ........................ ថ្ងៃទី ខែ ឆ្នាំ ២០០៨ ចំនួន ៣ ច្បាប់ជាភាសាអង់គ្លេស ។

សំរាប់រដ្ឋាភិបាលប្រ៊ុយណេដារ៉ូសាឡាម

សំរាប់រដ្ឋាភិបាល នៃអូស្ត្រាលី

សំរាប់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

សំរាប់រដ្ឋាភិបាល នៃណូវែលហ្សេឡង់

សំរាប់រដ្ឋាភិបាល នៃសាធារណរដ្ឋឥណ្ឌូនេស៊ី

សំរាប់រដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតឡាវ

សំរាប់រដ្ឋាភិបាល នៃម៉ាឡេស៊ី

សំរាប់រដ្ឋាភិបាល នៃសហភាពមីយ៉ាន់ម៉ា

សំរាប់រដ្ឋាភិបាល នៃសាធារណរដ្ឋហ្វីលីពីន

សំរាប់រដ្ឋាភិបាល នៃសាធារណរដ្ឋសឹង្ហបុរី

សំរាប់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រថៃឡង់ដ៍

សំរាប់រាជរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

# ការយោគយល់គ្នាលើ
# មាត្រា ១ (ការកាត់បន្ថយ និង/ឬ ការលុបចោលពន្ធគយ)
# នៃជំពូក២ (ពាណិជ្ជកម្មទំនិញ)
# នៃកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់

រដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេដារូស្សាឡាម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបុរី ព្រះរាជាណាចក្រថៃ សាធារណរដ្ឋសង្គមនិយមវៀតណាម អូស្ត្រាលី និងណូវែលហ្សេឡង់ (បន្ទាប់ពីនេះគឺជា " ភាគី " នៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់) ដោយយោងលើកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ (ASEAN-Australia-New Zealand Free Trade Area – "AANZFTA") និងការបង្កើតនូវការយោគយល់រួមគ្នារបស់ពួកគេដូចខាងក្រោម :

ភាគីរបស់ AANZFTA បញ្ជាក់ពីការយោគយល់របស់ពួកគេថា កាតព្វកិច្ចដែលមានចែងនៅក្នុងមាត្រា ១ (ការកាត់បន្ថយ និង/ឬ ការលុបចោលនៃពន្ធគយ) នៃជំពូក២ (ពាណិជ្ជកម្មទំនិញ) មិនការពារភាគីនៃ AANZFTA ពីវិធានការទទួលយកនៅក្នុងភាពស្របគ្នាជាមួយមាត្រា ១ (ការលើកលែងទូទៅ) នៃជំពូក៥ (ការលើកលែង និងនិយមន័យទូទៅ) ឡើយ ។

ភាគីនីមួយៗ នៃ AANZFTA ត្រូវកត់សំគាល់ពីការយោគយល់គ្នានេះបន្ថែមទៀតថា វិធានការផ្សេងទៀតអាចបញ្ចូលក្នុងវិធានការដោយឈរលើមូលដ្ឋាននីយ័តកម្ម និងច្បាប់ក្នុងស្រុកដែលស្របនឹង Basel Convention on the Control of Transboundary Movements of Hazardous Wastes and their Disposal ឬកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត ។

បានចុះហត្ថលេខាក្នុងឆ្នាំពីរពាន់ប្រាំបី ខែ ..... ថ្ងៃទី ..... ចំនួនបីច្បាប់ ជាភាសាអង់គ្លេស ។

ត ទៅរាជកិច្ច លេខ ៨៥

# ព្រះរាជក្រឹត្យ

នស/រកត/១១១០/៩៤៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគុបិជាតិសាសនា រក្សាខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្មូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

## គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ចំពោះ

សប្បុរសជន វៀតណាម ចំនួន ០២រូប បានជួយឧបត្ថម្ភ ថវិកា ចំនួន ៣០០.០០០ ដុល្លារអាមេរិក
និងបំពេង ៣.០០០ គីឡូក្រាម ដល់បញ្ជាការដ្ឋានកងទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទ

១- វរសេនីយ៍ឯក TRAN QUOC LIEM
២- លោក TRAN VAN TRI

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រល. ១០១១. ៩៦៥

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១០

លេខ: ៧៦៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១០១០/៩៥០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

តែងតាំង

១- លោក អ៊ាប អេងហុង

២- លោក ឃួយ ត្រី

ជា

ឧកញ៉ា

៣រល.១០១១.៩៦៦

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១០

លេខ:៧៥៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃ៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១១១០/៩៥១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

មន្ត្រីរាជការ ចំនួន ០៧រូប ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធ ក្នុងបរិវេណសាកលវិទ្យាល័យបាត់ដំបង សំដៅរួមចំណែកលើវិស័យអប់រំឱ្យមានការរីកចម្រើនលំដាប់

**នូវ**

ក. គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

១- លោក ចាន់ សំបូរ
២- លោក សូ ប៊ុណ្ណារ៉ុង
៣- លោក លុត គៀន

ខ. គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សរិទ្ធិ ចំពោះ :

១- លោក ព្រួញ វិទ្ធថា
២- លោក សល់ សុនត្ត
៣- លោក សាន សិរីសិទ្ធិ
៤- លោក ឌិន ម៉ាក់ឆែល

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រ.ល. ១០១១.៩៦៧

លេខ: ៧៥៤ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០១០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ប៉ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១១១០/៩៥២

**យើង**

**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ក្រឹត្យ លេខ ២៨ ក្រ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការលើកលែងទោស និង បន្ធូរបន្ថយទោស
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវលើកលែងទោសឱ្យទណ្ឌិតចំនួន ០១ នាក់ ដែលមានឈ្មោះ **ដួង ធីមិញហ្វុង** ភេទស្រី អាយុ ៤៧ ឆ្នាំ ជនជាតិវៀតណាម សញ្ជាតិអូស្ត្រាលី ពីបទជួញដូរគ្រឿងញៀនឆ្លងដែនខុសច្បាប់ ហើយត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០.០០០.០០០ (ហាសិបលាន) រៀល តាមអំណាចសាលដីកាលេខ ១១ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ២០១០ របស់តុលាការ កំពូល ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*៣រល.១០១១.៩៦៩*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១០*

លេខ: ៧៥៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ២០១០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ជិនគេន**

**ព្រះរាជក្រឹត្យ**

នស/រកត/១១១០/៩៥៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

ចំពោះ

សប្បុរសជន ចំនួន០២រូប នៅខេត្តព្រះសីហនុ និងនៅក្រុងព្រៃវែង មានគុណបំណាច់និងស្នាដៃល្អក្នុងការកសាងនិងអភិវឌ្ឍន៍សមិទ្ធផលនានាលើគ្រប់វិស័យ ស្ថិតនៅស្រុកព្រះស្ដេច ខេត្តព្រៃវែង

នូវ

**ក-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :**
**លោកជំទាវ ស៊ាន ឈុនហេង ស្មៀង សារ៉ាត**

**ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :**
**អ្នកស្រី ម៉ក់ ជឹម**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

*៣រល. ១០១១.៩៦៩*

**នរោត្តម សីហមុនី**

លេខៈ៧៦១ ច.ល

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១០*

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី១០ ខែ វិច្ឆិកា ឆ្នាំ២០១០
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ចិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១១១០/៩៥៥

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

ចំពោះ

សប្បុរសជនបរទេស ចំនួន០២រូប មានគុណបំណាច់ និងស្នាដៃល្អក្នុងការ ចូលរួមកសាងមជ្ឈមណ្ឌលកុមារកំព្រា មួយកន្លែង នៅស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ

នូវ

**គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ៖**

១-លោក PAUL BRANDT

២-អ្នកស្រី MARIE ENS

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣រល. ១០១១. ៩៧១

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១០*

លេខ: ៧៦០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ចិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១១១០/៩៥៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានបញ្ចប់ភារកិច្ចឯកឧត្តម **ចាន់ ថ័ន** ពីទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល.១០១១.៩៧២

លេខ:៧៦៤ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ.ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១០

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ.ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១០*

**អគ្គលេខាធិការនៃរាជរដ្ឋាភិបាល**

**ស៊ិន ច័នកេន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០៩៦ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនជប៉ុន ចំនួន០៣រូប ដែលបានផ្តល់ថវិកាចូលរួមចំណែកក្នុងការជួយកសាងអគារសិក្សាចំនួន០២ខ្នងស្ថិតនៅក្នុងបរិវេណសាលាអនុវិទ្យាល័យទួលពង្រ ឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ចំណាយអស់ទឹកប្រាក់សរុបចំនួន ៧០.០០០ ដុល្លារ ដូចមានរាយនាមខាងក្រោម ៖

១-លោក **កិនហ្ស៊ិ អូតានី** ( KENJI OTANI ) ប្រធានអង្គការ CMC

២-លោក **ស៊ុណាអូ គូដាម៉ា** ( SUNAO KODAMA ) ប្រធានក្រុមហ៊ុន ដាតាម៉ាក់ (DATAMAX Co., Ltd )

៣-លោក **សីហ្ស៊ីរ៉ូ ស៊ីមិស៊ុ** ( SEIJIRO SHIMISU ) ប្រធានសមាគមអន្តរជាតិ នៃក្លឹបវ៉ាយ ម៉ិន អូសាកា-និស៊ិ
( President of International Association of y's men's clubs Osaka-Nishi )

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០៨៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ផ្តល់ជូនសប្បុរសជនចំនួន ០២រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា និងសង្គមកិច្ច ស្ថិតនៅក្នុងស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

**ខ. មេដាយមុនីសារាភ័ណ្ឌថ្នាក់ធិបឌិន្ទចំនួន ០១ គ្រឿង ផ្តល់ជូន**

លោក **ស៊ឹម កុសល** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៣៦.៧០០ ដុល្លារ

**គ. មេដាយមុនីសារាភ័ណ្ឌថ្នាក់អស្សឫទ្ធិចំនួន ០១ គ្រឿង ផ្តល់ជូន**

លោកជំទាវ **មាស ទី** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ២១.១០០ ដុល្លារ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តព្រៃវែង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១០៥៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ផ្តល់ជូនមន្ត្រីរាជការចំនួន ០៣ រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលលើវិស័យនានា ស្ថិតនៅក្នុងខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

១-លោកស្រី **សរិត ចំនួនចំណ្ណ** មន្ត្រីរដ្ឋបាលក្រសួងមហាផ្ទៃ

២-លោកអនុសេនីយ៍ឯក **មាស សុគ័ន្ធ្រ** នាយការិយាល័យព័ត៌មានទូទៅ នៃកងរាជអាវុធហត្ថខេត្ត អត្តលេខ ០១៥៨៣៧

៣-លោកអនុសេនីយ៍ទោ **ផាន់ ចំន្ទកោសី** មេបញ្ជាការរងកងរាជអាវុធហត្ថស្រុកពាមរក៍ អត្តលេខ ១៩៦៥៨

**មាត្រា ២.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តព្រៃវែង និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០៩៩ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនមន្ត្រីរាជការ និងសប្បុរសជននៅក្នុង និងក្រៅប្រទេសចំនួន ៧៥ រូប ដែលបានលះបង់កំលាំងកាយចិត្ត និង បរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា និងសង្គមកិច្ច ស្ថិតនៅក្នុងស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ១៩ គ្រឿង ប្រគេន និងផ្តល់ជូន :**

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **ស៊ិន** | **ស៊ា** | ធម្មធរ អនុគណសង្ឃស្រុកកញ្ជ្រៀច | បច្ច័យចំនួន ១៤.៧៥០ ដុល្លារ |
| ២-ព្រះតេជគុណ | **អ៊ឹម** | **ថន** | ព្រះវិន័យធរ អនុគណស្រុកស្វាយអន្ទរ | បច្ច័យចំនួន ១៤.៦៦០ ដុល្លារ |
| ៣-ព្រះតេជគុណ | **ឈួន** | **តុខស្រ៊ីន** | លេខាធិការ អនុគណស្រុកកញ្ជ្រៀច | បច្ច័យចំនួន ១៤.៦៤១ ដុល្លារ |
| ៤-ព្រះតេជគុណ | **ហុក** | **ចាន់ឆួន** | ព្រះចៅអធិការវត្តត្នោត | បច្ច័យចំនួន ១៤.៥៩០ ដុល្លារ |
| ៥-លោក | **កែវ** | **សុធា** | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១៤.៤៧១ ដុល្លារ |
| ៦-លោក | **ឃុត** | **នួន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៤.៤៥៣ ដុល្លារ |
| ៧-លោក | **ឈិន** | **ចាន់** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៤.៣២៤ ដុល្លារ |
| ៨-លោក | **អម** | **អ៊ឹម** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ១៤.៣១៥ ដុល្លារ |
| ៩-លោក | **ខួន** | **គីមស្រេង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៣.៩៣០ ដុល្លារ |
| ១០-លោក | **ពុត** | **គូ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៣.៨៧០ ដុល្លារ |
| ១១-លោក | **ឈី** | **សុខុម** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ១៣.៧៥០ ដុល្លារ |
| ១២-លោក | **ស៊ាន** | **ពុធ** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ១៣.៧៤០ ដុល្លារ |

១៣-លោក **ហ៊ាង ហុង** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ១៣.៦៧០ ដុល្លារ
១៤-លោក **ប៊ី ឆ៊ន** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ១៣.៥៧០ ដុល្លារ
១៥-លោក **មឿន សេង** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ១៣.៤៦០ ដុល្លារ
១៦-លោក **ឆន លាង** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ១៣.៣៧០ ដុល្លារ
១៧-លោក **នាង ឈូ** សប្បុរសជនខ្មែររស់នៅប្រទេសបារាំង ថវិកាចំនួន ១៣.៣០០ ដុល្លារ
១៨-លោក **ទុំ នៅ** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ១៣.២៤៥ ដុល្លារ
១៩-លោក **ឈាន ឈន់** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ១៣.២៣០ ដុល្លារ

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ៤៤ គ្រឿង ប្រគេន និងផ្តល់ជូន :**

១-ព្រះតេជគុណ **គាន ម៉ុនឡឿន** ព្រះចៅអធិការវត្តចុងអំពិល បច្ច័យចំនួន ៥.៣២០ ដុល្លារ
២-លោក **នួន ឈាងប៊ូ** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៥.៩៦០ ដុល្លារ
៣-លោក **យាន គីមស៊ែ** សប្បុរសជននៅខេត្តកំពង់ចាម ថវិកាចំនួន ៥.៩៥០ ដុល្លារ
៤-លោក **ពត មាស** សប្បុរសជននៅខេត្តកំពង់ចាម ថវិកាចំនួន ៥.៩៣០ ដុល្លារ
៥-ឧបាសិកា **ស៊ឹម ផល្លា** សប្បុរសជននៅខេត្តកំពង់ចាម ថវិកាចំនួន ៥.៩២០ ដុល្លារ
៦-លោក **ហាស់ មិត** សប្បុរសជននៅខេត្តកំពង់ចាម ថវិកាចំនួន ៥.៩២០ ដុល្លារ
៧-ឧបាសក **ឌី សាន** សប្បុរសជននៅខេត្តកំពង់ចាម ថវិកាចំនួន ៥.៩១០ ដុល្លារ
៨-លោកស្រី **អៀច ស្រីម៉ៅ** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៥.៨៥០ ដុល្លារ
